ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៨ លេខ ៣ | ខែកញ្ញា ២០១៤ | តម្លៃ ១.៥០០៛

# ព្រៃសហគមន៍ សម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងជីវភាពល្អប្រសើរ៖ ករណីសិក្សាលើក្រុមអ្នកប្រើប្រាស់ព្រៃឈើសហគមន៍អូរសោម

## សេចក្តីផ្តើម

ព្រៃឈើរួមចំណែកសំខាន់ណាស់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច។ ការពិតជាក់ស្តែងដូចខាងក្រោមបង្ហាញថា ព្រៃឈើសំខាន់ខ្លាំងប៉ុណ្ណា ក្នុងការដោះស្រាយតម្រូវការរបស់មនុស្សច្រើនពាន់លាននាក់ដែលពឹងផ្អែកលើផល និងសេវាព្រៃឈើ ដើម្បីរកបានម្ហូបអាហារ ថាមពល និងទីជម្រក។ មនុស្សយ៉ាងហោចណាស់ ១,៣ ពាន់លាននាក់ ឬ ១៨% នៃប្រជាជននៅលើពិភពលោក កំពុងរស់នៅក្នុងផ្ទះដែលសាងសង់ឡើងជាសំខាន់ អំពីផលព្រៃឈើ (FAO 2014)។ មនុស្សប្រហែល ១៣,២លាននាក់ កំពុងបម្រើការងារ ក្នុងវិស័យផ្លូវការទាក់ទងនឹងព្រៃឈើ ហើយយ៉ាងហោចណាស់មាន ៤១លាននាក់ទៀតកំពុងធ្វើការ ក្នុងវិស័យមិនផ្លូវការទាក់ទងនឹងព្រៃឈើ (FAO 2014)។ តាមការប៉ាន់ស្មាន មនុស្សប្រហែល ២,៤ពាន់លាននាក់ ឬ ៤០% នៃប្រជាជនក្នុងប្រទេសមានប្រាក់ចំណូលទាប តែងប្រើអុសសម្រាប់ចម្អិនអាហារ និង ៧៦៤លាននាក់ទៀតប្រើវាសម្រាប់ដាំទឹក (FAO 2014)។



ការចូលរួមក្នុងក្រុមអ្នកប្រើប្រាស់ព្រៃឈើនៅអូរសោម ខេត្តកំពង់ធំ បានជួយបង្កើនកម្រិតជីវភាព ខែសីហា ២០១៤

នៅកម្ពុជា ក៏ដូចជានៅប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀតដែលស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍ស្រដៀងគ្នានោះ វិស័យព្រៃឈើរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ច។ វិស័យនេះរួមចំណែក ៨,៤% ក្នុង ផសស កម្ពុជា ពីឆ្នាំ១៩៩៩ ដល់ ២០០៨ (Koy and Sasaki 2013) និង ៣,២% នៅឆ្នាំ២០១១ ដែលជាអត្រាដ៏ខ្ពស់បំផុត ក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ (FAO 2014)។ ព្រៃឈើបន្តដើរតួនាទីសំខាន់ក្នុងជីវភាពនៅតាមជនបទ ព្រោះជាង ៨០% នៃប្រជាជនកម្ពុជា(ប្រហែល ១៥លាននាក់) ឬប្រមាណ ៩០% នៃប្រជាជនក្រីក្រ កំពុងរស់នៅក្នុងតំបន់ជនបទ (NIS 2013)។ ម្យ៉ាងទៀត ប្រមាណ ២,២លានគ្រួសារ (៧១% នៃចំនួនគ្រួសារសរុប) ដែលភាគច្រើនរស់នៅតាមទីជំរាលនៃតំបន់ដីខ្ពស់ និងតំបន់ទន្លេសាប កំពុងពឹងផ្អែកដោយផ្ទាល់លើព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត (NIS 2013)។

## មាតិកា

ព្រៃសហគមន៍ សម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភា និងជីវភាពល្អប្រសើរ ........ ១
២០ឆ្នាំ ធ្វើការពង្រឹងសង្គមស៊ីវិលនៅកម្ពុជា៖ ដល់ពេលត្រូវបូកសរុបឡើងវិញ ........ ១០
កំណែទម្រង់វិមជ្ឈការ និងការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋាននៅទីជនបទ ........ ១៤
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៨
— ស្ថានភាពក្នុងប្រទេស ........ ២០
— សូចនាករ ........ ២២
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២៨

---

រៀបចំឡើងដោយ លន់ពេជ្រតារា អ្នកស្រាវជ្រាវ កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI ជា ណារ៉េត អនុប្រធានការិយាល័យផែនការ និងរដ្ឋបាលរបស់នាយកដ្ឋានរុក្ខាប្រម៉ាញ់ និងសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើ និង ម៉ា វុទ្ធី អនុប្រធាន មជ្ឈមណ្ឌលវាយតម្លៃពីធនធានព្រៃឈើ និងផលប៉ះពាល់ផ្នែកបរិស្ថាន និងសេដ្ឋកិច្ចសង្គម នៃរដ្ឋបាលព្រៃឈើ។ គួរយោងឯកសារនេះថា៖ Lonn Pichdara, Chea Nareth and Ma Vuthy. 2014. “Community Forestry for Sustainable Forest Management and Livelihoods: A Case Study of Osoam Community Forest Users Group”, *Cambodia Development Review*, 18(3): 1-9។

ការថយចុះព្រៃឈើ ជាការគម្រាមកំហែងច្បាស់លាស់ និងដោយផ្ទាល់ទៅលើធនធានសម្រាប់ចិញ្ចឹមពោះ និងសកម្មភាពបង្កើតចំណូលដ៏សំខាន់ៗបំផុត សម្រាប់ការចិញ្ចឹមជីវិតនៅតាមមូលដ្ឋានដែលពឹងផ្អែកលើព្រៃឈើ។ គម្របព្រៃឈើបានធ្លាក់ចុះពី ៧៣% នៃផ្ទៃដីសរុបនៅកម្ពុជា នៅឆ្នាំ១៩៦០ មកត្រឹម ៥៧,៥៩% នៅឆ្នាំ២០១០ ដែលស្មើនឹងអត្រាបាត់បង់ព្រៃឈើប្រចាំឆ្នាំ 0,5% (FA 2011)។ ការគ្រប់គ្រងប្រកបដោយគតិទៅលើព្រៃឈើនៅសេសសល់សំខាន់ខ្លាំងណាស់ សម្រាប់ទប់ស្កាត់ការបាត់បង់ព្រៃឈើ ការរក្សាសេវាប្រព័ន្ធអេកូឡូស៊ី និងការផ្តល់នូវប្រភពសម្រាប់ការចិញ្ចឹមជីវិត។ ដើម្បីពង្រឹងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងលើកកម្ពស់សុខុមាលភាព និងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចទៅថ្ងៃអនាគត របស់សហគមន៍ព្រៃឈើនោះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូល ការគ្រប់គ្រងព្រៃឈើផ្អែកលើសហគមន៍ ទៅក្នុងគោលនយោបាយ និងការធ្វើផែនការ (RGC 2013)។ នៅដើមទសវត្សរ៍១៩៩០ រដ្ឋាភិបាលបានអនុម័តប្រើវិធីសាស្ត្រព្រៃសហគមន៍ដើម្បីកាត់បន្ថយការបាត់បង់ព្រៃឈើ (FA 2013; Ty 2013)។ គោលដៅមួយក្នុងកម្មវិធីជាតិ ស្តីពីព្រៃឈើ គឺការលៃចែកដីព្រៃ ២លានហិកតាសម្រាប់ដាក់ក្រោម ការគ្រប់គ្រងរបស់សហគមន៍នៅត្រឹមឆ្នាំ២០២៩ (FA 2013)។

ទោះបីមានការទទួលស្គាល់ជាទូទៅ ពីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចសង្គមកិច្ច និងបរិស្ថាននៃព្រៃសហគមន៍នៅកម្ពុជាក៏ដោយ ក៏នៅមានការយល់ដឹងតិចតួចពីលទ្ធផលសម្រេចបាន ចំណុចខ្វះខាត ឬបញ្ហារារាំងដល់ចីរភាព ពិសេសបន្ទាប់ពីជំនួយទ្រទ្រង់ពីខាងក្រៅបានចប់អស់។ ម្យ៉ាងទៀត គោលគំនិតនៃ ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ហាក់ពុំមានការយល់ដឹងជាទូទៅទេ។

ដើម្បីពិនិត្យបញ្ហាដូចខាងលើ អត្ថបទនេះបានសិក្សាពីសំណួរគន្លឹះបី៖ តើសហគមន៍ព្រៃឈើនៅកម្ពុជាមានស្ថានភាពយ៉ាងណា? តើសហគមន៍ព្រៃឈើបានរួមចំណែកអ្វីខ្លះ ដល់ការអភិរក្សព្រៃឈើ និងការសម្រេចបាននូវសន្តិសុខក្នុងជីវភាពរស់នៅ? តើនៅមានបញ្ហាប្រឈមចម្បងៗអ្វីខ្លះត្រូវដោះស្រាយ ដើម្បីជួយឲ្យសហគមន៍ព្រៃឈើអាចរក្សាចីរភាពបានដោយខ្លួនឯង? ការសិក្សានេះ ចាប់ផ្តើមតាមការពិនិត្យជារួម លើការអភិវឌ្ឍសហគមន៍ព្រៃឈើនៅកម្ពុជា បន្ទាប់មកស្វែងរកចម្លើយលើសំណួរទាំងបី ដោយប្រើករណីសិក្សា និងការវិភាគ SWOT (ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង) លើគម្រោងសហគមន៍ព្រៃឈើមួយ ក្នុងភូមិសាលាវិស័យ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ។

រូបភាព ១៖ ចំនួន និងផ្ទៃដី (១០០០ហិកតា) នៃតំបន់សហគមន៍ព្រៃឈើ ឆ្នាំ២០០៨-១៣




ប្រភព៖ MAFF 2014

រូបភាព ២៖ បំណែងចែកតំបន់ព្រៃសហគមន៍ គិតតាមខេត្ត (១០០០ហិកតា), ខែមិថុនា ២០១៣




ប្រភព៖ FA 2013

រូបភាព ៣៖ តំបន់ព្រៃសហគមន៍នៅកម្ពុជា




ប្រភព៖ FA 2013

## ការពិនិត្យជារួមលើសហគមន៍ព្រៃឈើនៅកម្ពុជា

### *ស្ថានភាពបច្ចុប្បន្ននៃសហគមន៍ព្រៃឈើ*

មកដល់ឆ្នាំ២០១៤ មាន ៤៧៩ក្រុមសហគមន៍ព្រៃឈើ ត្រូវបានបង្កើតឡើងក្នុង ២១ខេត្ត ដោយគ្របដណ្តប់លើផ្ទៃដី ៤០៩.២៣៩ហិកតា (រូបភាព ១)។ ក្នុងនោះ ៣៦៤ក្រុម

តារាង ១៖ ការប្រែប្រួលក្នុងចំនួនភាគរយនៃផ្ទៃដីមានគម្របព្រៃ ពីឆ្នាំ២០០២ ដល់ ២០១០ នៅក្នុងតំបន់ព្រៃសហគមន៍ តំបន់ទ្រនាប់ និង តំបន់ការពារ

| ទីតាំង | គម្របព្រៃ (%) | | | ការប្រែប្រួលគម្របព្រៃ (%) | | |
|---|---|---|---|---|---|---|
| | 2002 | 2006 | 2010 | 2002-06 | 2006-10 | 2002-10 |
| តំបន់ព្រៃសហគមន៍ | 89.22 | 88.15 | 87.13 | -1.07 | -1.02 | -2.09 |
| តំបន់ព្រៃទ្រនាប់ក្នុងរង្វង់ ៣គម ពីព្រំប្រទល់ព្រៃសហគមន៍ | 64.70 | 61.23 | 58.13 | -3.47 | -3.10 | -6.57 |
| ព្រៃក្នុងតំបន់ការពារ | 81.99 | 80.47 | 78.72 | -1.52 | -1.75 | -3.27 |

ប្រភព៖ Ty 2013

(៣២៩.៥៨៧ហិកតា) បានទទួលការអនុម័តយល់ព្រមជាផ្លូវការ ហើយ ៣០៩ក្រុម (២៧៥.៦៣៤ហិកតា) បានដំណើរការក្រោមកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ រវាងផ្នែករដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) នឹងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើនីមួយៗ (FA 2013)។

ដូចមានបង្ហាញក្នុង រូបភាព ២ និង ៣ ខេត្តឧត្តរមានជ័យមានផ្ទៃដីធំជាងគេ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់សហគមន៍ព្រៃឈើ (៦៥.១៦៨ហិកតា) ហើយបន្ទាប់មកគឺ កំពង់ធំ (៥៤.៦៥២ហិកតា) ក្រចេះ (៤៧.១៩២ហិកតា) និង ព្រះវិហារ (៣៧.០៦៣ហិកតា) (FA 2013)។ ដោយមានការជំរុញអំពីគម្រោងកាបូនសហគមន៍ព្រៃឈើរបស់ REDD[១] ដែលគ្របដណ្ដប់លើផ្ទៃដី ៦៧.៨៥៣ហិកតានោះ ខេត្តឧត្តរមានជ័យក៏មានផ្ទៃដីធំជាងគេដែរ (៦៤.៣១៨ហិកតា) ដែលត្រូវបានគ្រប់គ្រងជាព្រៃសហគមន៍ ក្រោមកិច្ចព្រមព្រៀងស្ដីពីសហគមន៍ព្រៃឈើ (Ty et al. 2011)។

## ការរួមចំណែកនៃសហគមន៍ព្រៃឈើ ក្នុងការអភិរក្សព្រៃឈើ និងក្នុងចំណូលគ្រួសារ

### *ការអភិរក្សព្រៃឈើ*

ការសិក្សានាពេលថ្មីៗមួយស្ដីពី ការប្រែប្រួលនៃគម្របព្រៃឈើនៅកម្ពុជា ពីឆ្នាំ២០០២ ដល់ ២០១០ ដែលបានប្រៀបធៀបតំបន់ព្រៃសហគមន៍ ជាមួយនឹងតំបន់ព្រៃឈើនៅជាប់គ្នា និងតំបន់ការពារ បានរកឃើញថា ព្រៃសហគមន៍ជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយ នៃការអភិរក្សធនធានព្រៃឈើ (Ty 2013)។ លទ្ធផលចុះក្នុង តារាង ១ បង្ហាញថា ការថយចុះផ្ទៃដីមានគម្របព្រៃឈើ មានអត្រាទាបបំផុតនៅក្នុងតំបន់ព្រៃសហគមន៍ គឺត្រឹមប្រហែល ២% ធៀបនឹង ៦,៦% ក្នុងតំបន់ទ្រនាប់ និង ជាង ៣% ក្នុងតំបន់ការពារ។

ទោះបីមានការធ្វើវិមជ្ឈការ លើការគ្រប់គ្រងព្រៃសហគមន៍ ជាង ២០ឆ្នាំមកហើយក្ដី ក៏នៅតែមានបញ្ហាការបាត់បង់ព្រៃឈើ ការរេចរឹលព្រៃឈើ និងភាពក្រីក្រ នៅក្នុងសហគមន៍ព្រៃឈើ។ កម្រិតពឹងផ្អែកលើព្រៃឈើ ក្នុងចំណោមប្រជាជនដែលត្រូវការប្រើប្រាស់ព្រៃឈើ ឬប្រព័ន្ធដាំដុះបែបប្រពៃណី នៅមានកម្រិតខ្ពស់ ព្រោះពួកគេគ្មាន ឬក៏មានតិចតួចនូវប្រភពចំណូលសម្រាប់ជំនួស។ ក្រុមសហគមន៍ព្រៃឈើភាគច្រើន ស្ថិតក្នុងដំណាក់កាលដំបូងៗនៃការស្ដារតំបន់ព្រៃឈើរបស់ខ្លួនឡើងវិញ និងមិនទាន់បានរៀបចំផែនការគ្រប់គ្រងធនធាននោះទេ (Ty 2013)។ ផែនការនេះ ចាំបាច់ណាស់សម្រាប់គ្រប់គ្រងធនធានឲ្យបានសព្វគ្រប់ និងទទួលបានការអនុម័តយល់ព្រមជាផ្លូវការ ទើបសហគមន៍អាចចាប់ផ្ដើមទាញយកផល ជាលក្ខណៈពាណិជ្ជកម្មពីធនធានព្រៃឈើរបស់ខ្លួន ក្នុងនេះការកាប់ឈើសម្រាប់គោលដៅពាណិជ្ជកម្ម រំពឹងថានឹងជួយបង្កើនចំណូលគ្រួសារ។

### *ចំណូលគ្រួសារ*

កន្លងមកមិនទាន់មានការវាយតម្លៃពី ផលប៉ះពាល់នៃសហគមន៍ព្រៃឈើ ទៅលើស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់គ្រួសារជាសមាជិកនោះទេ (Sunderlin 2006)។ ដោយសារមានតែតំបន់ព្រៃរេចរឹលមាន ដើមឈើមានតម្លៃទាបដែលត្រូវបានលៃចែកសម្រាប់សហគមន៍ព្រៃឈើនោះ ដូច្នេះអត្ថប្រយោជន៍នៅក្នុងមូលដ្ឋានមានត្រឹមតែការប្រមូលអនុផលព្រៃឈើ (NTFP) ប៉ុណ្ណោះ។ ចំណូលទទួលបាន សឹងតែមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពប្រជាជន ដែលពឹងផ្អែកលើព្រៃឈើនៅក្នុងមូលដ្ឋានផង កុំថាឡើយដល់លើកកម្ពស់ជីវភាពនោះ។ ផ្ទុយគ្នាស្រឡះ ព្រៃឈើគ្រប់គ្រងដោយរដ្ឋមានតម្លៃខ្ពស់ផ្នែកសេដ្ឋកិច្ច ពោលគឺ មានប្រភេទឈើកម្រ ឈើមានតម្លៃខ្ពស់ ជីវៈចម្រុះសម្បូរបែប និងអនុផលព្រៃឈើយ៉ាងច្រើន ហើយអាចបង្កើតចំណូលពីព្រៃឈើបានច្រើនជាងព្រៃងកជន និងព្រៃគ្រប់គ្រងដោយសហគមន៍ បើគិតជាចំណូលក្នុងមួយគ្រួសារ ឬក្នុងដីមួយហិកតា (Jagger et al. 2014)។ ច្បាស់ណាស់ ការអភិវឌ្ឍសហគមន៍ព្រៃឈើត្រូវមាន ការយកចិត្តកាន់តែខ្លាំងខាងផ្នែកគោលនយោបាយ និងជំនួយទ្រទ្រង់ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុជាបន្តបន្ទាប់ ទើបអាចចូលរួមចំណែកបានជាក់ស្ដែង ក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិរក្សជីវៈចម្រុះ (de Lopez 2004)។

---

១ អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្ដីពី ការប្រែប្រួលអាកាសធាតុ (UNFCCC) បានកំណត់និយមន័យ REDD+ ថាជា៖ "វិធីសាស្ត្រផ្នែកគោលនយោបាយ និងគ្រឿងលើកទឹកចិត្តវិជ្ជមាន លើបញ្ហាទាក់ទងនឹងការកាត់បន្ថយឧស្ម័នបំភាយចេញតាមការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ព្រមទាំងតួនាទីនៃការអភិរក្ស, ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការពង្រីកស្ដុកកាបូនព្រៃឈើក្នុងប្រទេសកំពុងអភិវឌ្ឍន៍" (Solution Exchange 2010, 1). សកម្មភាពនៅក្រោម REDD+ រួមមាន៖ ការកាត់បន្ថយឧស្ម័នបំភាយចេញតាមការបាត់បង់ព្រៃឈើ (RED), ការកាត់បន្ថយឧស្ម័នបំភាយចេញតាមការរេចរឹលព្រៃឈើ, ការអភិរក្សស្ដុកកាបូនព្រៃឈើ ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការពង្រីកស្ដុកកាបូន (Solution Exchange 2010,1)។

ការសិក្សាមួយក្នុងឆ្នាំ២០១១ លើ ៣សហគមន៍ ស្ថិតនៅជាប់តំបន់ព្រៃក្នុងខេត្ត កំពត កំពង់ធំ និង កំពង់ស្ពឺ បានប៉ាន់ស្មានថា ចំណូលពីព្រៃឈើ រួមចំណែកជាមធ្យមប្រមាណ ២៥% ក្នុងចំណូលគ្រួសារប្រចាំឆ្នាំ (ទាំងជាប្រាក់កាស និងការចិញ្ចឹមពោះ) គឺពី ៧៤ដុល្លារ ដល់ ១៥១ដុល្លារ ឬស្មើនឹង ៣០៣.០០០រៀល ដល់ ៦១៨.០០០រៀល (±១៨.០០០រៀល ទៅ ២២.០០០រៀល) (Koy and Sasaki 2013)។ តួលេខនេះ ទាបខ្លាំងជាងការសិក្សាពីមុនៗ ដែលប៉ាន់ស្មានថា ចំណូលពីព្រៃឈើរួមចំណែកក្នុងចំណូលគ្រួសារប្រចាំឆ្នាំ បានពី ១៦៣ដុល្លារ (៦៦៨.០០០រៀល) ដល់ ៤១៤ដុល្លារ (១.៦៩៦.០០០រៀល) (Kasper and Top 2006)។ ភាពខុសគ្នានេះ អាចបណ្ដាលជាចម្បងមកពីវិធីសាស្ត្រខុសគ្នាក្នុងការវាយតម្លៃពីស្ថានភាពព្រៃឈើ។ ការសិក្សាមួយទៀតក្នុងឆ្នាំ២០០៧ ដើម្បីវាយតម្លៃពីការរួមចំណែកនៃ NTFP នៅក្នុងចំណូលរបស់សមាជិកសហគមន៍ព្រៃឈើភ្នំកុក (ក្នុងខេត្តរតនគិរី) រកឃើញថា NTFP ផ្ដល់ចំណូលជាមធ្យម ៧៩ដុល្លារក្នុងអ្នកប្រមូលម្នាក់ក្នុងមួយឆ្នាំ (Kim, Sasaki and Koike 2008)។ បើសិនបែងចែកទៅតាមប្រភេទធនធាន គឺ NTFP បានពីរុក្ខជាតិ (អាហារ, រុក្ខជាតិចំណីសត្វចិញ្ចឹម, ឱសថ, គ្រឿងផ្សំផលិតផលកែសម្ផស្ស, សម្ភារសំណង់ និងជ័រឈើ) ផ្ដល់ចំណូលប្រចាំឆ្នាំជាមធ្យម ៥៨,៥ដុល្លារ ក្នុងអ្នកប្រមូលម្នាក់ (ក្នុងចន្លោះពី ៥ដុល្លារ ទៅ ២៧០ដុល្លារ) ហើយ NTFP បានពីសត្វ (សត្វរស់, ទឹកឃ្មុំ, ក្រមួនឃ្មុំ, សាច់សត្វព្រៃ, ស្បែក, ឱសថ, គ្រឿងផ្សំថ្នាំជ្រលក់ពណ៌) ផ្ដល់បានប្រហែល ៥០ដុល្លារ (Kim, Sasaki and Koike 2008)។

ការអភិរក្ស និងការគ្រប់គ្រងធនធាន NTFP ជាវិធីសាស្ត្រអាចអនុវត្តបាន ដើម្បីកែលំអលទ្ធភាពចិញ្ចឹមពោះ និងសេដ្ឋកិច្ចសាច់ប្រាក់របស់សហគមន៍ដែលពឹងផ្អែកលើព្រៃឈើ (Hall and Bawa 1993)។ ក្នុងនេះ គេមិនបានគិតចូលទេនូវផលប្រយោជន៍មិនអាចកំណត់ជារូបិយវត្ថុបាន ដូចជា ស្តុកនៃធនធានព្រៃឈើដែលមិនទាន់ផ្ដល់ផលភ្លាមៗ និងផលប្រយោជន៍ផ្សេងទៀត ដូចជា អារម្មណ៍រីករាយនឹងលំអធម្មជាតិ ការលំហែកាយ និងតម្លៃផ្នែកវប្បធម៌និងបេតិកភណ្ឌ ដែលអាចទទួលបានពីធនធាន និងសេវាព្រៃឈើមានសុខភាពល្អ។ គួយ៉ាងអេកូទេសចរណ៍ដំណើរការដោយសហគមន៍នៅចំបក់ ក្នុងខេត្តកំពង់ស្ពឺ បានផ្ដល់នូវប្រភពចំណូលមួយទៀត និងលើកទឹកចិត្តសហគមន៍ឲ្យការពារតំបន់ធម្មជាតិនៅមូលដ្ឋានខ្លួន។ ដោយសារមានទេសភាពព្រៃឈើល្អត្រកាល ពីឆ្នាំ២០០២ ដល់ ២០១០ សហគមន៍អាចរកចំណូលប្រចាំឆ្នាំបានជាមធ្យម ១០.០០០ដុល្លារ ពីភ្ញៀវជាតិ និងអន្តរជាតិ។ ក្នុងឆ្នាំ២០១១ សមាជិកសហគមន៍រកចំណូលប្រចាំខែបានប្រមាណ ១០ដុល្លារ/គ្រួសារ ដែលភាគច្រើនបានពីអេកូទេសចរណ៍ (Lonn et al. 2012)។

## *បញ្ហាប្រឈមចំពោះសហគមន៍ព្រៃឈើ៖ កត្តាជំរុញការបាត់បង់ និងការរេចរឹលព្រៃឈើ*

អត្រាបាត់បង់ និងអត្រារេចរឹលព្រៃឈើ កំពុងចោទបញ្ហានៅពាសពេញកម្ពុជា រួមទាំងតំបន់ព្រៃសហគមន៍ផង។ ការបាត់បង់ព្រៃឈើដែលតាមនិយមន័យ គឺជា "ការផ្លាស់ប្ដូរដីព្រៃ ទៅជាដីសម្រាប់ការប្រើប្រាស់មួយបែបទៀត ដោយសារសកម្មភាពមនុស្ស (សម្រាប់ការធ្វើកសិកម្ម និងការតាំងលំនៅដ្ឋានជាសំខាន់) ឬដោយសារគ្រោះធម្មជាតិ ដូចជា បន្ទុះភ្នំភ្លើង ការរញ្ជួយផែនដី ឬទឹកជំនន់ (FAO n.d., 1) ដែលអាចប៉ះពាល់មិនល្អច្រើនយ៉ាងទៅលើបរិស្ថាន។ ការរេចរឹលព្រៃឈើ សំដៅដល់ "ការផ្លាស់ប្ដូរក្នុងព្រៃឈើ ដែលប៉ះពាល់មិនល្អទៅលើរចនាសម្ព័ន្ធ ឬមុខងារនៃតំបន់ព្រៃ ហើយកាត់បន្ថយសមត្ថភាពរបស់វា ក្នុងការផ្គត់ផ្គង់ផលិតផល និង/ឬ សេវា" (FAO n.d., 2)។ តារាង ២ បានបង្ហាញថា ក្នុងកិច្ចខិតខំប្រឹងប្រែងដោះស្រាយការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ ត្រូវមានការយល់ដឹងអំពីមូលហេតុដែលជាឫសគល់ ក៏ដូចជា មូលហេតុលេចធ្លោ ឬទំនងៗជាងគេ ដូចមានចុះសង្ខេបក្នុងតារាង ២។

តារាង ២៖ កត្តាជំរុញការបាត់បង់ និងការរេចរឹលព្រៃឈើ

| មូលហេតុលេចធ្លោ | មូលហេតុជាឫសគល់ |
|---|---|
| ការកាប់ឈើខុសច្បាប់ និងគ្មានចីរភាព | កំណើនប្រជាជន |
| ការប្រមូលយកអុសច្រើនហួសហេតុ | ចំណាកស្រុកចូលក្នុងតំបន់ព្រៃ |
| ការរានព្រៃដើម្បីធ្វើកសិកម្ម | ទំនៀមទម្លាប់សង្គម (ការចាប់យកដីតាមការប្រើប្រាស់) |
| ការពង្រីកលំនៅដ្ឋាន | កំណើនលទ្ធភាពចូលទៅក្នុងតំបន់ព្រៃឈើ |
| | តម្រូវការធនធានក្នុងតំបន់ |
| | សិទ្ធិកាន់កាប់ដីព្រៃនៅទន់ខ្សោយ |
| | កង្វះយន្តការដោះស្រាយទំនាស់ដោយយុត្តិធម៌ និងមានតម្លាភាព |
| | កង្វះផែនការលើការប្រើប្រាស់ដី |
| | ផលប្រយោជន៍សេដ្ឋកិច្ចទទួលបានតិចពីព្រៃឈើនៅកម្រិតជាតិ បើធៀបនឹងជម្រើសផ្សេងទៀត |
| | ការយល់ដឹងតិចតួចអំពីមុខងារព្រៃឈើជួយដល់បរិស្ថាន |

ប្រភព៖ Ngoun 2014

រដ្ឋបាលព្រៃឈើ បានលើកពីឧបសគ្គជាច្រើនដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព មានជាអាទិ៍៖ ១) កង្វះបុគ្គលិកមានសមត្ថភាព និងការតាំងចិត្តខ្ពស់ដើម្បីបម្រើការនៅតាមខេត្តដាច់ស្រយាល ២) កង្វះថវិកា និងមធ្យោបាយ សម្រាប់អនុវត្តសកម្មភាពបានគ្រោងទុក ៣) ចំណេះដឹងនិងការប្តេជ្ញាចិត្តមានកម្រិតរបស់បុគ្គលិក ៤) សមត្ថភាពទន់ខ្សោយសម្រាប់ត្រួតពិនិត្យលើ ការកាប់យកឈើដោយខុសច្បាប់ និង ៥) កង្វះសហប្រតិបត្តិការពីសំណាក់អាជ្ញាធរ និងស្ថាប័នមូលដ្ឋាន (ACI 2014)។

ពិនិត្យតាមឧបសគ្គ និងល្បឿននៃការបាត់បង់ និងរេចរឹលព្រៃឈើ ប្រទេសកម្ពុជាប្រហែលមិនអាចអនុវត្តតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍បានទេ ក្នុងការរក្សាទុកគម្របព្រៃឲ្យបានយ៉ាងហោចណាស់ ៦០% នៃផ្ទៃដីសរុបក្នុងឆ្នាំ២០១៥ (FA 2011)។ ដើម្បីសម្រេចគោលដៅនេះ ត្រូវមានការដាំដើមឈើឡើងវិញលើដី ០.៥លានហិកតា និងកំណត់វាជាតំបន់ការពារ ហើយសិទ្ធិកាន់កាប់ដីរបស់សហគមន៍ព្រៃឈើ ក៏ត្រូវពង្រឹងឡើងដែរ (FA 2011; CDRI 2013)។

ការបន្ថយល្បឿនការបាត់បង់ព្រៃឈើ ដោយមិនបដិសេធសិទ្ធិរបស់ប្រជាជននៅជនបទ ជាពិសេស ជនក្រីក្រ និងជិតក្រីក្រ ក្នុងការប្រើប្រាស់ធនធាននេះ គឺជាបញ្ហាប្រឈមចម្បងមួយសម្រាប់រដ្ឋាភិបាល និងសង្គមទាំងមូល។ ដូច្នេះ រដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន គួរខិតខំលើកកម្ពស់ការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយចីរភាព។

## ករណីសិក្សាលើគម្រោងសហគមន៍ព្រៃឈើអូរសោម

គម្រោងសហគមន៍ព្រៃឈើអូរសោម ក្នុងខេត្តកំពង់ធំ ត្រូវបានជ្រើសរើសយកមកធ្វើករណីសិក្សា ព្រោះជាឧទាហរណ៍ដ៏ប្រសើរមួយនៃការអនុវត្តបានល្អ ក្នុងការងារសហគមន៍ព្រៃឈើ។ គម្រោងនេះទទួលបានថវិកាពីគម្រោងឈ្មោះថា "ពហុមុខងារ, ការស្តារព្រៃឈើ និងការគ្រប់គ្រងតំបន់ព្រៃរេចរឹល" ដែលបង្កើតឡើង និងអនុវត្តដោយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ និងសត្វព្រៃ នៃរដ្ឋបាលព្រៃឈើ ដោយមានជំនួយទ្រទ្រង់ពីបណ្តាញអាស៊ីប៉ាស៊ីហ្វិក ដើម្បីការស្តារ និងគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព (APFNet) រហូតដល់ចុងឆ្នាំ២០១៤។

ទិន្នន័យបឋមសម្រាប់ការសិក្សា បានប្រមូលយកពីបទសម្ភាសន៍ក្រៅផ្លូវការ ជាមួយសមាជិកសហគមន៍អូរសោម ក្នុងខែសីហា ២០១៤ និងទិន្នន័យបន្ទាប់បន្សំទទួលបានពីការសិក្សាឯកសារបោះពុម្ពផ្សាយ ឯកសារនយោបាយ និងរបាយការណ៍ស្រាវជ្រាវផ្សេងៗ។ ការសិក្សានេះអនុវត្តវិធីសាស្ត្របែបគុណភាព និងបែបបរិមាណរួមគ្នា ដោយប្រើកម្មវិធី Excel សម្រាប់គណនារកចំណូលពីព្រៃឈើ និងប្រើក្របខ័ណ្ឌ SWOT សម្រាប់វាយតម្លៃពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និង គារគំរាមកំហែង ដើម្បីផ្តល់ជាយោបល់ពីយុទ្ធសាស្ត្រទៅមុខទៀត។

ក្រុមសហគមន៍ព្រៃឈើអូរសោម ស្ថិតក្នុងភូមិសាលាវិស័យ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ (រូបភាព ៤) ប្រមាណ ៣៧ គ.ម ពីទីរួមខេត្តកំពង់ធំ និង ១៦៨គ.ម ពីក្រុងភ្នំពេញ (Ma 2014)។ គម្រោងសហគមន៍ព្រៃឈើនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៤ លើផ្ទៃដី ៣០៨ហិកតា ក្នុងគោលបំណងចម្បងជំរុញប្រជាជនក្នុងមូលដ្ឋានឲ្យអភិរក្សព្រៃឈើ ការពារព្រៃឈើ និងប្រើប្រាស់ធនធានព្រៃឈើប្រកបដោយចីរភាព។

នៅឆ្នាំ២០០៨ មាន ៣៥៤គ្រួសារ ត្រូវជា ១៨១៨នាក់ (ស្រី ៩១៨នាក់) រស់នៅក្នុងភូមិសាលាវិស័យ (NIS 2010) ក្នុងនេះមាន ២៧៣គ្រួសារ ជាសមាជិកសហគមន៍ព្រៃឈើ ដែលភាគច្រើនជាជនជាតិភាគតិចកួយ។ ក្រៅពីការដាំស្រូវ និងដំណាំផ្សេងៗ ពួកគេប្រមូល NTFP ដូចជា ផ្តៅ ឫស្សី ទឹកឃ្មុំ

រូបភាព ៤៖ តំបន់ព្រៃសហគមន៍អូរសោម




ប្រភព៖ FA 2014

ផ្លែឈើ ផ្សិត និងរុក្ខជាតិឱសថ។ អ្នកខ្លះមានតូបលក់ដូរតូចៗ និងអ្នកផ្សេងទៀតជាពលករ (Ma 2014)។ ជាគោលការណ៍ មានតែសមាជិកសហគមន៍ព្រៃឈើប៉ុណ្ណោះ ដែលអាចប្រមូលយកធនធានពីព្រៃឈើសហគមន៍។

## ការរួមចំណែករបស់សហគមន៍ព្រៃឈើ ក្នុងការអភិរក្សព្រៃឈើ និងបង្កើនចំណូលគ្រួសារ

*ឥទ្ធិពលនៃការស្ដារព្រៃឈើ និងសកម្មភាពអភិរក្ស*

ស្របតាមគម្រោងគ្រប់គ្រងព្រៃឈើរបស់ខ្លួននោះ ក្នុងឆ្នាំ២០១៤ សហគមន៍ព្រៃឈើអូរសោមបានដាំដើមឈើលើផ្ទៃដីរក្សាទុកជាតំបន់ការពារចំនួន ១៥ហិកតា ដែលមានឫស្សី និងដើមឈើប្រាំប្រភេទសរុបទាំងអស់ ៩៨១០ដើម គឺមាន គគីរ (Hopea odorata), ធ្នង់ (Pterocarpus macrocarpus Kurz), កកោះ (Sindora cochinchinensis H. Baill), ផ្ដៅ (Calamus sp.) និង ព្រីង។ ពួកគេក៏បានដាំដើមឈើ ៧៨១០ដើម នៅតំបន់ស្ដារព្រៃឈើឡើងវិញ ក្នុងនោះមាន ដើមអាកាស្យា ២០០០ដើម (Acacia auriculiformis Muell)។ រដ្ឋបាលព្រៃឈើ បានជួយបណ្ដុះបណ្ដាលសមាជិកគណៈកម្មការសហគមន៍ អំពីវិធីជួយឲ្យព្រៃឈើលូតលាស់ឡើងវិញ ដូចជា របៀបរបបថែទាំ កាប់ឈើឲ្យស្រឡះ និងប្រមូលផល។ ប៉ុន្តែត្រូវមានការបណ្ដុះបណ្ដាលបច្ចេកទេសច្រើនថែមទៀត ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សមាជិក អំពីរបៀបអនុវត្តល្អបំផុត និងជួយឲ្យពួកគេមានជំនាញសម្រាប់អនុវត្តបច្ចេកទេសទាំងនោះ។

ការកាប់ឈើ និងការប្រមាញ់ខុសច្បាប់ បានថយចុះជាខ្លាំង ចាប់តាំងពីសមាជិកសហគមន៍ចាប់ផ្ដើមដើរល្បាតក្នុងព្រៃ ដើម្បីទប់ទល់នឹងសកម្មភាពខុសច្បាប់ផ្សេងៗ។ រូបសញ្ញារបស់សហគមន៍ព្រៃឈើ និងរដ្ឋបាលព្រៃឈើ ដែលមានដាក់ពាសពេញក្នុងព្រៃ បញ្ជាក់ច្បាស់ថា សហគមន៍អូរសោម មានកម្មសិទ្ធិស្របច្បាប់លើព្រៃឈើ និងធនធាននៅក្នុងនោះ។

អ្នកគាំទ្រគម្រោងនេះជឿថា ព្រៃឈើក្នុងតំបន់ការពារ និងព្រៃសហគមន៍ នឹងក្លាយជាព្រៃឈើចុងក្រោយដែលរងការខូចខាតតែតិចតួចនៅកម្ពុជា គឺដូចជាកោះនៅកណ្ដាលសមុទ្រមួយ។ សមាជិកសហគមន៍គិតថា នៅពេលណាមួយនឹងមានអ្នកក្រៅឈ្លានពានចូលព្រៃរបស់គាត់ ហើយដាក់សំពាធបន្ថែមមកលើព្រៃឈើ និងបង្កើនតម្រូវការការពារព្រៃទាំងនោះ។

## អត្ថប្រយោជន៍បានពីការចូលរួមក្នុងសហគមន៍ព្រៃឈើ

អត្ថប្រយោជន៍ផ្ទាល់និងជាក់ស្ដែង សម្រាប់គ្រួសារដែលចូលរួមក្នុងគម្រោងសហគមន៍ព្រៃឈើអូរសោម គឺ លទ្ធភាពចេញចូល និងប្រើប្រាស់ព្រៃ ដើម្បីប្រមូល NTFP ផ្សេងៗ ដូចជា អុស ផ្សិត ផ្លែឈើ ផ្ដៅ ទឹកឃ្មុំ សត្វល្អិតអាចហូបបាន (ដូចជា អាពីង) និងត្រី និងការមានចំណែកក្នុងប្រាក់ចំណេញបានពីការលក់កូនឈើ និងពីភ្ញៀវចូលមកទស្សនាសហគមន៍អូរសោម (តារាង ៣)។

ចំណូលជាសាច់ប្រាក់បានពី NTFP មានច្រើនគួរសម។ ព្រៃឈើមានសក្ដានុពលធំណាស់ សម្រាប់ផលិតកម្មទឹកឃ្មុំធម្មជាតិ។ សហគមន៍ប្រមូល និងផ្គត់ផ្គង់ទឹកឃ្មុំសុទ្ធបានពី ៥០០ ទៅ ៧០០លីត្រក្នុងមួយឆ្នាំ ហើយលក់បានថ្លៃ ៥ដុល្លារ/លីត្រ ឬបានចំណូលសរុប ៣៥០០ដុល្លារ/ឆ្នាំ។ ថ្លៃទឹកឃ្មុំនេះ ពួកឈ្មួញកណ្ដាលបានកំណត់វាទាបជាងថ្លៃទីផ្សារ។ ទោះបីសមាជិកសហគមន៍ បានដឹងពីបញ្ហា និងឱកាសល្អក្ដី ក៏ពួកគេខ្វះខាតជំនួយគាំទ្រផ្នែកថវិកា និងបច្ចេកទេស ដើម្បីអភិវឌ្ឍមុខរបរផ្គត់ផ្គង់ទឹកឃ្មុំ។

តារាង៣៖ ការប្រមូលធនធាននៅព្រៃសហគមន៍អូរសោម ឆ្នាំ២០១៤

| ប្រភេទធនធាន | រដូវប្រមូលផល | គ្រួសារទទួលផល | |
|---|---|---|---|
| | | ចំនួន | ជា % នៃចំនួនសរុប |
| ចំណូលបានពី NTFP | | | |
| ត្រី | ពីខែឧសភា ដល់ មិថុនា និងពីខែកញ្ញា ដល់ តុលា | 273 | 100 |
| អុស | ប្រចាំថ្ងៃ | 273 | 100 |
| រុក្ខជាតិចំណីសត្វចិញ្ចឹម | ចុងខែធ្នូ ដល់ខែមេសា | 190 | 70 |
| ផ្សិតព្រៃ | ខែមីនា ឧសភា និង កញ្ញាក្រោយពេលមានភ្លៀងធំៗ | 191 | 70 |
| ផ្លែឈើព្រៃហូបបាន (គុយ) | ខែមីនា និង មេសា | 82 | 30 |
| ផ្ដៅ (សម្រាប់ធ្វើគ្រឿងសង្ហារឹម និងត្បាញកន្ត្រក) | ខែមករា កុម្ភៈ និង កញ្ញា | 38 | 14 |
| ទឹកឃ្មុំ | ពីខែមេសា ដល់ កញ្ញា | 44 | 16 |
| អាពីង | ពីខែសីហា ដល់ កញ្ញា | 10 | 3.7 |
| ចំណូលបានមកពីកន្លែងបណ្ដុះកូនឈើ និងមូលនិធិសហគមន៍ | | | |
| ការលក់កូនឈើ |ម្ដងម្កាលក្នុងពេញមួយឆ្នាំ | ប្រើសម្រាប់រក្សានិងដំណើរការព្រៃសហគមន៍ | |
| មូលនិធិសហគមន៍ | ប្រាក់តិចតួចបានពីភ្ញៀវមកទស្សនា ក្នុងពេញមួយឆ្នាំ | ប្រើសម្រាប់រក្សានិងដំណើរការព្រៃសហគមន៍ | |

ប្រភព៖ សម្ភាសន៍ជាមួយសមាជិកក្រុមសហគមន៍ព្រៃឈើអូរសោម នៅខែសីហា ២០១៤

អត្ថប្រយោជន៍មួយទៀតគឺ អាហារព្រៃដែលមានជីវជាតិខ្ពស់ និងជាប្រភពអាហារ និងចំណីសត្វពេញៗមួយឆ្នាំ។ ត្រីជាប្រភពអាហារធម្មជាតិចម្បងមួយទៀត អាចរកចាប់បាននៅក្នុងអូរសោម ដែលហូរកាត់ព្រៃធ្លាក់ចូលទៅក្នុងស្ទឹងព្រៃប្រស់ និងរួចចូលទៅបឹងទន្លេសាប។ ក្នុងអូរមានត្រីធំៗ ដូចជា ត្រីឆ្តោរ (Channa micropeltes) ដែលអាចមានប្រវែងដល់ ១,៣ម និងមានទម្ងន់ ២០គ.ក។

សមាជិកសហគមន៍ស្ទើរគ្រប់គ្នា តែងនេសាទត្រីម្តងម្កាលក្នុងរដូវនេសាទ ចាប់ពីខែឧសភា ដល់ មិថុនា និងពីខែកញ្ញា ដល់ តុលា។ ក្រៅពីការហូបចុកក្នុងផ្ទះ គ្រួសារនានាអាចរកចំណូលពីការលក់ត្រីបានប្រមាណ ៤០០.០០០រៀល (១០០ដុល្លារ) ក្នុងមួយរដូវ។ ការលំបាកធំបំផុតក្នុងការគ្រប់គ្រងការនេសាទសម្រាប់ចិញ្ចឹមពោះ គឺការពិនិត្យតាមដាន ព្រោះទិន្នផលតែងប្រែប្រួលចុះឡើង នាំឲ្យមានក្តីបារម្ភពីការនេសាទហួសកម្រិត។ បើសិនមិនអាចប៉ាន់ស្មានពីចំនួនត្រីដែលមាននោះទេ គេពិតជាមិនអាចកំណត់បានឡើយ នូវចំនួនត្រីដែលអាចចាប់យកបាន ហើយអាចរក្សាស្តុកត្រីឲ្យមានចីរភាពថែមទៀត។ ការមិនមានទិន្នន័យវិទ្យាសាស្ត្រ ឬកំណត់ត្រាពីការចាប់ត្រី ដើម្បីវាយតម្លៃស្តុកត្រីទៅតាមប្រភេទត្រី វាគូសបញ្ជាក់ពីតម្រូវការនូវការវាយតម្លៃតាមរបៀបវិទ្យាសាស្ត្រ ដើម្បីធានាចីរភាពត្រីនៅពេលអនាគត។ សរុបមក បើសិនព្រៃឈើត្រូវបាត់បង់ ស្តុកត្រីក៏ត្រូវបាត់បង់ដែរ។

ផលិតផលព្រៃឈើអាចបរិភោគបាន ដូចជា ផ្សិត ផ្លែឈើ និងសត្វល្អិត ក៏ជាប្រភពអាហារ និងប្រាក់ចំណូលដ៏សំខាន់ដែរ។ ផ្សិតព្រៃ តាមធម្មតាវាដុះក្នុងខែ មីនា ឧសភា និង កញ្ញា ក្រោយពេលមានភ្លៀងធំៗ។

ដោយមានជំនួយទ្រទ្រង់ពីមូលនិធិគម្រោង កន្លែងបណ្តុះកូនឈើ ផ្តល់នូវកូនឈើពូជក្នុងស្រុកដែលគេបណ្តុះវាពីគ្រាប់ឈើប្រមូលបានក្នុងមូលដ្ឋាន ហើយមានលក់កូនឈើខ្លះទៅឲ្យអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋបាលព្រៃឈើ។ កន្លែងបណ្តុះនេះលក់កូនឈើបានប្រមាណ ៨០០០ដើម ក្នុងឆ្នាំ២០១១ ៥០០០ដើម ក្នុងឆ្នាំ២០១២ និង ២០០០ដើមក្នុងឆ្នាំ២០១៤។ កូនឈើភាគច្រើនជាដើម ក្រញូង (Dalbergia conchinensis Pierre) និង បេង (Afzelia xylocarpa Kurz. Craib)។

## លទ្ធផលនៃការវិភាគ SWOT

តារាង ៤ មានចុះសង្ខេបពី ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និង ការគំរាមកំហែង ដែលក្រុមសហគមន៍ព្រៃឈើអូរសោមកំពុងតែមានសព្វថ្ងៃ (តារាង ៤)។

តារាង៤៖ ការវិភាគ SWOT

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| ព្រំប្រទល់ព្រៃសហគមន៍មានសញ្ញា/បង្គោលកំណត់ច្បាស់<br>សហគមន៍មានបទបញ្ជាផ្ទៃក្នុង សមត្ថភាពធ្វើច្បាប់គ្រប់គ្រង និងលក្ខណៈស្របច្បាប់ជាផ្លូវការ<br>ការបណ្តុះបណ្តាលនាំឲ្យមានការផ្ទេរចំណេះដឹងក្នុងសហគមន៍អំពីរបៀបរបបល្អក្នុងការដាំ/ថែទាំព្រៃ ការថែទាំ/បណ្តុះគ្រាប់ ការលាយដី ការកាប់មែកឈើឲ្យស្រឡះ<br>ការដាក់បញ្ចូលចំណេះដឹងក្នុងមូលដ្ឋានអំពី បរិស្ថាន និងការស្រាវជ្រាវបែបវិទ្យាសាស្ត្រៈ ការតាមដាន និងកត់ត្រាសន្ទុះលូតលាស់ព្រៃក្នុងដីឡូត៍ទុកសម្រាប់សង្កេត<br>ការដើរល្បាតក្នុងព្រៃជាប្រចាំបានបំបាត់ជិតអស់នូវ សកម្មភាពកាប់ឈើ និងប្រមាញ់ ខុសច្បាប់<br>កន្លែងបណ្តុះបានផ្តល់កូនឈើប្រភេទក្នុងស្រុក និងលក់កូនឈើទៅឲ្យ NGOs និងរដ្ឋបាលព្រៃឈើ<br>ការរក្សាទុកដីព្រៃច្រើនកន្លែងសម្រាប់ការអភិរក្ស និងការស្តារព្រៃឡើងវិញ<br>ទំនាក់ទំនងសហប្រតិបត្តិការ និងការសម្របសម្រួលរវាងរដ្ឋបាលព្រៃឈើនឹងសហគមន៍មូលដ្ឋាន បានជួយរក្សាឲ្យសហគមន៍មានសុវត្ថិភាព<br>សមាជិកសហគមន៍គ្រប់គ្រងឲ្យការប្រើប្រាស់ NTFP ស្ថិតក្នុងកម្រិតព្រៃអាចដុះលូតលាស់ឡើងវិញតាមធម្មជាតិ និងគោរពតាមបទបញ្ជាហាមឃាត់ការប្រមូលអុសក្នុងតំបន់អភិរក្ស | កង្វះសេចក្តីប្រកាស/ការយល់ព្រមជាផ្លូវការពី MAFF<br>កង្វះហិរញ្ញវត្ថុបន្ទាប់ពីគម្រោងចប់អស់<br>ចំណេះដឹងនិងសមត្ថភាពជំនាញមានកម្រិតលើការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ជាពិសេស ទាក់ទងនឹងការបង្កាត់ពូជឈើ និងការស្តារប្រព័ន្ធអេកូឡូស៊ីនៃព្រៃ<br>ថ្នាក់ដឹកនាំក្រុមមិនសូវសកម្ម<br>ស្ថាប័នទន់ខ្សោយប៉ះពាល់ដល់គុណភាពអភិបាលកិច្ច<br>សមាជិកមិនបានចូលរួមពេញលេញទាំងអស់គ្នាទេ ក្នុងសកម្មភាពរបស់សហគមន៍<br>ឈ្មួញកណ្តាល កំណត់តម្លៃ NTFP ឲ្យទាបជាងថ្លៃនៅទីផ្សារ<br>គ្មានខ្សែចង្វាក់ទីផ្សារសម្រាប់ផលិតផលព្រៃឈើវិសេសៗ |
| **ឱកាស** | **ការគំរាមកំហែង** |
| អាហារព្រៃ ជាពិសេស ទឹកឃ្មុំ ត្រី ផ្លែឈើព្រៃ និងផ្សិត មានសក្តានុពលខ្លាំងក្នុងទីផ្សារដោយឡែកខ្លះ ដូច្នេះសំខាន់សម្រាប់ការបង្កើនប្រភពចំណូល<br>ចំណូលបានពីកន្លែងបណ្តុះកូនឈើ អេកូទេសចរណ៍ និងទស្សនកិច្ចសិក្សា បានជួយរក្សាការពារព្រៃសហគមន៍ | អសន្តិសុខកម្មសិទ្ធិ និងសិទ្ធិប្រើប្រាស់ដី<br>ការកាន់កាប់ និងកម្មសិទ្ធិដីគ្មានសុវត្ថិភាព<br>ការខ្លាចមានអ្នកក្រៅចូលមកទន្ទ្រានយកដីព្រៃសហគមន៍ |

ជម្រើស និងបញ្ហារកឃើញតាមការវិភាគ SWOT អាចយកទៅប្រើដើម្បីកំណត់យុទ្ធសាស្ត្រទៅមុខទៀត សម្រាប់ក្រុមអ្នកប្រើប្រាស់ព្រៃឈើអូរសោម ហើយសកម្មភាពដូចខាងក្រោមគួរលើកមកពិចារណាៈ

- ធានាសុវត្ថិភាពការកាន់កាប់ និងកម្មសិទ្ធិដី
    - ត្រូវទទួលបានការយល់ព្រមជាផ្លូវការពី MAFF
    - ញ៉ាំងឲ្យមានសហប្រតិបត្តិការដោយពេញចិត្ត ឆ្លងតាមការប្រស្រ័យទាក់ទងល្អ និងការកសាងទំនាក់ទំនងការងាររឹងប៉ឹងជាមួយអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលព្រៃឈើ ដើម្បីរក្សាឲ្យសហគមន៍មានសុវត្ថិភាព
- ធានាការទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ
    - កសាងសមត្ថភាព សម្រាប់អាជីវកម្មរបស់សហគមន៍លើ NTFP (ឧ. ទឹកឃ្មុំព្រៃ) ដែលរួមមាន ការប្រមូលផលប្រកបដោយចីរភាព ការកែច្នៃ ការផ្សព្វផ្សាយផលិតផល ការអភិវឌ្ឍផលិតផល និងការបង្កើតតម្លៃបន្ថែម។ ចំណូលបានពីការលក់ទឹកឃ្មុំ និងផលិតផលព្រៃផ្សេងទៀត អាចជួយទ្រទ្រង់ដល់សកម្មភាពសហគមន៍។
    - រដ្ឋបាលព្រៃឈើ និងអ្នកពាក់ព័ន្ធផ្សេងទៀត គួរជួយសហគមន៍ឲ្យបង្កើតគេហទំព័រ សម្រាប់ផ្សព្វផ្សាយលក់ផលិតផលខ្លួន បំផុសចំណាប់អារម្មណ៍របស់សាធារណជន និង ផ្សព្វផ្សាយព័ត៌មានពីសហគមន៍ព្រៃឈើតាមរយៈបណ្ដាញសង្គម
    - កសាងសមត្ថភាពអ្នកដឹកនាំក្រុម និងសមាជិកគណៈកម្មការ ដើម្បីបំពេញកង្វះសមត្ថភាព ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ អភិបាលកិច្ច និងការរៀអង្គាសថវិកា
    - បង្កើតក្រុមសន្សំក្នុងសហគមន៍ តាមការវិនិយោគទៅវិញនូវ ចំណូលបានពីមជ្ឈមណ្ឌលទទួលភ្ញៀវ កន្លែងបណ្ដុះកូនឈើ និងប្រភពចំណូលផ្សេងទៀត
- ពង្រឹងសមត្ថភាពសហគមន៍ សម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព
    - បណ្ដុះបណ្ដាលសមាជិកសហគមន៍ ពីវិធីធ្វើបញ្ជីសារពើភ័ណ្ឌព្រៃឈើ (ការប្រមូលជាប្រព័ន្ធនូវទិន្នន័យ និងព័ត៌មានព្រៃឈើសម្រាប់ការវាយតម្លៃ) ដើម្បីពួកគាត់អាចបន្តធ្វើការសិក្សាដោយខ្លួនឯង
    - បង្កើនសមត្ថភាពក្នុងមូលដ្ឋាន សម្រាប់ដំណើរការកន្លែងបណ្ដុះកូនឈើ ជាពិសេស ការបង្កាត់ពូជ ការបណ្ដុះឈើ និងឫស្សី ដើម្បីទទួលបានកូនឈើកាន់តែល្អសម្រាប់លក់ និងដាំដុះក្នុងព្រៃសហគមន៍
    - រក្សាឲ្យគណៈកម្មការ សហគមន៍ព្រៃឈើ មានគំនិតភ្លឺស្វាង ផ្ដោតចំគោលដៅ និងប្រកបដោយប្រសិទ្ធភាព តាមរយៈការបោះឆ្នោតជ្រើសតាំងជាទៀងទាត់
    - ផ្ដល់គ្រឿងលើកទឹកចិត្តរបស់រដ្ឋាភិបាល ដើម្បីជំរុញពួកនិស្សិតបញ្ចប់ការសិក្សា និងមន្ត្រីមានជំនាញបច្ចេកទេសឲ្យចូលជួយនិងធ្វើការដោយផ្ទាល់ជាមួយ សហគមន៍ក្នុងការស្ដារ និងអភិរក្សព្រៃឈើ។

## ការពិភាក្សា និងសេចក្ដីសន្និដ្ឋាន

តំបន់សហគមន៍ព្រៃឈើ អាចកកើតឡើងនៅតាមកន្លែងជាក់លាក់ក្នុងបរិស្ថាន និងជួយទ្រទ្រង់ដល់ក្រុមរុក្ខជាតិ និងសត្វព្រៃជាក់លាក់មួយចំនួន ហើយបានជោគជ័យ ឬបរាជ័យកម្រិតណាអាស្រ័យភាគច្រើនលើស្ថានភាពអេកូឡូស៊ី សង្គម និងសេដ្ឋកិច្ច។ នៅមានកត្តាសំខាន់ជាងគេបី ដែលញ៉ាំងឲ្យសមាគមន៍ព្រៃឈើទទួលបានជោគជ័យគឺ ១) សិទ្ធិលើអចលនទ្រព្យមានចែងច្បាស់ ២) របៀបរៀបចំស្ថាប័នមានប្រសិទ្ធភាពខ្ពស់ និង ៣) ផលប្រយោជន៍ និងគ្រឿងលើកទឹកចិត្តដល់សហគមន៍ (Pagdee, Kim and Daugherty 2006)។ បើសិនជាគ្មានកត្តាទាំងអស់នេះទេ វាជាលំបាកខ្លាំងណាស់ ដើម្បីធានាបាននូវការរស់រានគង់វង្សព្រៃធម្មជាតិ និងសុខមាលភាពរបស់សហគមន៍ដែលពឹងផ្អែកលើព្រៃឈើ។

នៅកម្ពុជា ស្ថាប័ន និងអភិបាលកិច្ចទន់ខ្សោយ ជាឫសគល់នៃជម្លោះដីធ្លីដែលកើតមានពាសពេញ។ ដីដែលត្រូវបានបែងចែកសម្រាប់សហគមន៍ព្រៃឈើរួចហើយ ក៏មិនច្បាស់ថាអាចគេចផុតពីការទន្ទ្រានកាន់កាប់ និងការធ្វើអាជីវកម្មជាលក្ខណៈពាណិជ្ជកម្មនោះដែរ។ អប្រសិទ្ធភាពក្នុងការពង្រឹងអនុវត្តន៍ច្បាប់ ធ្វើឲ្យក្រុមសហគមន៍ព្រៃឈើនានាលំបាកបំផុត ក្នុងការប្រើសិទ្ធិជាម្ចាស់ជាពិសេសទល់នឹងពួកអ្នកមានអំណាច ដែលគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន។ បញ្ហានេះ គូសបញ្ជាក់ពីតម្រូវការបន្ទាន់នូវជំនួយទ្រទ្រង់ ដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាពតាមរយៈ ការបង្កើតច្បាប់កំណត់ច្បាស់ពីសិទ្ធិកាន់កាប់អចលនទ្រព្យ និងការកសាងសមត្ថភាពស្ថាប័នក្នុងមូលដ្ឋាន (Clements et al. 2010)។ ម្យ៉ាងទៀត ក្នុងការតាមដាន និងវាយតម្លៃលើសកម្មភាពរបស់សហគមន៍ព្រៃឈើ គេត្រូវស្រាវជ្រាវឲ្យដឹងថាតើមានអ្វីខ្លះដំណើរការបានល្អ និងអ្វីខ្លះមិនដំណើរការ (Sokh and Iida 2001)។

បច្ចុប្បន្ននេះ មានការទទួលស្គាល់កាន់តែច្រើនឡើងហើយពីសារៈសំខាន់ នៃសហគមន៍ព្រៃឈើចំពោះសង្គមសេដ្ឋកិច្ច និងអេកូឡូស៊ី និងមានការបង្កើតក្រុមសហគមន៍ព្រៃឈើកាន់តែច្រើនឡើង។ ប៉ុន្តែដូចមានបង្ហាញក្នុងករណីសិក្សាលើសហគមន៍ព្រៃឈើអូរសោមនេះស្រាប់ នៅមានបញ្ហាធំៗនៃអសុវត្ថិភាពក្នុងការកាន់កាប់ដី ស្ថាប័នតាមមូលដ្ឋាននៅរប៉ាត់រប៉ាយ និងជំនួយគាំទ្រមិនគ្រប់គ្រាន់ផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ ដែលអាចរាំងស្ទះដល់ការសម្រេចគោលដៅរួម នៃការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។

ទោះបីជាមានបញ្ហាចោទដូចខាងលើក្ដី ក៏សហគមន៍ព្រៃឈើនៅប្រទេសកម្ពុជា នៅតែជាវិធីសាស្ត្រមួយ អាចអនុវត្តបានយូរអង្វែង សម្រាប់ការការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើ ដែលស្ថិតនៅខាងក្រៅតំបន់ការពារ។ បើសិនជាអនុវត្តបានល្អ សហគមន៍ព្រៃឈើ អាចដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិរក្សជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ី, ការដោះស្រាយបាននូវសន្តិសុខស្បៀង និងតម្រូវការផ្សេងៗទៀតនៅក្នុងជីវភាពរស់នៅ និងការកែលំអសុខុមាលភាពរបស់សហគមន៍មូលដ្ឋាន។ ផលប្រយោជន៍ផ្នែកវប្បធម៌ សោភណភាព និងវិទ្យាសាស្ត្រ ក៏ជា

ហេតុផលសំខាន់ ដើម្បីបង្កើនជំនួយទ្រទ្រង់ដល់សហគមន៍នានាដែលចង់បាន និងចង់គ្រប់គ្រងដីព្រៃ។

សរុបមក តាមការយកចិត្តទុកខ្លាំងឡើងទៅលើសហគមន៍ព្រៃឈើ គេបានធ្វើវិនិយោគទៅលើមូលធនបរិស្ថានដែលនឹងជួយដោះស្រាយតម្រូវការ ទាំងនៅពេលបច្ចុប្បន្ន និងទៅអនាគត។ ក្នុងនេះ និងសំខាន់បំផុតសម្រាប់លក្ខណៈម្ចាស់ការលើការគ្រប់គ្រងព្រៃឈើ គឺត្រូវជំរុញកិច្ចសហការយ៉ាងជិតស្និទ្ធរវាងអាជ្ញាធរមូលដ្ឋាន នឹងសហគមន៍ព្រៃឈើនានា ជាពិសេសក្នុងការកំណត់ច្បាស់នូវប្រព័ន្ធសិទ្ធិកាន់កាប់ដី ការកសាងស្ថាប័នរឹងមាំ និងមានស្ថិរភាព និងការផ្តល់ជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសជាបន្តបន្ទាប់។

## ឯកសារយោង


ACI, Agrifood Consulting International. 2014. "Diagnostic Study Cambodia Agriculture in Transition." Draft Final Report. Kensington, MA: ACI.

CDRI, Cambodia Development Resource Institute. 2013. *Cambodia Development Dynamics: Past Performance and Emerging Priorities*. Phnom Penh: CDRI.

Clements, T., Ashish John, Karen Nielsen, Dan An, Setha Tan and E.J. Milner-Gulland. 2010. "Payments for Biodiversity Conservation in the Context of Weak Institutions: Comparison of Three Programs from Cambodia." *Ecological Economics* 69(6): 1283-1291.

FA, Forestry Administration. 2011. *Forest Cover Assessment 2010*.

Forestry Administration. 2013. *Community Forestry Statistics in Cambodia 2013*.

Forestry Administration. 2014. *Community Forestry Statistics Report 2014*.

FAO, Food and Agriculture Organization. undated. "Reducing Emissions from Deforestation in Developing Countries." Accessed 20 Oct 2014, www.fao.org/forestry/11262-0c118e3a425bb480af3f7512bc83695ce.pdf.

Food and Agriculture Organization. 2014. *State of the World's Forests: Enhancing the Socioeconomic Benefits from Forests.* Rome: FAO

Hall, P., and K.S. Bawa. 1993. "Methods to Assess the Impact of Extraction of Non-Timber Tropical Forest Products on Plant Population." *Economic Botany* 47:234-237.

Jagger, P., J.F. Lund, A.E. Duchelle, M.M.K. Luckert and W.D. Sunderlin. 2014. "Tenure and Forest Income: Observations from a Global Study on Forests and Poverty." *World Development.* DOI: 10.1016/j.worlddev.2014.03.004.

Kasper, K.H. and Top, N. 2006. *Natural Forest Benefit and Economic Analysis of Natural Forest Conversion in Cambodia*. Working Paper 33. Phnom Penh: CDRI.

Kim S., N. Sasaki and M. Koike. 2008. "Assessment of Non-Timber Forest Products in Phnom Kok Community Forest, Cambodia." *Asia Europe Journal* 6(2): 345-354.

Koy R., and N. Sasaki. 2013. "Assessment of Local Livelihood of Forest-Dependent Communities in Cambodia." *International Journal of Environmental and Rural Development* 4-1:63-68.

Lonn P., M. Nobuya, K. Tsuyoshi and Y. Shigejiro. 2012. "Effectiveness of Community-Based Ecotourism in Forest Conservation and Livelihood Improvement: A Case Study in Chambok Community-Based Ecotourism, Cambodia." Master's thesis, Kyushu University, Japan.

de Lopez, T.T. 2004. "Resource Degradation, Property Rights, Social Capital and Community Forestry in Cambodia." In *Policy Trend Report 2004,* 35-44. Tokyo: Institute for Environmental Strategies.

Ma Vuthy. 2014. "Participation in Forest Restoration of Osoam Community Forestry Members." Leaflet. Phnom Penh: Forestry Administration.

MAFF, Ministry of Agriculture, Forestry, and Fisheries. 2014. *Cambodia Agriculture Review 2014*.

Nguon Pheakkdey. 2014. "Sustainable Forest Governance in the Asia-Pacific Region: Has REDD+ Adequately Addressed Drivers of Deforestation and Forest Degradation?" DRF Policy Brief No. 6. Phnom Penh: CDRI.

NIS, National Institute of Statistics. 2010. *2008 General Population Census of Cambodia: Map Layers and Databases*.

National Institute of Statistics. 2013. *Supplementary Notes, Commenting the Results of the Cambodia Socio-Economic Survey, CSES 2012*.

Pagdee, Adcharaporn, Kim Yeon-Su and P.J. Daugherty. 2006. "What Makes Community Forest Management Successful: A Meta-Study from Community Forests Throughout the World." *Society and Natural Resources* 19:33-52.

RGC, Royal Government of Cambodia. 2013. *Rectangular Strategy for Growth, Employment, Equity and Efficiency Phase III*.

Solution Exchange. 2010. "Cambodia REDD+ Roadmap". Accessed 13 Nov 2014, www.solex-un.net/repository/kh/cc/cr5-res2-en.pdf.

Sokh H. and S. Iida. 200. "Community Forestry Models in Southeast Asia and Cambodia: A Comparative Study." *Journal of the Faculty of Agriculture, Kyushu University* 46(1): 113-121.

Sunderlin, W.D. 2006. "Poverty Alleviation through Community Forestry in Cambodia, Laos, and Vietnam: An Assessment of the Potential." *Forest Policy and Economics* 8:386-396.

Ty Sokun. 2013. "Evaluation of Community Forestry in Cambodia." Presentation at Asia Forest Workshop, Phnom Penh, 3-4 Dec.

Ty S., N. Sasaki, A.H. Ahmad and A.Z. Zainal. 2011. "REDD Development in Cambodia–Potential Carbon Emission Reductions in a REDD Project." *Formath* 10:1-23.

World Bank. 2013. *Poverty Monitoring and Analysis: Where Have All the Poor Gone?* Phnom Penh: World Bank.

# ២០ឆ្នាំធ្វើការពង្រឹងសង្គមស៊ីវិលនៅកម្ពុជា៖ ដល់ពេលត្រូវបូកសរុបឡើងវិញ

## សេចក្ដីផ្ដើម

បន្ទាប់ពីមានកិច្ចប្រឹងប្រែងជាអន្តរជាតិអស់ជាង ២០ឆ្នាំ ដើម្បីពង្រីកការយល់ដឹងអំពី សិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និង វប្បធម៌មក មានសំណួរសំខាន់មួយផុសឡើងថា តើកម្ពុជាសម្រេចបានហើយឬនៅ នូវសង្គមស៊ីវិលមួយដ៏រឹងមាំ និងរួបរួមគ្នា? ការពិចារណាដោយយកចិត្តទុកដាក់លើសំណួរនេះ នាំឲ្យមានការពិភាក្សាប្រកបដោយគំនិតល្អិតល្អន់ ដែលមិនទាន់មានចម្លើយច្បាស់លាស់ទេ។ សង្គមស៊ីវិលនៅកម្រិតជាតិ នៅទន់ខ្សោយនៅឡើយ ប៉ុន្តែសង្គមស៊ីវិលដ៏ស្វាហាប់មួយហាក់កំពុងផុសឡើងពីស្រទាប់មហាជន។

ការពិភាក្សាលើសំណួរនេះ ជាដំបូងបំភ្លឺលើចំណុចខ្វែងមតិដ៏សំខាន់ថា តើអង្គការមិនមែនរដ្ឋាភិបាល (NGO) និងសង្គមស៊ីវិល ធាតុពិតវាដូចគ្នាឬយ៉ាងណា ហើយបន្ទាប់មកកំណត់ពីគោលគំនិតនៃសង្គមស៊ីវិលកម្ពុជា។ តមកទៀតមានការពិនិត្យជាទូទៅលើ NGOs ដោយកំណត់ពី NGOs ដែលបានចូលរួមនានា, អ្នកណាខ្លះគាំទ្រពួកគេ និងហេតុអ្វី។ ចំណុចចុងក្រោយ គឺការពិនិត្យពីការវិវត្តនៃ NGOs ក្នុង២ទសវត្សរ៍កន្លងទៅ ដោយផ្ដោតថា តើ NGOs ជាសង្គមស៊ីវិលមែនឬទេ និង តើ NGOs បានជួយលើកស្ទួយសង្គមស៊ីវិលដល់កម្រិតណា ព្រមទាំងផ្ដោតលើចលនានាពេលថ្មីៗ ក្នុងការពង្រាយ NGOs ទៅដល់ស្ទើរគ្រប់កន្លែងនៅកម្ពុជា នៅក្នុងសង្គមស៊ីវិលកម្រិតមូលដ្ឋាន។

## តើ NGOs និងសង្គមស៊ីវិលធាតុពិត គឺដូចគ្នាឬយ៉ាងណា?

ទោះបីជាពាក្យ សង្គមស៊ីវិល ឃើញមានប្រើយ៉ាងទូលំទូលាយក្ដី ក៏និយមន័យនៅមិនទាន់កំណត់ច្បាស់លាស់ទេ។ អ្នកបកស្រាយនានាបានសន្និដ្ឋានថា អត្ថន័យនៃពាក្យនេះនៅស្រពិចស្រពិល និងពិបាកកំណត់បានក្នុងការពិតជាក់ស្ដែង។ និយមន័យបែបទូលាយ និងមានលើកឡើងជាទូទៅមួយដែលសហគមន៍ផ្ដល់ជំនួយនៅកម្ពុជា និងប្រទេសផ្សេងទៀត គាំទ្រឲ្យប្រើ បានកំណត់សង្គមស៊ីវិលថាជា "មជ្ឈដ្ឋានអន្តរការីមួយនៅចន្លោះរវាងរដ្ឋ នឹងគ្រួសារ ហើយរួមមានអង្គការនានាដែលដាច់ដោយឡែកពីរដ្ឋ មានស្វ័យភាពដាច់ពីរដ្ឋ និងបង្កើតឡើងតាមការស្ម័គ្រចិត្តដោយសមាជិកសង្គម ដើម្បីការពារ ឬពង្រឹងផលប្រយោជន៍ ឬតម្លៃសីលធម៌របស់ខ្លួន" (White 1994, 337-338)។ និយមន័យនេះ សង្កត់ធ្ងន់លើចំណុចសំខាន់ៗមួយចំនួន។ ទី១ សង្គមស៊ីវិល ជាការប្រមូលផ្ដុំគ្នានូវអង្គការផ្សេងៗនៅក្នុងក្របខ័ណ្ឌនៃសមាគមស្ម័គ្រចិត្តស្វយ័ត។ ទី២ ក្របខ័ណ្ឌនេះ ការពារផលប្រយោជន៍ជាសមូហភាពរបស់អង្គការ។ ទី៣ ក្របខ័ណ្ឌនេះ តំណាងឲ្យសកម្មភាពផ្ទាល់ និងដោយស្ម័គ្រចិត្តនានា នៅពេលមានការបញ្ចេញមតិផ្ទាល់ខ្លួនផុសផុលឡើង និងមានមនុស្សកាន់តែច្រើនមករួបរួមគ្នា ដើម្បីសម្រេចវត្ថុបំណងដ៏ជាក់លាក់ផ្សេងៗ ជាពិសេសក្នុងការទាមទារឲ្យរដ្ឋឆ្លើយតបនឹងវត្ថុបំណងរបស់ខ្លួន។ ចំណុចមួយដែលគួរបញ្ជាក់បន្ថែម គឺនិយមន័យនេះ ឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធជាទូទៅ និងលក្ខណៈសំគាល់ជាធម្មតានៃសង្គមស៊ីវិលនៅបស្ចឹមប្រទេស។

តើកម្ពុជាមានទម្រង់ផ្ទាល់ខ្លួនមួយ នៃសង្គមស៊ីវិលឬទេ? សង្គមស៊ីវិល ពិតជាមាននៅកម្ពុជា ប៉ុន្តែវាខុសប្លែកពីទម្រង់នៅបស្ចឹមប្រទេស។ តាំងពីមុនពេលផ្ទុះសង្គ្រាមម្លេះ May Ebihara (1968) បានរកឃើញថា សង្គមស៊ីវិលកម្ពុជាមិនមែនជាអង្គភាពមានអង្គការចាត់តាំង ដែលតភ្ជាប់ខ្លួនទៅនឹងរដ្ឋនោះទេ ប៉ុន្តែវាស្ដែងចេញតាមទម្រង់ផ្សេងៗ នៃការដោះដូរគ្នានៅក្នុងសង្គម ឬភាពផ្ដល់ឲ្យគ្នាទៅវិញទៅមក ដែលរងឥទ្ធិពលពី និងទ្រទ្រង់ដោយបណ្ដាញនៃសាច់ញាតិ និងការរាប់អានគ្នា។ បើពិនិត្យឲ្យល្អិតល្អន់ សង្គមស៊ីវិលកម្ពុជា ប្រមូលផ្ដុំសំខាន់នៅលើវត្ត និងក្រុមរួមសមាគមគ្នាផ្សេងៗ ដែលបំពេញតួនាទីភាគច្រើនខាងសាសនា សង្គម និងការអភិវឌ្ឍ ជាជាងផ្ដោតលើភាពជាតំណាង (ផ្នែកនយោបាយ) ជាសមូហភាព និងការបញ្ចេញមតិរបស់ក្រុមចំណាប់អារម្មណ៍ និងចលនាសង្គមផ្សេងៗ ទៅដល់រដ្ឋ ដើម្បីដោះស្រាយនូវបញ្ហាដែលជាក្ដីបារម្ភ។

ក្នុងកិច្ចប្រឹងប្រែងផ្ដល់សិទ្ធិអំណាច ដល់សង្គមស៊ីវិលកម្ពុជា ពួកអ្នកផ្ដល់ជំនួយនៅបស្ចឹមប្រទេស បានជួយទ្រទ្រង់ដល់ NGOs នៅកម្ពុជាតាំងពីដើមទសវត្សរ៍ ១៩៩០ មកម្លេះ។ នៅពេលនោះ គេរំពឹងថា អាចពង្រឹងសង្គមស៊ីវិលនៅកម្ពុជា ឲ្យវិវត្តឡើងលើសពីទំនាក់ទំនងក្នុងសង្គមជនជាតិដើមបែបបុរាណ ដើម្បីដើរតួនាទីកាន់តែសំខាន់ក្នុងការកែតម្រូវនូវតុល្យភាពអំណាច ដែលអាចជួយលើកកម្ពស់អភិបាលកិច្ចល្អទៀតផង។ តួនាទីដ៏សំខាន់មួយទៀតរបស់ NGOs គឺ ផ្ដល់នូវសេវាសង្គមដ៏ចាំបាច់នានាដែលវិស័យសាធារណៈពុំមានផ្ដល់ឲ្យ ដោយសាររដ្ឋមានសមត្ថភាពនៅខ្សោយ។

ពាក្យ NGO ក៏មានន័យមិនសូវច្បាស់លាស់ ស្រដៀងគ្នានឹងពាក្យសង្គមស៊ីវិលដែរ។ Clarke (1998, 2-3) បានកំណត់និយមន័យ NGOs ថាជា "...អង្គការឯកជន មិនស្វែងរកចំណេញ និងមានជំនាញវិជ្ជាជីវៈ ដែលមានលក្ខណៈសំគាល់ដាច់ដោយឡែកតាមផ្លូវច្បាប់ និងមានគោលដៅផ្ដោតលើសុខុមាលភាពសាធារណៈ"។ NGOs គឺជាអង្គការមានជំនាញវិជ្ជាជីវៈដែលកកើតឡើងជាសំខាន់ដើម្បីធ្វើជា "មធ្យោបាយ" ឬ "ភ្នាក់ងារ"

---

អត្ថបទនេះ រៀបរៀងដោយ អ៊ូ ស៊ីវហួច អ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ដោយផ្អែកលើឯកសារ Ou and Kim (2013)។ សូមយោងអត្ថបទនេះថា Ou Sivhuoch and Kim Sedara. 2014. "20 Years' Strengthening of Cambodian Civil Society: Time for Reflection." *Cambodia Development Review* 18(3):10-13. Phnom Penh: CDRI.

ជួយសម្រេចនូវគោលដៅសាធារណៈនានា និងផ្ដល់សិទ្ធិអំណាចដល់សង្គមស៊ីវិលក្នុងការអភិវឌ្ឍប្រទេស (Clarke 1998)។ តួនាទីរបស់ NGOs ធ្វើជាមធ្យោបាយជួយសម្រេចនូវគោលដៅរបស់អ្នកផ្សេង វាបង្ហាញជាស្រេចថា NGOs មានលក្ខណៈខុសគ្នាពីនិយមន័យទូទៅនៃសង្គមស៊ីវិល ព្រោះសង្គមស៊ីវិលត្រូវបានបង្កើតឡើង ដើម្បីបានជាប្រយោជន៍ដល់សមាជិកខ្លួន។ លក្ខណៈដែល NGOs ខ្វះខាតទំនាក់ទំនងក្នុងស្រទាប់មហាជន ឬមូលដ្ឋានគាំទ្ររបស់ប្រជាជន និងត្រូវមានគណនេយ្យភាពឡើងលើចំពោះម្ចាស់ជំនួយបែបនេះ វាបង្ហាញថែមទៀតថា NGOs មិនមែនជាសង្គមស៊ីវិលឡើយ។

ជំរឿនលើកក្រោយបំផុតក្នុងឆ្នាំ២០១២ បង្ហាញថា អង្គការសង្គមស៊ីវិលកំពុងដំណើរការនៅកម្ពុជា មានសរុប ១៣១៥ ក្នុងនេះមាន ១១៣០ (៨៦%) ទទួលបានជំនួយជាមូលនិធិ (CCC 2013, 7)។ បាតុភូតថ្មីមួយទៀតនៅកម្ពុជា គឺ សង្គមស៊ីវិលកូនកាត់ ដែលសំដៅលើ NGOs ថ្នាក់ក្រោមជាតិ និងអង្គការសហគមន៍ (community-based organizations - CBOs) ដែលមានចំនួនប្រមាណ ២៥.០០០។ អង្គការទាំងនោះ ត្រូវបានចាត់ទុកជាសង្គមស៊ីវិលកូនកាត់ ដោយសារវាបម្រើព្រមគ្នានូវផលប្រយោជន៍របស់ប្រជាជនក្នុងមូលដ្ឋាន, របស់រដ្ឋ និងរបស់បរទេស។ អង្គភាពសង្គមស៊ីវិលទាំងនេះ ជារឿយៗគេបង្កើតឡើង ដើម្បីបម្រើផលប្រយោជន៍របស់ ប្រជាជនមូលដ្ឋាន ហើយតាមធម្មតាតែងទទួលបានជំនួយទ្រទ្រង់ ពី NGOs។

> “ *NGOs ខ្លះមានអំពើពុករលួយ និងខ្លះទៀតខ្វះអភិបាលកិច្ចល្អ និងតម្លាភាព។ NGOs ដែលបង្កើតឡើងក្នុងគោលដៅចម្បងស្វែងរកប្រាក់ចំណេញ ក៏មានច្រើនដែរ៖ 'NGOs មួយចំនួន នៅតែមានបង្កើតឡើង ដើម្បីផ្ដល់ការងារ ជាជាងជួយដល់ជនក្រីក្រ'* ”

## **តើ** NGOs **បានពង្រឹងសង្គមស៊ីវិលដល់កម្រិតណា**?

នៅថ្នាក់ជាតិ ជាពិសេសនៅទសវត្សរ៍១៩៩០ ម្ចាស់ជំនួយតែងផ្ដល់មូលនិធិ ដល់ក្រុម NGOs ជាក់លាក់មួយ ដែលភាគច្រើនជាអង្គការធំៗមានសក្ដានុពលខ្លាំង និងប្រវត្តិការងារល្អ ជាជាងផ្ដល់ជំនួយដល់ក្រុមសង្គមស៊ីវិលជាទូទៅ ដូចជា សហជីពជាដើម ដើម្បីធានាឲ្យមានលទ្ធផលដូចការរំពឹងទុក អាចវាស់វែងបាន និងបញ្ជាក់នូវភាពត្រឹមត្រូវនៃការផ្ដល់ជំនួយគាំទ្រ។ អ្នកសិក្សាស្រាវជ្រាវមួយចំនួនរែកញែកថា ការសម្រេចចិត្តផ្ដល់មូលនិធិរបស់ម្ចាស់ជំនួយ ផ្ដល់ផលប្រយោជន៍មិនបានល្អទេដល់សកម្មភាពរួមគ្នាដើម្បីលើកកម្ពស់ស្ថានភាពសង្គម ហើយ Hughes (2009) បានហៅបាតុភូតនេះថា "យុទ្ធសាស្ត្របំបែកល្អិតៗ" របស់ម្ចាស់ជំនួយ។ Christie (2013, 91) ក៏យល់ស្របដែរថា "...ក្នុងន័យនយោបាយ ការជំរុញសង្គមស៊ីវិលបន្តផ្ដោតលើការបង្កើត NGOs ជាជាងបណ្ដាសមាគមមានទម្រង់ទូលំទូលាយជាងនេះ" ប៉ុន្តែការសិក្សាជាក់ស្ដែង ដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា បានកំណត់គណនេយ្យភាពទៅថ្នាក់លើរបស់ NGOs ថាជាបញ្ហាដ៏សំខាន់មួយ៖ "ការអនុវត្តគណនេយ្យភាព ជាទូទៅមានទិសពីក្រោមទៅលើ... ដោយសារ NGOs ភាគច្រើន ត្រូវពឹងផ្អែកលើម្ចាស់ជំនួយ ហេតុនេះគេអាចរំពឹងបានថា ការសម្រេចចិត្តរបស់អង្គការ ត្រូវរងឥទ្ធិពលយ៉ាងខ្លាំងពីម្ចាស់ជំនួយ/ដៃគូអភិវឌ្ឍន៍នានា។ ក្នុងការកំណត់គោលដៅជាយុទ្ធសាស្ត្រ ... ការគិតគូរពីអាទិភាព ឬបញ្ហាចោទក្នុងសហគមន៍ វាស្ថិតនៅលំដាប់ទី២ គឺនៅក្រោយរបៀបវារៈ និងអាទិភាពរបស់ ម្ចាស់ជំនួយ" (CCC.2010, 31-32)។

កម្មវិធីជំនួយផ្ដោតលើលទ្ធផលរបស់ម្ចាស់ជំនួយ ភាគច្រើនផ្ដល់អាទិភាពលើការបង្ហើយគម្រោង និងមិនសូវបានផ្ដោតទៅលើឥទ្ធិពលរបស់វាទេ (R.F. Catalla and T. Catalla 2001) កុំថាឡើយដល់ជួយពង្រឹងសង្គមស៊ីវិលជាទូទៅ។ ដូច្នេះ NGOs មានទំនាក់ទំនងតិចណាស់ជាមួយថ្នាក់មូលដ្ឋាន ឬស្រទាប់ប្រជាជន ហើយទុកឲ្យប្រជាជនមូលដ្ឋាននៅតែរប៉ាត់រប៉ាយគ្មានការរៀបចំ និងគ្មានសិទ្ធិអំណាច។ សរុបមក NGOs ផ្ដល់ការងារមានប្រាក់កម្រៃខ្ពស់ដល់ អ្នកស្រទាប់លើមានការអប់រំល្អនៅតាមទីក្រុង ដែលចំណាយពេលធ្វើការងារនៅឯរាជធានី និងទីក្រុងធំៗច្រើនជាងខិតខំតភ្ជាប់ទំនាក់ទំនង ជាមួយប្រជាជនមូលដ្ឋាន។ NGOs ខ្លះមានអំពើពុករលួយ និងខ្លះទៀតខ្វះអភិបាលកិច្ចល្អ និងតម្លាភាព។ NGOs ដែលបង្កើតឡើងក្នុងគោលដៅចម្បងស្វែងរកប្រាក់ចំណេញ ក៏មានច្រើនដែរ៖ "NGOs មួយចំនួន នៅតែមានបង្កើតឡើង ដើម្បីផ្ដល់ការងារ ជាជាងជួយដល់ជនក្រីក្រ" (Nowaczyk 2009, 25)។ កង្វះគោលការណ៍ប្រជាធិបតេយ្យ របស់អង្គការនានា បានធ្វើឲ្យចុះខ្សោយដល់ ភាពគួរឲ្យជឿទុកចិត្ត និងប្រសិទ្ធភាពរបស់ពួកគេ ក្នុងការលើកកម្ពស់អង្គការ និងចលនាផ្សេងៗរបស់សង្គមស៊ីវិលជាទូទៅ។

ទោះបី NGOs ដើមឡើយបានប្រមូលផ្ដុំគ្នានៅក្នុងរាជធានី និងទីក្រុងធំៗ ហើយនិន្នាការនេះ នៅតែបន្តទៅមុខ និងបង្កឧបសគ្គជាក់ស្ដែង ដែលរារាំងដល់ប្រតិបត្តិការរបស់ពួកគេ ក៏មានបាតុភូតថ្មីមួយកំពុងផុសឡើងជាបណ្ដើរៗ។ នៅថ្នាក់មូលដ្ឋាន ចាប់ពីពាក់កណ្ដាលទសវត្សរ៍២០០០ មក NGOs បានរីកសាយទៅដល់តំបន់ជនបទ ហើយអង្គការសហគមន៍ (CBO) ដែលជារឿយៗមាន NGOs ជួយទ្រទ្រង់ផង បានកកើតឡើងនៅស្ទើរគ្រប់ភូមិ។ អ្នកបកស្រាយ បានហៅព្រឹត្តិការណ៍នេះថាជាបាតុភូតកូនកាត់ (សូមមើលដូចជា öjendal 2014 ជាដើម)។ បាតុភូត CBO នេះ បានកកើតឡើងដោយមានចោទបញ្ហាដូចជា ការក្ដោបក្ដាប់ដោយជនមានវណ្ណៈខ្ពស់ និងចីរភាពមិនសូវប្រាកដប្រជា ដោយសារមានការពឹងផ្អែកផ្អែកហិរញ្ញវត្ថុទៅលើ NGOs និងម្ចាស់ជំនួយ។ ទោះយ៉ាងនេះក្ដី ចំណុចវិជ្ជមានខ្លះដែលមិនធ្លាប់មានពីមុនមក កំពុងលេចរូបរាងបន្តិចម្ដងៗ៖ កម្ពុជាភាវូបនីយកម្មនៃសង្គមស៊ីវិល (ពោលគឺ អ្នកចាប់អារម្មណ៍បានផ្លាស់ប្ដូរពីជនបរទេស មកជាប្រជាជនក្នុងស្រុកវិញ) និងការផុស

ឡើងនៃស្ថាប័នអន្តរការី។ ការវិវត្តថ្មីៗទាំងនេះ នាំឲ្យមានក្រុមប្រភេទខ្លះកកើតឡើងយ៉ាងច្រើន ជាពិសេស ក្រុមសន្សំ (saving group) រាប់ពាន់ក្រុមៈ គ្រាន់តែអង្គការសេដាក (CEDAC) មួយរាយការណ៍ថា បង្កើតបាន ៣០០០ក្រុមសន្សំ ដែលដំណើរការប្រកបដោយជោគជ័យ។ ក្រុមទាំងនេះ និងក្រុមដទៃទៀតបានផុសឡើងនៅទូទាំងប្រទេស ហើយវាជាបាតុភូតមួយមិនធ្លាប់មានសោះ ជួយញ៉ាំងឲ្យសង្គមស៊ីវិលទំនើបនៅកម្ពុជាលេចចេញជារូបរាង។

ករណីសិក្សាផ្នែកជាតិពន្ធុសាស្ត្រលំអិតមួយ (Hiwasa 2014) បានវែកញែកថា កិច្ចប្រឹងប្រែងរបស់ម្ចាស់ជំនួយក្នុងការបង្កើតក្រុមសន្សំនៅតាមជនបទកម្ពុជា បានហុចលទ្ធផលដោយបង្កើតបាននូវក្រុមជាច្រើនដែលមានដំណើរការ និងជួយផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច និងសង្គមទៅដល់ប្រជាជនមូលដ្ឋាន ជាពិសេសស្ត្រី។ មុនពេលមានក្រុមសន្សំក្រៅផ្លូវការទាំងនេះ ស្ថានភាពស្ត្រីអាចប្រដូចទៅនឹង "កង្កែបនៅក្នុងអណ្តូង"។ សព្វថ្ងៃនេះ សកម្មភាពរួមគ្នារបស់ស្ត្រីតាមរយៈការចូលរួមក្នុងក្រុមសន្សំ បានជួយឲ្យពួកគេមានសមត្ថភាពអាចចូលរួមដោយផ្ទាល់ក្នុងវិស័យសាធារណៈ និងសង្គមស៊ីវិល។ ម៉្យាងទៀតក្រុមសន្សំរបស់ស្ត្រី បានក្លាយជាថ្នាលមួយ សម្រាប់ការកសាងបណ្តាញសង្គម និងបណ្តាញក្រុមដែលបានរីកដុះដាល ទៅដល់ថ្នាក់ស្រុក និងថ្នាក់ជាតិ ព្រមទាំងបានផ្តល់ជាវេទិកាមួយ សម្រាប់ឲ្យក្រុមស្ត្រី លើកបញ្ហាក់ពីក្តីបារម្ភរបស់ខ្លួន (Hiwasa 2014)។ ការសិក្សាមួយផ្សេងទៀត លើវិស័យមីក្រូហិរញ្ញវត្ថុ (Jörgensen 2009) បញ្ជាក់ថា ទោះជាកិច្ចប្រឹងប្រែងរបស់ម្ចាស់ជំនួយទទួលបរាជ័យ ក្នុងការជំរុញក្រុមសន្សំនៅមូលដ្ឋានក្តី ក៏វាបានបង្កើតនូវក្រុមមានជោគជ័យល្អជាច្រើនដែលបានជួយបង្កើនមូលធនសង្គម និងជះឥទ្ធិពលវិជ្ជមានទៅលើដំណើរការផ្តល់សិទ្ធិអំណាច។ ការវាយតម្លៃពីគម្រោងលើកស្ទួយជីវភាពកសិករមួយ ទ្រទ្រង់ដោយអង្គការសេដាក បានបង្ហាញពីការរីករាលដាលយ៉ាងលឿន និងខ្លាំងក្លានៃក្រុមកសិករ, ក្រុមផលិតករ និងក្រុមសន្សំ ក្នុងនេះមាន "ការសិក្សាគេតែងយោងដល់ជាញឹកញាប់មួយ ស្តីពី ជីវភាពនៅទីជនបទកម្ពុជា ដែលមានចំណងជើងថា "នៅពេលគ្រប់គ្រួសារក្លាយជាកោះមួយ"។ សព្វថ្ងៃប្រជាកសិករនៅស្រុកត្រាំកក់កំពុងបង្ហាញថាចំណងជើងនេះ អាចក្លាយជាប្រវត្តិសាស្ត្រពិតបានលឿនប៉ុណ្ណោះ" (Johnsen and Prom 2005, 2)។

ឥទ្ធិពលវិជ្ជមាននៃការខិតខំរបស់សហគមន៍អន្តរជាតិ ក្នុងការកសាងសង្គមស៊ីវិលថ្នាក់មូលដ្ឋាននៅកម្ពុជា ត្រូវបានគេទទួលស្គាល់ ដោយសារ វា"... បានទទួលជោគជ័យក្នុងការលើកកម្ពស់សមត្ថភាពមូលដ្ឋាន និងឆន្ទៈក្នុងការរៀបចំ ... ដោយបានជ្រាបចូលទៅក្នុងសង្គមស៊ីវិលមួយភាគធំ" ហើយវាបានបង្កើតនូវបរិយាកាសល្អមួយសម្រាប់ "មជ្ឈដ្ឋានសមាគមអន្តរការី" (öjendal 2014, 35)។ ទោះបីមានគោលដៅចម្បងខាង ផ្នែកសេដ្ឋកិច្ចក្តី ក៏ CBOs មានអំណាចជាសមូហភាពខាងនយោបាយដែរ (Feuer 2014)។ ការវិភាគនាពេលថ្មីៗអំពី យុទ្ធសាស្ត្រអភិវឌ្ឍន៍សហគមន៍របស់ CEDAC តាមការបង្កើតសមាគមកសិករ បង្ហាញថា នៅកម្រិតមូលដ្ឋាន ផលិតករមួយក្រុមមានសមាជិកត្រឹមតែ ១០គ្រួសារ ក៏អាចគ្រប់គ្រាន់ សម្រាប់កេណ្ឌប្រមូលសកម្មភាពក្នុងមូលដ្ឋាន ដើម្បីឆ្លើយតបនឹងការគំរាមកំហែង មិនថាក្នុងផ្នែកបរិស្ថាន (ឧ. ទឹកជំនន់, ជំងឺឆ្លងរាលដាល) ឬផ្នែកនយោបាយ (ឧ. ការរំលោភយកដីធ្លី, ឈ្មួញកេញប្រវ័ញ្ច ឬក៏អំពើពុករលួយ) នោះទេ (Feuer 2014, 246)។ នៅកម្រិតមូលដ្ឋាន ការផ្តល់សិទ្ធិអំណាចដល់ក្រុមប្រជាជននៅជនបទ ដូចជា សហព័ន្ធសមាគមកសិករកម្ពុជានៃផលិតករកសិកម្ម តាមរយៈការបង្កើនសមត្ថភាពសម្រាប់សកម្មភាពជារួម, បានផ្តល់ជាមធ្យោបាយដ៏សំខាន់សម្រាប់ឆ្លើយតបនឹង រដ្ឋាភិបាលដែលធ្វើការបំពេញអាសនៈ និងការគំរាមកំហែងៈ "នៅពេលដែលសមាគមកសិករ នៅតែរក្សាទំនាក់ទំនង ជាមិត្តភាពជាមួយរដ្ឋាភិបាលនោះ... វត្តមានអង្គការធំៗ នៅជនបទទាំងនេះ គឺជាបញ្ហាប្រឈមដំបូងមួយហើយ ចំពោះការក្តោបក្តាប់ផ្តាច់មុខ លើអំណាចរដ្ឋនៅទីជនបទ" (Feuer 2014, 246)។ ម៉្យាងទៀត ការរីកសាយនៃបណ្តាញ និងក្រុមសន្សំរបស់ ស្ត្រីនៅមូលដ្ឋាន អាចចូលរួមចំណែកក្នុងរយៈពេលវែង ដល់ការរីកធំធាត់នៃចលនាផ្សេងៗ ក្នុងស្រទាប់មហាជនដែល Feuer បានចង្អុលបង្ហាញនេះ។

> *“មុនពេលមានក្រុមសន្សំក្រៅផ្លូវការទាំងនេះ ស្ថានភាពស្ត្រីអាចប្រដូចទៅនឹង 'កង្កែបនៅក្នុងអណ្តូង'។ សព្វថ្ងៃនេះ សកម្មភាពរួមគ្នារបស់ស្ត្រីតាមរយៈ ការចូលរួមក្នុងក្រុមសន្សំ បានជួយឲ្យពួកគេមានសមត្ថភាព អាចចូលរួមដោយផ្ទាល់ ក្នុងវិស័យសាធារណៈ និងសង្គមស៊ីវិល។”*

ករណីប្លែកពីគេមួយគឺ សហគមន៍ខ្មែរដើម្បីអភិវឌ្ឍន៍កសិកម្ម (KCAD) ដែលជាអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្តមួយបានកកើតឡើង ២០ឆ្នាំមកហើយ នៅខេត្តកំពត។[១] KCAD តំណាងឲ្យអង្គការសង្គមស៊ីវិលដ៏ពិតៗ ដែលមិនអាចផុសឡើងដោយគ្មានការទ្រទ្រង់ពីម្ចាស់ជំនួយឡើយ។ ក្នុងដំណាក់កាលដំបូងដ៏គ្រោះថ្នាក់ KCAD ត្រូវពឹងផ្អែកលើជំនួយទ្រទ្រង់ពីខាងក្រៅ ប៉ុន្តែក្រោយមកអាចបង្កើតប្រាក់ចំណូលដោយខ្លួនឯង ទោះបីមិនបានទៀងទាត់ក្តី តាមការរៀបចំវគ្គបណ្តុះបណ្តាលអ្នកប្រើប្រាស់បរិក្ខារកសិកម្ម។ KCAD បំពេញបានតាមនិយមន័យសង្គមស៊ីវិល ដោយសារមានស្វ័យភាពដែលបានអនុញ្ញាតឲ្យ

---

[១] ករណីផ្សេងទៀតប្រហែលកើតមាននៅតំបន់ផ្សេង ប៉ុន្តែវាស្ថិតនៅក្រៅវិសាលភាពនៃការអង្កេតសម្រាប់ការសិក្សា។

អង្គការនេះ អាចវាតដែនអនុវត្តសកម្មភាព និងបំពេញបានតាមគោលដៅរបស់ខ្លួន ក្នុងមជ្ឈដ្ឋានសង្គមស៊ីវិល។ ក្រោយពីបានរឹងមាំហើយ KCAD បានបន្តប្រតិបត្តិការខ្លួនដោយឯករាជ្យពីរដ្ឋាភិបាល។ នាយករបស់ សហគមន៍ខ្មែរដើម្បីអភិវឌ្ឍន៍កសិកម្ម (KCAD) រកចិញ្ចឹមជីវិតខ្លួនឯងតាមមធ្យោបាយផ្សេង ប៉ុន្តែអាចបំពេញគោលបំណងផ្នែកមនុស្សធម៌របស់គាត់បាន តាមការចូលរួមធ្វើការមិនពេញម៉ោងក្នុងសកម្មភាពរបស់អង្គការ។ ករណីប្លែកមួយទៀតគឺ អង្គការមិនមែនរដ្ឋាបាល (NGOs) ដូចជា អង្គការ Hagar និង Friends International បានវិវត្តប្រែក្លាយខ្លួនទៅជាអាជីវកម្មបម្រើសង្គម ដែលអាចឲ្យពួកគេបង្កើតប្រាក់ចំណូលប្រកបដោយចីរភាព និងជាទូទៅប្រកាន់ខ្ជាប់បានតាមរបៀបវារៈរបស់ខ្លួន ក្នុងការជួយដល់ក្រុមទន់ខ្សោយ ដូចជា សិស្ស/និស្សិតក្រីក្រ និងកុមារកំព្រា ជាដើម។ ប៉ុន្តែច្បាស់ហើយ ការផ្លាស់ប្តូរពីអង្គការមិនមែនរដ្ឋាភិបាល ទៅជាអាជីវកម្មបម្រើសង្គម (នេះជាទម្រង់កូនកាត់មួយទៀតនៃសង្គមស៊ីវិល) មិនអាចកើតឡើងបានទេ បើសិនគ្មានជំនួយទ្រទ្រង់ពីដំបូង អំពីម្ចាស់ជំនួយខាងក្រៅ។

## សេចក្តីសន្និដ្ឋាន

កិច្ចប្រឹងប្រែងរបស់ម្ចាស់ជំនួយ ក្នុងការពង្រឹងសង្គមស៊ីវិលនៅកម្ពុជាកន្លងមក បានផ្តល់លទ្ធផលចម្រុះ។ នៅថ្នាក់ជាតិ អង្គការមិនមែនរដ្ឋាភិបាល ជាពិសេសកាលពីដំបូងៗ សើងតែមិនបានជួយពង្រឹង សិទ្ធិអំណាចរបស់សង្គមស៊ីវិលសោះទេ ដោយសារមានបញ្ហាប្រឈមចម្បងពីរ។ ទី១ ម្ចាស់ជំនួយខាងក្រៅដែលទាមទារគណនេយ្យភាពទៅថ្នាក់លើផង និងគណនេយ្យភាពប្រភេទជាក់លាក់ខ្លះទៀតផង បានផ្តល់មូលនិធិប្រមូលផ្តុំទៅលើអង្គការមួយក្រុមតូច ហើយធ្វើឲ្យអង្គការមិនមែនរដ្ឋាភិបាល (NGOs) មិនបានផ្សារភ្ជាប់ល្អទៅនឹងអាទិភាពរបស់អ្នកទទួលផលនៅតាមមូលដ្ឋាន ដែលខ្លួនត្រូវបម្រើ។ ទី២ បញ្ហានៅក្នុងអង្គការមិនមែនរដ្ឋាភិបាលខ្លួនឯង បានធ្វើឲ្យខូចខាតដល់ភាពគួរឲ្យជឿជាក់ និងប្រសិទ្ធភាពរបស់អង្គការ។ បើទោះបីឧបសគ្គទាំងនេះ នឹងមិនងាយរលាយបាត់ ដោយសារ អង្គការមិនមែនរដ្ឋាភិបាល នៅពឹងផ្អែកខ្លាំងលើជំនួយពីខាងក្រៅក្តី ក៏ការងាររបស់ពួកគេកាន់តែរីកដុះដាលទៅដល់ តំបន់ជនបទច្រើនឡើង ហើយជាបណ្តើរៗ បានឈានទៅតភ្ជាប់ជាមួយប្រជាជនមូលដ្ឋាន។ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍២០០០មក អង្គការមិនមែនរដ្ឋាភិបាល កាន់តែច្រើនឡើង បានពង្រីកសកម្មភាពគម្រោងរបស់ខ្លួនទៅដល់ជនបទ ដោយបង្កើតបាននូវក្រុមសង្គមស៊ីវិលកូនកាត់ជាច្រើន ជាពិសេសក្រុមសន្សំ។ និន្នាការគួរឲ្យពេញចិត្តទាំងនេះ ផ្តល់ក្តីសង្ឃឹមថា សង្គមស៊ីវិលនៅថ្នាក់ទាបបំផុត ពិតជាមានសក្តានុពលដើម្បីរីកលូតលាស់ និងមានផលប្រយោជន៍ដាច់ដោយឡែកមួយខាងផ្នែកនយោបាយ។

## ឯកសារយោង


Catalla, R.F., and T. Catalla 2001.*Cambodia: A Situation Analysis*. Bangkok: Action Aid-Asia.

CCC, Cooperation Committee for Cambodia. 2010. *Reflections, Challenges, and Choices: 2010 Review of NGO Sector in Cambodia*. Phnom Penh: CCC.

CCC. 2013. *CSO Contributions to the Development of Cambodia 2012: Opportunities and Challenges*. Phnom Penh:CCC.

Christie, R. 2013. *Peacebuilding and NGOs: State-Civil Society Interactions*. London: Routledge.

Clarke, G. 1998. *The Politics of NGOs in South-East Asia: Participation and Protest in the Philippines*. London: Routledge.

Ebihara, M. 1968. "Svay, a Khmer Village in Cambodia." PhD dissertation, Columbia University.

Feuer, H. 2014. "Competitive Discourses in Civil Society: Pluralism in Cambodia's Agricultural Development Platform." In *Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam*, edited by G. Waibel, J. Ehlert and H.N. Feuer. London: Routledge.

Hiwasa, A. 2014. "Changing Gendered Boundaries in Rural Cambodia." In *Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam*, edited by G. Waibel, J. Ehlert and H.N. Feuer. London: Routledge.

Hughes, C. 2009. *Dependent Communities: Aid and Politics in Cambodia and East Timor*. New York: Cornnell Southeast Asia Program.

Johnsen, S., and T. Prom. 2005. *Evaluation, ILFARM (Improving Livelihoods of Subsistence Farmers) Project, Tram Kok District, Takeo Province, Cambodia*. Phnom Penh: JICA.

Jörgensen, J.N.I. 2009. "Revisiting Social Capital in Development: Can Group-Based Microfinance Reproduce Social Capital? A Case Study in Rural Cambodia." Master's thesis, Lund University.

Nowaczyk, M. 2009. "Between a Rock and a Hard Place: Organizations and Institutionalized Corruption in Cambodia." MSc Thesis, University of Birmingham.

Öjendal, J. 2014. "In Search of a Civil Society: Re-negotiating State-Society Relations in Cambodia." In *Southeast Asia and the Civil Society Gaze: Scoping a Contested Concept in Cambodia and Vietnam*, edited by G. Waibel, J. Ehlert and H.N. Feuer. London: Routledge.

Öjendal, J., and Kim S. 2013. "Reconstruction and Local Democratization in Cambodia? An Empirical Review of the Potential of a Decentralization Reform." In *The Imperative of Good Local Governance: State of the Art of Local Governance and the Challenges for the Next Decade*,edited by J. Öjendal and A. Dellnäs. Tokyo: United Nations University Press.

Ou Sivhuoch and Kim Sedara. 2013. *20 Years' Strengthening of Cambodian Civil Society: Time for Reflection*. Working Paper Series No. 85. Phnom Penh: CDRI.

White, G. 1994. "Civil Society, Democratization and Development (I): Clearing the Analytical Ground."*Democratization* 1(3): 375-390.

# កំណែទម្រង់វិមជ្ឈការ និងការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋាននៅទីជនបទ

## សេចក្តីផ្តើម

មកទល់បច្ចុប្បន្ន កម្មវិធីវិមជ្ឈការតាមបែបប្រជាធិបតេយ្យនៅកម្ពុជា ដំណើរការបានជាងមួយទសវត្សរ៍ហើយ។ ការសម្រេចបានគោលដៅចម្បងៗក្នុងកម្មវិធីវិមជ្ឈការនៅកម្ពុជា កន្លងមកមានលទ្ធផលចម្រុះ (សូមមើលឯកសារ ដូចជា (jendal and Kim 2006; Kim and öjendal 2009; Kim 2012; Heng, Kim and So 2011; Heng and So 2012; Malena and Chhim 2009; EIC 2010; CDRI 2013)។ កំណែទម្រង់វិមជ្ឈការបានរួមចំណែកលើកកម្ពស់គោលការណ៍នយោបាយពហុបក្ស ដែលជាមូលដ្ឋានគ្រឹះនៃរបបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ ឥឡូវនេះ ប្រជាជនអាចជ្រើសរើសថ្នាក់ដឹកនាំក្នុងមូលដ្ឋាន អាចចូលរួម ក៏ដូចជាបង្ហាញពីការចង់បាន និងតម្រូវការរបស់ខ្លួនក្នុងការអភិវឌ្ឍសហគមន៍។ ទោះជាយ៉ាងនេះក្តី ការចូលរួមជាក់ស្តែងរបស់ប្រជាជនក្នុងការអភិវឌ្ឍមូលដ្ឋាននៅមានកម្រិតទាប ដោយសារក្រុមប្រឹក្សាឃុំ មិនមានលទ្ធភាពបំពេញតាមតម្រូវការក្នុងមូលដ្ឋាន, ការខ្វាយខ្វល់រកចិញ្ចឹមជីវិតប្រចាំថ្ងៃ, ទម្លាប់មានការរុញរា, បែបបទកោះអញ្ជើញឲ្យចូលរួម។ល។ ម្យ៉ាងទៀត ការចូលរួមក៏មានលក្ខណៈអសកម្ម និងជារឿយៗ តែងជំរុញឡើងដោយផលប្រយោជន៍ផ្ទាល់ខ្លួន ដែលចង់បានផលចំណេញភ្លាមៗ។

ទោះបីមានការស្រាវជ្រាវជាច្រើន ពិនិត្យពីការជំរុញរបស់វិមជ្ឈការទៅលើការចូលរួមរបស់ប្រជាជន ក្នុងការអភិវឌ្ឍ និងកិច្ចការនយោបាយនៅមូលដ្ឋានក្តី ក៏នៅមិនទាន់មានការវាយតម្លៃជាលក្ខណៈប្រព័ន្ធណាមួយ ដែលផ្តោតលើការចូលរួមរបស់យុវជននោះទេ។[១] ការសិក្សានេះព្យាយាមបំពេញចន្លោះខ្វះខាតក្នុងការសិក្សាកន្លងមក ដោយឆ្លើយតបនឹងសំណួរថា៖ តើយុវជនបានប្រើប្រាស់យ៉ាងណាដែរ នូវឱកាសដែលកំណែទម្រង់វិមជ្ឈការបានផ្តល់ឲ្យ? លទ្ធផលសិក្សាផ្តល់នូវការយល់ដឹងដ៏សំខាន់សម្រាប់ការពិភាក្សាអំពី ដំណើរការដែលវិមជ្ឈការបានក្លាយជាមធ្យោបាយជំរុញ ការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចថ្នាក់មូលដ្ឋាននៅទីជនបទ។

## ការវាយតម្លៃពីការចូលរួមរបស់យុវជន

ការសិក្សានេះ វាយតម្លៃពីការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋាននៅតំបន់ជនបទ ដោយពិនិត្យលើសូចនាករធំៗបីខាងផ្នែកសង្គមនយោបាយ និងការបោះឆ្នោតដែលបង្កើតឡើងដោយមជ្ឈមណ្ឌលសម្រាប់ព័ត៌មាន និងការស្រាវជ្រាវពីការអប់រំ និងការអនុវត្តសិទ្ធិពលរដ្ឋ (CIRCLE 2002)។ សូចនាករនីមួយៗចែកជាសកម្មភាពជាច្រើន។ សូចនាករសង្គម រួមមានការស្ម័គ្រចិត្តជួយ ការងារអង្គការមិនទាក់ទងនឹងការបោះឆ្នោត, សមាជិកភាពសកម្មក្នុងក្រុម ឬអង្គការផ្សេងៗ, ការរៃអង្គាសមូលនិធិសម្រាប់សកម្មភាពសប្បុរសធម៌ និងការដោះស្រាយបញ្ហាសហគមន៍។ សូចនាករនយោបាយមានជាអាទិ ការជួបទាក់ទងជាមួយមន្ត្រីរាជការ, ការបញ្ជូន ឬចុះហត្ថលេខាលើសារឬញត្តិតវ៉ា, ការជួបទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ, ការធ្វើបាតុកម្ម, ការធ្វើពហិកា និងការស្ទង់មតិ។ សូចនាករការបោះឆ្នោតរួមមាន ការបោះឆ្នោតជាទៀងទាត់, ការបញ្ចុះបញ្ចូលអ្នកដទៃ, ការចូលរួមក្នុងគណៈបក្សនយោបាយ និងការជួយឃោសនាឲ្យបេក្ខជន (ការពិភាក្សាលំអិតអំពីសូចនាករទាំងនេះ មានចុះក្នុងការសិក្សារបស់ Heng, Vong and Chheat 2014.)។

ដើម្បីរក្សាឲ្យការសិក្សានេះមិនធំហួសកម្រិត អាចគ្រប់គ្រងបាន ប៉ុន្តែអាចបង្ហាញពីការចូលរួមរបស់យុវជនកម្ពុជា ក្នុងអភិបាលកិច្ចមូលដ្ឋាននៅតំបន់ជនបទ ក្រុមស្រាវជ្រាវបានជ្រើសរើសសកម្មភាពពីរសម្រាប់សូចនាករនីមួយៗគឺ៖ ការស្ម័គ្រចិត្តជួយការងារអង្គការមិនទាក់ទងនឹងការបោះឆ្នោត និងសមាជិកភាពសកម្មក្នុងក្រុមឬអង្គការផ្សេងៗសម្រាប់សូចនាករសង្គម, ការជួបទាក់ទងជាមួយមន្ត្រីរាជការ និងការចុះហត្ថលេខាលើញត្តិតវ៉ាសម្រាប់សូចនាករនយោបាយ, និងការបោះឆ្នោតជាទៀងទាត់ និងការជួយឃោសនាឲ្យបេក្ខជន សម្រាប់សូចនាករការបោះឆ្នោត។

ការសិក្សានេះ មិនបានពិនិត្យពីទម្រង់មិនធម្មតានៃការចូលរួម ដូចជា បាតុកម្មជាដើមទេ ព្រោះវាមិនសូវស្របនឹងបរិបទនយោបាយនៅកម្ពុជា។ អ្នកស្រាវជ្រាវនានា (រួមទាំង Chandler 1996, 2000; Martin 1994; Hughes 2009) បានលើកមតិថា ចលនាវប្បធម៌ និងសង្គម ដែលមានភាពសំខាន់ក្នុងការកៀងគរសកម្មភាពសង្គមនោះ គឺមិនសូវឃើញមានក្នុងសង្គមកម្ពុជាទេ ជាពិសេសក្នុងសម័យខ្មែរក្រហម ដែលបណ្តាសមាគមជាប្រពៃណី និងទម្រង់ផ្សេងៗ នៃសកម្មភាពជាសមូហភាពបានបាក់បែកខ្ទេចខ្ទីអស់។ ក្នុងទសវត្សរ៍១៩៩០ និង២០០០ មានឯកសារបង្ហាញពីភស្តុតាងនៃការឃាត់ឃាំង និងការទប់ស្កាត់ដោយប្រើហិង្សាពីសំណាក់រដ្ឋាភិបាល ទៅលើចលនាដោយសន្តិវិធីផ្សេងៗខាងនយោបាយ និងសង្គម (Hughes 2009)។

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះធ្វើឡើងពីខែកញ្ញា ២០១៣ ដល់កុម្ភៈ ២០១៤ នៅឃុំចំនួន៤ ក្នុងខេត្តបី គឺព្រៃវែង កំពង់ចាម និងបាត់ដំបង។ តំបន់សិក្សា បានជ្រើសយកដោយផ្អែកលើលក្ខណៈវិនិច្ឆ័យធំៗ ដូចជា ភូមិសាស្ត្រ, វត្តមានសមាគមយុវជនក្នុងតំបន់, និងទំនាក់ទំនងមានស្រាប់ជាមួយមន្ត្រីមូលដ្ឋាន។ ការជ្រើសរើសតំបន់

---

អត្ថបទនេះ រៀបរៀងដោយ ហេង សីហា និង វង់ ម៉ាន់ ជាអ្នកស្រាវជ្រាវ កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ នៃវិទ្យាស្ថាន CDRI។ អត្ថបទនេះ ដកស្រង់ចេញពីការសិក្សារបស់ Heng, Vong and Chheat (2014)។ សូមឯកសារនេះថា៖ Heng Seiha and Vong Mun. 2014. “The Enduring Gap: Decentralisation Reform and Youth Participation in Local Rural Governance.” *Cambodia Development Review* 18(3):14-17។

១ ការសិក្សានេះកំណត់និយមន័យរបស់ពាក្យយុវជនថាជាអ្នកមានអាយុចន្លោះពី១៨ទៅ៣០ឆ្នាំ។

សិក្សាមានគោលដៅ គូសបញ្ជាក់ពីការចូលរួមរបស់យុវជននៅមូលដ្ឋាន ជាជាង បង្កើតនូវករណីសិក្សាសម្រាប់ប្រៀបធៀបគ្នា។

វិធីសាស្ត្រស្រាវជ្រាវ រួមមាន ការពិភាក្សាតាមក្រុមស្នូល (FGDs) និងសម្ភាសន៍ពាក់កណ្ដាលរៀបរយ។ ដើម្បីស្រាវជ្រាវពីការយល់ឃើញរបស់យុវជន ដែលមានបទពិសោធន៍សង្គមខុសៗគ្នា ក្នុងឃុំនីមួយៗមានធ្វើ FGDs ពីរលើកគឺ មួយលើកជាមួយអ្នកស្ម័គ្រចិត្តក្នុងអង្គការយុវជន និងមួយលើកទៀតជាមួយយុវជនមិនមានចូលរួមក្នុងបណ្ដាញយុវជន ហើយក្នុងការពិភាក្សានីមួយៗ មានយុវជនពីបួនទៅប្រាំមួយនាក់ស្មើភាពគ្នាខាងយេនឌ័រមកចូលរួម។ សម្ភាសន៍បានធ្វើឡើងជាមួយបុគ្គល ៣៣នាក់ រួមមាន មេឃុំ និងក្រុមប្រឹក្សាឃុំ, មេភូមិ, យុវជននិងតំណាងអង្គការយុវជននៅមូលដ្ឋាន, ក៏ដូចជាថ្នាក់ដឹកនាំអង្គការយុវជនថ្នាក់ជាតិ និងស្ថាប័នរដ្ឋាភិបាលផ្នែកយុវជន។

ការសិក្សាយ៉ាងទូលំទូលាយលើឯកសារមានស្រាប់ ដូចជាសៀវភៅ, អត្ថបទសារព័ត៌មាន, របាយការណ៍ និងការសិក្សានានាបានផ្ដល់ជាទស្សនៈរួមមួយ នៃការយល់ឃើញតាមហេតុការណ៍ជាក់ស្ដែង និងតាមទ្រឹស្ដីអំពីការចូលរួមផ្នែកនយោបាយ និងភាពសកម្មរបស់យុវជន។ អង្កេតមួយចំនួនមានផ្ដល់ទិន្នន័យសំខាន់ៗស្ដីពីការចូលរួមរបស់យុវជននៅកម្ពុជា ហើយការសិក្សានេះសំដៅកសាងបន្ដលើសំណុំទិន្នន័យទាំងនោះ ដើម្បីអាចផ្ដល់ការពណ៌នាកាន់តែលំអិតថែមទៀត។

ការសិក្សានេះ ព្យាយាមគូសបញ្ជាក់ពីបញ្ហាសំខាន់ៗដែលនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការស្រាវជ្រាវបន្ថែម និងជួយរួមចំណែកដល់ការជជែកវែកញែក ពីការរីកចម្រើនរបស់យុវជននៅកម្ពុជា។ ប៉ុន្តែវិធីសាស្ត្រប្រមូលទិន្នន័យ និងអ្នកផ្ដល់ព័ត៌មានគន្លឹះមានតិចនាក់ បានធ្វើឲ្យការសិក្សានេះមានកំហិតចម្បងមួយគឺ កង្វះលទ្ធភាពក្នុងការបំបែកលំអិតទិន្នន័យ (ឧ. ទៅតាមយេនឌ័រ, ស្ថានភាពសេដ្ឋកិច្ច, ការអប់រំ, ទំនាក់ទំនងនយោបាយនិងទីតាំងភូមិសាស្ត្រ)។

## លទ្ធផលសិក្សា

លទ្ធផលសិក្សាបង្ហាញថា ការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋាននៅទីជនបទជាទូទៅ និងជាពិសេសក្នុងការធ្វើផែនការអភិវឌ្ឍន៍គឺនៅមានកម្រិតនៅឡើយ។ សកម្មភាពដែលយុវជនចូលរួម តែងជំរុញឡើងដោយអន្តរការីផ្សេងៗ ដូចជាសមាគមយុវជន សមាជិកក្រុមប្រឹក្សាឃុំ និងមេភូមិ។ ដូច្នេះគេអាចនិយាយបានថា ប្រសិនបើគ្មានអន្តរការីដើរតួនាទីនោះទេ យុវជននៅតែគ្មានសេចក្ដីក្លាហាន និងអសកម្មដដែល។

## *ការចូលរួមផ្នែកសង្គម*

យុវជននៅមានចំណេះដឹងតិចនៅឡើយអំពី អង្គការសហគមន៍ (CBOs) ឬសមាគមនៅមូលដ្ឋាន និងមានការចូលរួមស្រាលៗជាមួយអង្គការទាំងនោះ។ ប៉ុន្តែការងារស្ម័គ្រចិត្តជាទូទៅមានការចូលរួមច្រើនពីយុវជន។ ភាពអសកម្មជាទូទៅរបស់ CBOs ធ្វើឲ្យមេភូមិមានតួនាទីសំខាន់ក្នុងការកៀងគរយុវជនស្ម័គ្រចិត្ត (សម្រាប់ជួយសហគមន៍ និង/ឬ ផលប្រយោជន៍គណបក្ស)។ មូលហេតុផ្នែកសេដ្ឋកិច្ច វប្បធម៌ និងបុគ្គល នាំឲ្យមានកង្វះការចូលរួមទូលំទូលាយរបស់យុវជន ក្នុងក្រុមសហគមន៍ និងការងារស្ម័គ្រចិត្តផ្សេងៗ។ តម្រូវការប្រាក់ចំណូលខ្ពស់ជាងមុនបាននាំឲ្យយុវជនជាច្រើន ទៅធ្វើការនៅក្រៅសហគមន៍របស់ពួកគេ។ កង្វះទឹកចិត្តក្នុងការចូលរួម និងការរារាំងពីឪពុកម្ដាយធ្វើឲ្យការចូលរួមរបស់យុវជនកាន់តែមានឧបសគ្គឡើង ហើយកង្វះយន្តការគាំទ្រផ្សេងៗ គឺជាឧបសគ្គសម្រាប់យុវជនដែលចង់ចូលរួម ប៉ុន្តែមិនដឹងថាត្រូវចាប់ផ្ដើមយ៉ាងដូចម្ដេច។ គេរកឃើញថាអង្គការយុវជនជាកាតាលីករដ៏សំខាន់ សម្រាប់ការចូលរួមរបស់យុវជននៅក្នុងសង្គម។ ក្រុមដូចខាងលើនេះ បានជួយបង្កើនការយល់ដឹងរបស់យុវជនអំពីវប្បធម៌នយោបាយ និងផ្ដល់ឱកាសល្អសម្រាប់ការចូលរួមក្នុងសង្គម[២] ដែលទំនងជាកត្តាសម្រាប់សំគាល់អ្នកសកម្ម ចេញពីអ្នកមិនសូវសកម្ម។ ទំនាក់ទំនងល្អជាមួយអាជ្ញាធរឃុំសង្កាត់ សំខាន់ខ្លាំងណាស់សម្រាប់ដំណើរការនេះ។

## *ការចូលរួមខាងផ្នែកនយោបាយ*

កង្វះចំណាប់អារម្មណ៍ ការគោរព ភាពដាច់ឆ្ងាយ និងការភ័យខ្លាច គឺជាលក្ខណៈដែលកើតមានញឹកញាប់ក្នុងសង្គមកម្ពុជា និងមានឥទ្ធិពលក្នុងទំនាក់ទំនង រវាងរដ្ឋាភិបាល និងប្រជាជន។ ប៉ុន្តែសម្រាប់យុវជនមួយចំនួន អារម្មណ៍របស់ពួកគេចំពោះមន្ត្រីនៅមូលដ្ឋាន គឺគោរពច្រើនជាងខ្លាច ពីព្រោះអាជ្ញាធរឃុំអាចប្រឈមនឹងការបោះឆ្នោតទម្លាក់។ បរិយាកាសនយោបាយដែលបើកចំហឡើងឆ្លងតាមដំណើរការវិមជ្ឈការ មានន័យថា យុវជនអាចឥទ្ធិពលទៅលើការសម្រេចចិត្តនៅមូលដ្ឋាន តាមរយៈការប្រជុំជាសាធារណៈ (ប្រជុំក្រុមប្រឹក្សាឃុំនិងប្រជុំភូមិ) និងការជួបទាក់ទងក្រៅផ្លូវការជាមួយមន្ត្រីនៅមូលដ្ឋាន។ ប៉ុន្តែការប្រើប្រាស់សិទ្ធិទាំងនេះនៅមានកម្រិតនៅឡើយ ហើយអ្នកប្រើប្រាស់សិទ្ធិទាំងនេះ ច្រើនជាយុវជនពាក់ព័ន្ធនឹងអង្គការមិនមែនរដ្ឋាភិបាល (NGOs)។ ទោះបីកន្លងមកមិនទាន់ឃើញមានរបាយការណ៍ពី ការបដិសេដសំណើចូលរួមក្នុងប្រជុំក្រុមប្រឹក្សាឃុំយ៉ាងណាក៏ដោយ ក៏ការប្រជុំក្រុមប្រឹក្សាឃុំ គឺជាការប្រជុំមួយដែលតម្រូវឲ្យមានការយល់ព្រម។ ម្យ៉ាងទៀត នៅពេលយុវជនទៅចូលរួមប្រជុំភូមិ ពួកគេទៅក្នុងនាមជាតំណាងរបស់ឪពុកម្ដាយ។ តួនាទីជាបន្ទាប់បន្សំរបស់យុវជនបែបនេះ មានន័យថា សកម្មភាពធ្វើផែនការដោយមានការចូលរួម នៅតែជាកិច្ចការរបស់មនុស្សចាស់។ មានការខ្វែងមតិគ្នាអំពីបញ្ហាថា តើយុវជនគួរចូលរួមប្រជុំភូមិដែរឬទេ។ ទោះយ៉ាងនេះក្ដី មានករណីវិជ្ជមានខ្លះៗទាក់ទងនឹងក្រុមប្រឹក្សាឃុំដាក់បញ្ចូលគំនិត និងសកម្មភាពរបស់យុវជនទៅក្នុងផែនការឃុំ។ ចំណែកឯករណីទាក់ទងនឹងការជួបទាក់ទងក្រៅផ្លូវការជាមួយមន្ត្រីមូលដ្ឋាន និងការដាក់ញត្តិតវ៉ាវិញ គឺកម្រកើតមាន។

---

២ "ការចូលរួមក្នុងសង្គមជាដំណើរការឯកទិសដែលក្នុងនោះ យុវជនបង្កើនការយល់ដឹងពីពិភពនយោបាយ តាមរយៈទំនាក់ទំនងជាមួយមនុស្សពេញវ័យ និងប្រព័ន្ធផ្សព្វផ្សាយ។ ការចូលរួមខាងផ្នែកនយោបាយ ជាដំណើរការមួយដែលប្រជាជនអាចកសាងឥរិយាបថ, គុណតម្លៃ, ជំនឿនិងមតិយោបល់ដែលជួយឲ្យពួកគេក្លាយជាពលរដ្ឋល្អនៅក្នុងប្រទេស ... វាជាប្រភេទជាក់លាក់មួយនៃការរៀនសូត្រផ្នែកនយោបាយ ដែលជួយឲ្យប្រជាជនកសាងនូវឥរិយាបថ, គុណតម្លៃ, ជំនឿ, មតិយោបល់និងអាកប្បកិរិយាអំណោយផលដល់ការក្លាយខ្លួនជាពលរដ្ឋល្អនៅក្នុងប្រទេស" (Anon. 2012)។

### *ការចូលរួមបោះឆ្នោត*

ការសិក្សានេះបង្ហាញថា យុវជនជាទូទៅចាប់អារម្មណ៍ខ្លាំងនឹងការបោះឆ្នោត ដោយមើលឃើញថាជាសិទ្ធិ និងការទទួលខុសត្រូវក្នុងការជ្រើសរើសអ្នកដឹកនាំល្អ និងជំរុញការអភិវឌ្ឍក្នុងសហគមន៍។ គេក៏សង្កេតឃើញដែរថា ការបោះឆ្នោតកំពុងក្លាយជាការពេញនិយមមួយ ដែលជាលទ្ធផលនៃការដើរតាមនិន្នាការសង្គម។ ទោះបីជាចំនួនយុវជនចុះឈ្មោះបោះឆ្នោតបានកើនឡើងគួរឲ្យកត់សម្គាល់ក៏ពិតមែន ប៉ុន្តែយុវជនមិនបានទៅបោះឆ្នោតក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ពីរលើកចុងក្រោយនេះក៏មានអត្រាខ្ពស់ដែរ។ អត្រាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់វ័យក្មេង បានកើនពីប្រមាណ ១% ក្នុងឆ្នាំ២០០៧ ដល់ ៥% ក្នុងឆ្នាំ២០១២ ដែលជាការវិវត្តវិជ្ជមានមួយ ហើយសាធារណជនបានអបអរសាទរជាខ្លាំង។ ក្នុងការសម្រេចចិត្តបោះឆ្នោតឲ្យគណបក្សណាមួយនោះ យុវជនតែងមើលពីការរីកចម្រើនជាក់ស្ដែងក្នុងការអភិវឌ្ឍនៅមូលដ្ឋាន, កម្មវិធីនយោបាយ និងថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ និងសមត្ថភាពរបស់បេក្ខជន ក្នុងការគោរពតាមពាក្យសន្យានៅពេលឃោសនាបោះឆ្នោត។ ព័ត៌មានទាំងនេះជ្រួតជ្រាបដល់សាធារណៈជន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធនាការបោះឆ្នោតជាចម្បង។ ប៉ុន្តែយុវជនត្រូវការព័ត៌មានច្រើនជាងនេះ ដើម្បីធ្វើការសម្រេចចិត្តឲ្យកាន់តែប្រសើរ។ ការបោះឆ្នោតជាសកម្មភាពប្រជាធិបតេយ្យមួយដែលមានប្រជាប្រិយភាព ប៉ុន្តែការចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត អាចជាបញ្ហារសើបមួយ ជាពិសេសសម្រាប់អ្នកស្ម័គ្រចិត្តក្នុងអង្គការយុជនដែលមានកាតព្វកិច្ចបំពេញការងារ ដោយមិនលំអៀងទៅខាងភាគីណាមួយស្របតាមគោលការណ៍របស់អង្គការខ្លួន ហើយក៏មិនចង់ធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងការងាររបស់ខ្លួន ជាមួយមន្ត្រីនៅមូលដ្ឋានដែរ។

### ការពិភាក្សា និងសេចក្ដីសន្និដ្ឋាន

ទោះបីកម្ពុជា បានអនុវត្តកំណែទម្រង់វិមជ្ឈការជាងមួយទសវត្សរ៍មកហើយក្តី ក៏ការចូលរួមរបស់ប្រជាជនជាទូទៅនៅមានកម្រិតទាប។ លទ្ធផលសិក្សានេះបង្ហាញថា ការចូលរួមរបស់យុវជនក៏នៅមានកម្រិតទាបដូចគ្នាដែរ។ ការចូលរួមកម្រិតទាបរបស់យុវជន ជាបញ្ហាមួយដែលត្រូវយកចិត្តទុកដាក់ខ្លាំង។ ការសិក្សានេះបង្ហាញទៀតថា គោលដៅកំណែទម្រង់វិមជ្ឈការដើម្បីជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងអភិបាលកិច្ចមូលដ្ឋានត្រូវប្រឈមជារឿយៗនឹងឧបសគ្គខាងនយោបាយ សេដ្ឋកិច្ចវប្បធម៌ និងរបស់បុគ្គលខ្លួនឯង។ ខាងផ្នែកនយោបាយ សកម្មភាពតិចតួចរបស់ក្រុមប្រឹក្សាឃុំ ដើម្បីជំរុញការចូលរួមរបស់យុវជនមានន័យថា ពួកគេដើរតួនាទីបន្ទាប់បន្សំបើធៀបនឹងអន្តរការីមិនមែនរដ្ឋាភិបាល។ តួយ៉ាងក្នុងចំណោមឃុំដែលក្រុមស្រាវជ្រាវបានចុះពិនិត្យ គ្មានឃុំណាមួយមានផែនការធ្វើឲ្យផែនការអភិវឌ្ឍន៍របស់ខ្លួនមានភាពទាក់ទាញដល់យុវជន និងជំរុញពួកគេឲ្យចូលរួមក្នុងអភិបាលកិច្ចថ្នាក់មូលដ្ឋានឡើយ។ ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍក្រុមយុវជនប្រហែលអាចកែលំអស្ថានភាពបច្ចុប្បន្ន ប៉ុន្តែនៅពេលនេះ សមាគមយុវជននានានៅមានតួនាទីសំខាន់បំផុត។

ទោះបីមានបញ្ហាជាច្រើន នៅរាំងស្ទះដល់ការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចមូលដ្ឋាននៅជនបទក្តី ក៏មានភស្តុតាងជាក់ស្តែង បង្ហាញពីការរីកចម្រើនទៅមុខជាបណ្តើរៗ ទោះបីជាមិនបានស្មើគ្នាល្អពីកន្លែងមួយទៅកន្លែងមួយក្តី។ ការសិក្សានេះមើលឃើញពីសារៈសំខាន់ នៃការប្រែប្រួលទិដ្ឋភាពនយោបាយនៅមូលដ្ឋាន ហើយបានធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោមទាក់ទងនឹងការរួមចំណែកនៃកំណែទម្រង់វិមជ្ឈការ ក្នុងការចូលរួមរបស់យុវជនក្នុងអភិបាលកិច្ចថ្នាក់មូលដ្ឋាននៅតំបន់ជនបទ។

ទី១ ការរួមចំណែកនៃកំណែទម្រង់វិមជ្ឈការ អាចមើលឃើញច្បាស់បំផុតនៅក្នុងដំណើរការបោះឆ្នោត។ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ បានផ្តល់ឱកាសឲ្យយុវជនមានសមត្ថភាពក្លាយខ្លួនជាអ្នកតំណាងនៅមូលដ្ឋាន។ ម្យ៉ាងទៀតសំឡេងយុវជន ក៏កំពុងនិងបន្តមានសារៈសំខាន់ ក្នុងការកំណត់រចនាសម្ព័ន្ធអំណាចនយោបាយថ្នាក់មូលដ្ឋាន ពីព្រោះយុវជនមានចំណែកធំជាងគេក្នុងចំណោមប្រជាជនអ្នកបោះឆ្នោត (៣,៥៣លាននាក់ ឬ ៣៧% នៃចំនួនអ្នកចុះឈ្មោះបោះឆ្នោតសរុប ៩,៦៧លាននាក់ ក្នុងឆ្នាំ២០១២) (NEC 2012)។

ទី២ កំណែទម្រង់បានកែលំអទំនាក់ទំនងការងារ រវាងក្រុមប្រឹក្សាឃុំ អង្គការយុវជន និងអន្តរការីក្រៅរដ្ឋាភិបាលដទៃទៀត ដោយបានបង្កើតនូវ បរិយាកាសនយោបាយមូលដ្ឋានអំណោយផលដល់ការបណ្តុះវប្បធម៌នៃការចូលរួម។ ការសិក្សានេះទទួលស្គាល់នូវតួនាទីរបស់សមាគមយុវជន ដែលមិនត្រឹមតែជួយជំរុញការចូលរួមរបស់យុវជន នៅក្នុងសហគមន៍មូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនចំណេះដឹងរបស់យុវជន អំពីភាពជាពលរដ្ឋ និងកិច្ចការនយោបាយ ព្រមទាំងបទពិសោធន៍ចូលរួមក្នុងសកម្មភាពសង្គម តាមរយៈការបណ្តុះបណ្តាល និងសកម្មភាពស្ម័គ្រចិត្តផ្សេងៗ។ ចាប់តាំងពីពេលបើកទូលាយប្រព័ន្ធនយោបាយនៅកម្ពុជានៅឆ្នាំ១៩៩៣មក អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលបានកើនចំនួនយ៉ាងច្រើន និងធ្វើប្រតិបត្តិការក្នុងទូទាំងប្រទេស ដើម្បីជំរុញការអភិវឌ្ឍ និងលទ្ធិប្រជាធិបតេយ្យ។ ក្រោយការអនុវត្តកំណែទម្រង់វិមជ្ឈការក្នុងឆ្នាំ២០០២ មានអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលជាច្រើនបានចូលរួមក្នុងសកម្មភាពផ្តល់សិទ្ធិអំណាចឲ្យប្រជាពលរដ្ឋ ដើម្បីឲ្យពួកគេទទួលបានអត្ថប្រយោជន៍ពីដំណើរការប្រជាធិបតេយ្យ និងកំណែទម្រង់វិមជ្ឈការ។ ក្នុងពេលជាមួយគ្នានេះ សមាគមយុវជនជាច្រើនបាននិងកំពុងធ្វើការនៅតាមមូលដ្ឋាន ដើម្បីបណ្តុះគំនិតទទួលខុសត្រូវក្នុងចំណោមយុវជន និងជួយពួកគេឲ្យកសាងអនាគតកាន់តែប្រសើរសម្រាប់ខ្លួនឯង និងសម្រាប់សហគមន៍។

ទី៣ ដំណើរការវិមជ្ឈការបានធ្វើឲ្យមានការកែសម្រួលជាបណ្តើរៗនូវទំនាក់ទំនង រវាងកុម្រប្រឹក្សាឃុំ នឹងយុវជន ពោលគឺមានការគោរពច្រើនឡើង និងការខ្លាចតិចជាងមុន។ ការប្រែប្រួលនេះផុសចេញពីការជួយសម្របសម្រួលដោយពួកអន្តរការី (ឧ. មេភូមិ, សមាគមយុវជន) និងការយល់ដឹងកាន់តែច្បាស់ពីតួនាទី និងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាឃុំ ដែលត្រូវតំណាងផលប្រយោជន៍ និងបំពេញតាមតម្រូវការរបស់ប្រជាជន។ ចំណេះដឹងទាំងនេះ បង្កើតជាការរំពឹងទុកលើលទ្ធផលការងារ ដែលអាចដាក់សំពាធទៅលើអ្នកតំណាងឲ្យផ្តល់នូវលទ្ធផលគួរជាទីគាប់ចិត្តរបស់ប្រជាជន។

ផ្អែកលើការយល់ដឹងទទួលបានពីការសិក្សានេះ ក្រុមស្រាវជ្រាវសន្និដ្ឋានថា បញ្ហាប្រឈមនៃវិមជ្ឈការ គឺការជំរុញឲ្យយុវជនចូលរួមកាន់តែស៊ីជម្រៅ ក្នុងកិច្ចការសង្គម និងនយោបាយ។ ដំណើរការនៅគ្រប់កម្រិត ត្រូវសង្កត់ធ្ងន់លើតួនាទីរបស់អ្នកតំណាងជាប់ឆ្នោតនៅមូលដ្ឋាន និងសង្គមស៊ីវិល ដែលក្រុមស្រាវជ្រាវអះអាងថា អាចជួយពង្រីកឥទ្ធិពលនៃកំណែទម្រង់វិមជ្ឈការ តាមរយៈការដោះស្រាយឧបសគ្គផ្នែកវប្បធម៌ និងរបស់បុគ្គលផ្ទាល់ ដើម្បីសម្រួលការចូលរួម។ ការទទួលខុសត្រូវនេះ នឹងក្លាយជាបន្ទុកចម្បងរបស់ថ្នាក់ដឹកនាំនយោបាយ អ្នកកសាងគោលនយោបាយ និងថ្នាក់ដឹកនាំសង្គមស៊ីវិលដែលអាចជួយរៀបចំយុវជនជំនាន់ក្រោយ ឲ្យក្លាយជាធនធានដ៏សំខាន់សម្រាប់កម្ពុជាទៅថ្ងៃអនាគត។ ដំណើរការនេះមិនមែនងាយស្រួលទេ ប៉ុន្តែអនុសាសន៍ខាងក្រោមអាចជួយយុវជនឲ្យប្រើប្រាស់សក្តានុពលរបស់ខ្លួនយបានពេញលេញ និងចូលរួមយ៉ាងសកម្មក្នុងសង្គម។

## ការជួយមតិផ្នែកគោលនយោបាយ

វិធានការដែលអាចជំរុញឲ្យយុវជនចូលរួម កាន់តែផុសផុសក្នុងអភិបាលកិច្ចមូលដ្ឋាន គឺមានច្រើន ប៉ុន្តែមានបីសំខាន់ៗដែលគួរយកចិត្តទុកដាក់ជាពិសេស។

ទី១ បណ្តាស្ថាប័នរដ្ឋាភិបាលអ្នកកសាងគោលនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាល គួរសិក្សាបន្ថែម ដើម្បីស្វែងយល់ពីសារៈសំខាន់នៃរដ្ឋបាលមូលដ្ឋាន ក្នុងការដោះស្រាយបញ្ហាជាក្តីបារម្ភរបស់យុវជន និងបញ្ហាផ្សេងទៀតក្នុងមូលដ្ឋានដែលប៉ះពាល់ដល់ពួកគេ។ ខាងក្រោមនេះ ជាប្រធានបទមួយចំនួនសម្រាប់ការស្រាវជ្រាវបន្ថែម៖

- ស្វែងយល់ពីបញ្ហាប្រឈម និងតម្រូវការរបស់យុវជន និងកំណត់ពីស្ថាប័នដែលអាចជួយដោះស្រាយ
- សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្នុងការដោះស្រាយបញ្ហា និងក្តីបារម្ភរបស់យុវជន
- សមត្ថភាពចាំបាច់ សម្រាប់ឲ្យក្រុមប្រឹក្សាឃុំដើរតួជាអ្នកតភ្ជាប់រវាងថ្នាក់លើនៃជួររដ្ឋាភិបាលនឹងយុវជន ដើម្បីផ្តល់ព័ត៌មានពីវិធីស្វែងរកឱកាសសិក្សា និងការងារ
- តើផែនការរបស់ក្រុមប្រឹក្សាឃុំមានចែងលំអិតគ្រប់គ្រាន់ និងជាប់ទាក់ទងដល់ស្ថានភាពរបស់យុវជន ឬទេ
- ទស្សនៈ និងឥរិយាបថ របស់យុវជនចំពោះផែនការរបស់ក្រុមប្រឹក្សាឃុំ និងកម្មវិធីនយោបាយរបស់គណៈបក្សនយោបាយ
- ឥទ្ធិពលនៃការអប់រំផ្លូវការ និងក្រៅផ្លូវការ ទៅលើការចូលរួមរបស់យុវជន
- ការសិក្សាកាន់តែមានលក្ខណៈជាប្រព័ន្ធ ស្តីពីឥទ្ធិពលនៃយេនឌ័រ ស្ថានភាពសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រ ការអប់រំ និន្នាការនយោបាយ និងសាវតារគ្រួសារ ទៅលើការចូលរួមរបស់យុវជន។

ទី២ រដ្ឋាភិបាលគួរពន្លឿនការអនុវត្តគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍយុវជន ដែលបានអនុម័តនៅឆ្នាំ២០១១។[៣] ការអនុវត្តគោលនយោបាយនេះ ប្រកបដោយប្រសិទ្ធភាព មិនត្រឹមតែផ្តល់ឲ្យយុវជន នូវ វេទិកាមួយដែលមានការទទួលស្គាល់ពីតួនាទីរបស់ពួកគេ និងអាចឲ្យពួកគេចូលរួមជាផ្លូវការក្នុងការអភិវឌ្ឍ និងការសម្រេចចិត្តផ្សេងៗ នៅក្នុងមូលដ្ឋាននោះទេ ប៉ុន្តែថែមទាំងជួយដោះស្រាយបញ្ហាប្រឈម (ដូចជា ការអប់រំ/ជំនាញកម្រិតទាប, ភាពអត់ការងារធ្វើ) ដែលរារាំងដល់ការចូលរួមរបស់យុវជនទៀតផង។

ទី៣ តួនាទីរបស់យុវជននៅក្នុងដំណើរការវិមជ្ឈការ គួរមានចែងដោយឡែកនៅក្នុងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (២០០១) និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៩)។ យុវជនកម្ពុជាមានតួនាទីសំខាន់ផ្នែកនយោបាយសេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសកម្ពុជា ហេតុនេះ ការព្យាយាមជំរុញឲ្យយុវជន ចូលរួមជាផ្លូវការក្នុងការធ្វើវិមជ្ឈការ នឹងផ្តល់ផលប្រយោជន៍ដល់សហគមន៍និងសង្គមជាតិទាំងមូល។

## ឯកសារយោង


Anon. 2012. "Political Culture and Socialization." In *21st Century American Government and Politics*, Section 6.2. Accessed 6 Oct 2014, http://2012books.lardbucket.org/books/21st-century-american-government-and-politics/s10-02-political-socialization.html.

CDRI. 2013. *Cambodia's Development Dynamics: Past Performance and Emerging Priopritie*s. CDRI Special Report. Phnom Penh: CDRI.

Chandler, David. 1996. *Facing the Cambodian Past*. Bangkok: Silkworm.

Chandler, David. 2000. *A History of Cambodia*. Chiang Mai: Westview Press.

CIRCLE, Center for Information and Research on Civic Learning and Engagement. 2002. "Civic Engagement Indicators."Accessed 25 September 2013, www.civicyouth.org/ practitioners/Core_Indicators_Page.htm.

EIC, Economic Institute of Cambodia. 2010. *Report of the Second Citizen Satisfaction Survey in Target Communes of the LAAR Project*. Phnom Penh: EIC.

Heng Seiha, Kim Sedara and So Sokbunthoeun. 2011. *Decentralised Governance in Hybrid Polity: Localisation of D&D Reform in Cambodia.* Working Paper Series No. 63. Phnom Penh: CDRI.

Heng Seiha and So Sokbunthoeun. 2012. "Citizens' Perceptions of Their Responsibilities: Preliminary Analysis of D&D's Contribution to Reciprocial State-Society Relations in Battambang Province", 8-21. *Annual Development Review 2012-13*. Phnom Penh: CDRI.

Heng Seiha, Vong Mun and Chheat Sreang. 2014. *The Enduring Gap: Decentralisation Reform and Youth Participation in*


តទៅទំព័រ ២១

៣ គោលនយោបាយនេះ មានគោលដៅ "អភិវឌ្ឍយុវជនកម្ពុជាឲ្យមានបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា ស្មារតី សីលធម៌ តម្លៃ និងបំណិន ដើម្បីក្លាយជាពលរដ្ឋល្អក្នុងសង្គមជាតិ"។ យុទ្ធសាស្ត្រមួយនៅក្នុងគោលនយោបាយនេះ គឺលើកកម្ពស់ការចូលរួមរបស់យុវជននៅក្នុងសហគមន៍មូលដ្ឋាន ស្ថាប័នផ្សេងៗ និងអង្គការសង្គមស៊ីវិល តាមរយៈយន្តការផ្លូវការ ដូចជា ការកំណត់ឲ្យមានតំណាងយុវជននៅក្នុងគណៈកម្មាធិការ និងក្រុមប្រឹក្សាថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិជាដើម (MOEYS 2011, 2-5)។

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាអំពីសូចនាករសេដ្ឋកិច្ចនានានៃប្រទេសមានសេដ្ឋកិច្ចធំៗក្នុងពិភពលោក និងបណ្តាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីខាងកើត។

នៅត្រីមាសទី២ ឆ្នាំ២០១៤ កំណើនសេដ្ឋកិច្ចនៅប្រទេសមួយចំនួនក្នុងតំបន់អាស៊ី មានស្ថានភាពមិនសូវល្អទេ។ គិតក្នុងរយៈពេល ១២ខែ ផសស នៅប្រទេសសិង្ហបុរី កើន ២,៤% ធៀបនឹង ៣,៧% កាលពីឆ្នាំមុន រីឯកំណើនប្រចាំឆ្នាំនៅប្រទេសថៃ មានត្រឹម ០,៣% ដោយសារមានភាពតានតឹងផ្នែកនយោបាយ ក្នុងចំណោមអ្នកមានឋានៈខ្ពស់ដែលកាន់អំណាច។ ហុងកុង ក៏មានកំណើនសេដ្ឋកិច្ចយឺតដែរនៅត្រីមាសទី២ នេះ ត្រឹមតែ ១,៨% ធៀបនឹង ៣,៣% កាលពីឆ្នាំមុន។ ចលនាគាំទ្រលទ្ធិប្រជាធិបតេយ្យ ដែលមានការធ្វើបាតុកម្មបិទផ្លូវ និងរាំងស្ទះតំបន់ហិរញ្ញវត្ថុ បានជះឥទ្ធិពលលើសកម្មភាពសេដ្ឋកិច្ចនៅហុងកុង។ អ្នកវិភាគនានាបានព្រមានរំលឹកថា សេដ្ឋកិច្ចហុងកុងនឹងត្រូវខូចខាតច្រើនទៀត ប្រសិនបើការតវ៉ានេះនៅតែបន្តទៅមុខ។ ប្រទេសចិនបន្តមានដំណើរការសេដ្ឋកិច្ចល្អគួរសម ដោយមានកំណើន ៧,៥% ក្នុងរយៈពេលមួយឆ្នាំមកដល់ត្រីមាសទី២ ហើយបន្ទាប់មកគឺ ឥណ្ឌូនេស៊ី ដែលមានកំណើន ៦,៤%។

កំណើនសេដ្ឋកិច្ចនៅបណ្តាប្រទេសឧស្សាហកម្ម ក៏ហាក់ដូចជាមិនសូវមានភាពជោគជ័យដែរ ដែលឆ្លុះបញ្ចាំងពីភាពមិនប្រាកដប្រជា និងការកែតម្រូវរចនាសម្ព័ន្ធដ៏ស្មុគស្មាញ ដែលត្រូវកែសម្រួលថែមទៀត។ សេដ្ឋកិច្ចនៅតំបន់ចាយប្រាក់អឺរ៉ូ កើន ០,៧% ក្នុងរយៈពេល ១២ខែកន្លងទៅ រីឯសេដ្ឋកិច្ចជប៉ុន រួមចុះ ០,១%។ ធនាគារជាតិជប៉ុន បានប្រកាសពីផែនការសម្រួលបរិមាណរូបិយវត្ថុមួយ ដើម្បីផ្គត់ផ្គង់សាច់ប្រាក់ ៨០លានលានយេន (៧១២ពាន់លានដុល្លារ) ក្នុងមួយឆ្នាំ ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើម "ព្រួញបី" តាមទ្រឹស្តី Abenomic សំដៅជាស់សកម្មភាពសេដ្ឋកិច្ច និងចៀសផុតពីបរិត្តផរណា។ គេនៅរង់ចាំមើលថា តើផែនការដ៏ក្លាហាននេះ នឹងផ្តល់លទ្ធផលដូចការរំពឹងទុក ឬយ៉ាងណា។ សហរដ្ឋអាមេរិកសម្រេចបានជោគជ័យច្រើនជាង ប្រទេសមានសេដ្ឋកិច្ចជឿនលឿនឯទៀតៗ ដោយទទួលបានកំណើនប្រចាំឆ្នាំ ២,៦% ធៀបនឹង ១,៤% កាលពីត្រីមាសមុន។ ការិយាល័យស្ថិតិពលកម្មរបស់សហរដ្ឋអាមេរិក បានឲ្យដឹងថា នៅខែកញ្ញា ២០១៤ មានការបង្កើតការងារ ២៤៨.០០០កន្លែងថែមទៀត ដែលធ្វើឲ្យអត្រាគ្មានការងារធ្វើស្ថិតនៅត្រឹមកម្រិត ៥,៩% ដោយបានថយចុះ ១,៣ ឯកត្តាភាគរយ ធៀបនឹងឆ្នាំមុន។ គោលនយោបាយបង្កើនរូបិយវត្ថុ និងបង្កើនហិរញ្ញវត្ថុ ត្រូវបានយកមកប្រើដើម្បីកែលំអស្ថានភាពសេដ្ឋកិច្ច ដែលកំពុងធ្លាក់ចុះធ្ងន់ធ្ងរបំផុត គិតតាំងពីពេលមានមហាវិបត្តិសេដ្ឋកិច្ច (Great Depression) រហូតមកទល់សព្វថ្ងៃ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី២ ឆ្នាំ២០១៤ អត្រាអតិផរណានៅគ្រប់ប្រទេសមានកម្រិតទាប និងអាចគ្រប់គ្រងបាន។ ថ្លៃទំនិញនៅកម្ពុជាកើន ៤,៩% ធៀបមួយឆ្នាំមុន។ អតិផរណានៅវៀតណាម មានកម្រិត ៤,៧%។ អត្រាអតិផរណានេះ ឡើងខ្ពស់ដល់ ២៣,៣% នៅឆ្នាំ២០០៨ ក្នុងពេលដែលវៀតណាមអនុវត្តគោលនយោបាយកញ្ចប់ជំរុញសកម្មភាពសេដ្ឋកិច្ច ដើម្បីទប់ទល់នឹងឥទ្ធិពល នៃវិបត្តិហិរញ្ញវត្ថុសកល។ អតិផរណានៅតំបន់ចាយប្រាក់អឺរ៉ូ មានកម្រិតទាបត្រឹម ០,៦%។ ជប៉ុនបានងើបផុតពីបរិត្តផរណាដោយមានអត្រាអតិផរណា ៣,៦%។ ធនាគារជាតិជប៉ុន បានអនុវត្តគោលនយោបាយសម្រួលបរិមាណសាច់ប្រាក់ ដើម្បីរក្សាអត្រាអតិផរណាក្នុងកម្រិត ២% ក្នុងមួយឆ្នាំ។ អតិផរណានៅសហរដ្ឋអាមេរិក មានអត្រា ២,១% ដែលជាកម្រិតមួយស្របតាមការកំណត់នៅក្នុងគោលនយោបាយគ្រប់គ្រងអតិផរណា របស់ក្រុមប្រឹក្សាធនាគារជាតិសហរដ្ឋអាមេរិក (Federal Reserve Board)។

នៅត្រីមាសទី២ ប្រាក់រៀល ឡើងថ្លៃ ០,១% ទល់នឹងប្រាក់ដុល្លារ ធៀបនឹងឆ្នាំមុន ហើយប្រាក់វ៉ុនកូរ៉េខាងត្បូង ឡើងថ្លៃ ៨,៤%។ ប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ៣,៣% ទល់នឹងប្រាក់ដុល្លារ ដែលធ្វើឲ្យផលិតផលជប៉ុន មានឧត្តមភាពប្រកួតប្រជែងនៅលើទីផ្សារពិភពលោក។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ឆ្នាំ២០១៤ ពោត ធ្លាក់ថ្លៃ ២៦,៣% ធៀបមួយឆ្នាំមុន មកត្រឹម ១២៤,៧ដុល្លារ/តោន, កៅស៊ូ ធ្លាក់ថ្លៃ ២៨,៨% មកត្រឹម ១៧៧៨ដុល្លារ/តោន ហើយ អង្ករ ធ្លាក់ថ្លៃ ២៧,៨% មកត្រឹម ៤១១,៧ដុល្លារ/តោន។ ថ្លៃកៅស៊ូ មាននិន្នាការធ្លាក់ចុះ គិតចាប់ពីត្រីមាសទី១ ឆ្នាំ២០១៣ មក។ ប្រេងឆា ឡើងថ្លៃ ៤,៤% ដល់ ៨៨៧,៣ដុល្លារ/តោន ហើយ ប្រេងឆៅ ឡើងថ្លៃ ៥,០% ដល់ ១០៥,៩ដុល្លារ/ធុង។ គិតចាប់ពីឆ្នាំមុនមក ថ្លៃទំនិញកសិកម្មមាននិន្នាការធ្លាក់ចុះ។

អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

តារាង ១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 Q1 | Q2 | Q3 | Q4 | 2014 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.2 | 6.8 | 0.1 | 6.0 | 6.1 | 6.2 | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 6.0 | 5.8 | 5.6 | 5.7 | 5.2 | 5.1 |
| ម៉ាឡេស៊ី | 6.3 | 4.6 | -2.4 | 9.0 | 4.9 | 5.4 | 4.1 | 4.3 | 5.0 | 5.1 | 6.2 | 6.4 |
| សិង្ហបុរី | 7.7 | 1.1 | -4.5 | 14.7 | 4.7 | 1.3 | 0.2 | 3.7 | 5.8 | 5.5 | 5.1 | 2.4 |
| ថៃ | 4.9 | 2.6 | 3.3 | 7.9 | 0.0 | 6.8 | 5.4 | 2.6 | 2.6 | 0.4 | 3.1 | 0.3 |
| វៀតណាម | 8.5 | 6.2 | 4.7 | 6.7 | 6.1 | 5.0 | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 11.9 | 9.0 | 8.2 | 10.4 | 9.3 | 7.8 | 7.7 | 7.5 | 7.8 | 7.7 | 7.1 | 7.5 |
| ហុងកុង | 6.4 | 2.4 | -3.2 | 6.9 | 4.9 | 2.9 | 2.8 | 3.3 | 2.9 | 3.0 | 2.5 | 1.8 |
| កូរ៉េខាងត្បូង | 4.9 | 2.2 | -1.0 | 6.1 | 3.6 | 2.1 | 1.5 | 2.3 | 3.3 | 4.0 | 4.1 | 3.5 |
| តៃវ៉ាន់ | 5.2 | 0.1 | -3.6 | 11.1 | 4.2 | 1.2 | 1.7 | 2.3 | 1.7 | 2.9 | 3.1 | 3.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.9 | 0.9 | -3.8 | 1.6 | 1.6 | -0.5 | 1.1 | -0.7 | -0.4 | 0.5 | 0.9 | 0.7 |
| ជប៉ុន | 2.0 | -0.7 | -5.4 | 4.1 | -0.8 | 1.7 | 0.4 | 0.9 | 2.7 | 2.6 | 3.1 | -0.1 |
| សហរដ្ឋអាមេរិក | 2.2 | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 1.4 | 1.6 | 2.5 | 2.3 | 2.6 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង ២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 Q1 | Q2 | Q3 | Q4 | 2014 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.5 | 19.7 | -0.5 | 4.1 | 5.5 | 3.0 | 1.5 | 2.2 | 3.8 | 4.3 | 4.5 | 4.9 |
| ឥណ្ឌូណេស៊ី | 6.4 | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 5.3 | 5.7 | 8.6 | 8.4 | 7.7 | 7.1 |
| ម៉ាឡេស៊ី | 2.0 | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 1.4 | 1.8 | 2.2 | 3.0 | 3.5 | 3.3 |
| សិង្ហបុរី | 2.1 | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 3.6 | 1.6 | 1.8 | 2.0 | 1.0 | 2.3 |
| ថៃ | 2.2 | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 3.1 | 2.3 | 1.7 | 1.7 | 2.0 | 2.5 |
| វៀតណាម | 8.3 | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.9 | 6.6 | 7.0 | 5.9 | 4.8 | 4.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 4.8 | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.4 | 2.4 | 2.8 | 2.9 | 2.1 | 2.2 |
| ហុងកុង | 2.0 | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 2.2 | 4.0 | 5.3 | 4.3 | 4.1 | 3.6 |
| កូរ៉េខាងត្បូង | 2.5 | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.4 | 1.1 | 1.2 | 0.9 | 1.1 | 1.6 |
| តៃវ៉ាន់ | 1.8 | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 1.8 | 0.8 | 0.0 | 0.5 | 1.1 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.8 | 1.5 | 1.3 | 0.6 | 0.6 | 0.6 |
| ជប៉ុន | 0.1 | 1.4 | -1.3 | -0.7 | 0.1 | -0.03 | -0.3 | -0.3 | 0.9 | 1.4 | 1.5 | 3.6 |
| សហរដ្ឋអាមេរិក | 2.9 | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.7 | 1.4 | 1.6 | 1.2 | 1.4 | 2.1 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង ៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 Q1 | Q2 | Q3 | Q4 | 2014 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4062.7 | 4054.2 | 4140.5 | 4187.1 | 4063.6 | 4037.8 | 3995.0 | 4032.9 | 4062.0 | 4018.9 | 3993.8 | 4026.9 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9419.0 | 9699.0 | 10,413.8 | 9089.9 | 8764.4 | 9363.0 | 9681.9 | 9783.6 | 10,666.0 | 11,545.1 | 11,765.8 | 11,615.3 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.3 | 3.3 | 3.5 | 3.2 | 1.5 | 3.1 | 3.1 | 3.0 | 3.2 | 3.2 | 3.3 | 3.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.5 | 1.4 | 1.5 | 1.4 | 1.3 | 1.2 | 1.2 | 1.2 | 1.3 | 1.3 | 1.3 | 1.3 |
| ថៃ (បាត) | 32.2 | 33.4 | 34.3 | 31.7 | 30.5 | 31.1 | 29.8 | 29.9 | 31.4 | 31.7 | 32.6 | 32.4 |
| វៀតណាម (ដុង) | 16,030.0 | 16,382.0 | 17,725.2 | 19,200.8 | 20,574.3 | 20,856.9 | 20,829.6 | 20,828.0 | 20,908.7 | 21,036.0 | 21,036.0 | 21,036.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ាន់) | 8.0 | 6.9 | 6.8 | 6.8 | 3.3 | 6.3 | 6.2 | 6.2 | 6.1 | 6.1 | 6.1 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 929.0 | 1137.2 | 1277.8 | 1156.3 | 1108.6 | 1126.6 | 1085.9 | 1123.4 | 1108.8 | 1062.0 | 1069.7 | 1028.9 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.9 | 31.5 | 33.0 | 31.3 | 29.4 | 29.6 | 29.5 | 29.9 | 29.9 | 29.6 | 30.3 | 30.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 0.8 | 0.8 | 0.8 | 0.8 | 0.7 | 0.7 | 0.7 |
| ជប៉ុន (យ៉េន) | 117.8 | 102.5 | 93.6 | 87.8 | 79.9 | 79.8 | 92.3 | 98.8 | 98.9 | 100.5 | 102.8 | 102.1 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង ៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៧-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 Q1 | Q2 | Q3 | Q4 | 2014 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - USA (USD/តោន) | 149.1 | 218.2 | 167.3 | 167.3 | 291.4 | 296.5 | 305.2 | 291.4 | 246.2 | 199.3 | 209.6 | 214.7 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 707.7 | 912.2 | 686.8 | 834.7 | 1125.4 | 999.3 | 852.7 | 850.3 | 827.3 | 897.3 | 911.3 | 887.3 |
| កៅស៊ូ SMR 5 (USD/តោន) | 2202.3 | 2586.3 | 1884.8 | 3152.2 | 4630.6 | 3200.7 | 3029.5 | 2497.2 | 2394.6 | 2380.0 | 2034.7 | 1777.6 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 305.4 | 615.3 | 524.5 | 456.2 | 558.5 | 594.8 | 607.0 | 570.0 | 502.3 | 455.7 | 450.7 | 411.7 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 294.6 | 460.4 | 414.0 | 375.4 | 507.9 | 566.1 | 558.4 | 569.8 | 545.1 | 514.9 | 533.0 | 565.7 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 69.3 | 95.4 | 60.5 | 71.6 | 106.2 | 109.5 | 109.5 | 100.9 | 106.9 | 106.4 | 104.7 | 105.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 53.6 | 62.2 | 42.9 | 49.8 | 71.9 | 74.6 | 74.8 | 71.2 | 73.3 | 65.7 | 70.1 | 74.1 |
| ម៉ាស៊ូត (ស្កាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 55.5 | 51.6 | 75.7 | 83.8 | 77.8 | 80.7 | 80.3 | 81.5 | 75.6 | 79.6 | 77.5 | 77.1 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចចម្បងៗ

តាមការគន់គូរ សេដ្ឋកិច្ចកម្ពុជានឹងរក្សាកំណើនខ្លាំងក្នុងអត្រា ៧,០% សម្រាប់ឆ្នាំ២០១៤។ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានធ្វើការប៉ាន់ស្មានប្រហាក់ប្រហែលនេះដែរ។ ទោះយ៉ាងណាក្តី ត្រូវធ្វើការកែសម្រួលលើការតម្រូវរចនាសម្ព័ន្ធដ៏ស្មុគស្មាញមួយចំនួន ជាពិសេស ខាងផ្នែកអប់រំ និងការផ្សារភ្ជាប់ជំនាញទៅនឹងតម្រូវការទីផ្សារ។

នៅត្រីមាសទី២ ឆ្នាំ២០១៤ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ មានស្ថានភាពមិនល្អទេ ដោយគម្រោងអនុម័តចេញបានធ្លាក់ចុះ ៨៥,៥% ធៀបឆ្នាំមុន មកត្រឹម ៣០២,២លានដុល្លារ។ វិនិយោគក្នុងវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៨៧,៦% មកត្រឹម ២៣៩,៣លានដុល្លារ។ វិនិយោគខាងផ្នែកកាត់ដេរនៅតែខ្លាំងក្លា ដោយរួមចំណែក ៧២% ក្នុងវិនិយោគទុនសរុបខាងវិស័យឧស្សាហកម្ម។ វិស័យសេវាកម្មបន្តមានដំណើរការល្អដោយវិនិយោគកើនឡើង ៧,៩% ធៀបឆ្នាំមុន។ វិនិយោគក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងសណ្ឋាគារ ធ្លាក់ចុះ ៨៥,៥% មកត្រឹម ១៥,៤លានដុល្លារ។

ចំនួនភ្ញៀវបរទេសមកដល់កម្ពុជា កើនបានត្រឹម ១,៤% ធៀបនឹងឆ្នាំមុន ដល់ ៩៣៣.០០០នាក់។ ទោះយ៉ាងនេះក្តី ក្រសួងទេសចរណ៍ មានសុទិដ្ឋិនិយមថា កម្ពុជានឹងទទួលបានភ្ញៀវទេសចរប្រមាណ ៤លាននាក់ ក្នុងឆ្នាំ២០១៤ ដោយទទួលបាន ២,២លាននាក់រួចជាស្រេច នៅក្នុងឆមាសទី១ ។ ចំនួនភ្ញៀវមកដល់តាមផ្លូវអាកាស កើន ១០,១% ធៀបនឹងឆ្នាំមុន ប៉ុន្តែភ្ញៀវមកដល់តាមផ្លូវគោក ឬផ្លូវទឹក ធ្លាក់ចុះ ៥,២%។

នៅត្រីមាសទី២ ការនាំចេញ កើន ១៤,៨% ធៀបឆ្នាំមុនក្នុងនេះ ការនាំចេញសម្លៀកបំពាក់ កើន ៩,៥% និងរួមចំណែក ៧៤,២% ក្នុងតម្លៃនាំចេញសរុប។ ទីផ្សារចម្បងៗរួមមាន សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកដែលមានចំណែក ៤០,៥% និង ៣២,៨% រៀងគ្នា ក្នុងតម្លៃនៃការនាំចេញសម្លៀកបំពាក់។ ទោះយ៉ាងនេះក្តី ការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក បានធ្លាក់ចុះ ៤,៧% បើធៀបនឹងឆ្នាំមុន។ មានការលើកមតិឲ្យស្វែងរកទីផ្សារនាំចេញថែមទៀត ដើម្បីទប់ទល់នឹងការប៉ះទង្គិចមិនអាចរំពឹងឃើញផ្សេងៗ នៅក្នុងប្រទេសជាគោលដៅនាំចេញចម្បងៗ។ ការនាំចេញផលិតផលកសិកម្ម កើន ២២,០% ធៀបឆ្នាំមុន។ ការនាំចេញកៅស៊ូ កើន ៣,៤% ទោះបីជាថ្លៃកៅស៊ូបន្តធ្លាក់ចុះក្តី។ នៅត្រីមាសទី២ នេះដែរ ការនាំចូលសរុប កើន ១០,៨% ធៀបឆ្នាំមុន ដល់ ២,៤ពាន់លានដុល្លារ។ ការនាំចូលសាំង កើន ៧,៨%, ការនាំចូលម៉ាស៊ូត កើន ៣,៧% ហើយការនាំចូលសម្ភារសំណង់ កើន ៦៤%។ ឱនភាពពាណិជ្ជកម្ម ថយចុះ ៤៣,៤% ធៀបឆ្នាំមុន មកត្រឹម ៣៣៤,៧លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

តាមការផ្តល់មតិមួយរបស់ដៃគូអភិវឌ្ឍន៍នានា (ឧ. ធនាគារពិភពលោក) គឺរដ្ឋាភិបាល ត្រូវអនុវត្តកំណែទម្រង់ឲ្យបានមធ្យ័ត និងពេញលេញក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពង្រឹងការប្រមូលចំណូល និងកាត់បន្ថយចំណាយខ្ជះខ្ជាយ។ រដ្ឋាភិបាលបានបញ្ជាក់ជាថ្មី ពីការប្តេជ្ញាចិត្តរបស់ខ្លួន និងបានដាក់អនុវត្តកំណែទម្រង់ជាជំហានៗ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ នៅត្រីមាសទី១ ឆ្នាំ២០១៤ ចំណូលសរុបរបស់រដ្ឋាភិបាល កើន ២២,០% ធៀបឆ្នាំមុន ដល់ ២២២០,៥ពាន់លានរៀល។ ចំណូលពន្ធ កើន ២៦,១% រីឯចំណូលមិនមែនពន្ធ ធ្លាក់ចុះ ២៦,៤%។ នៅត្រីមាសទី១ នេះដែរ ចំណាយសរុបធ្លាក់ចុះ ២២,៣% មកត្រឹម ១៦៤២,៤ពាន់លានរៀល ប៉ុន្តែចំណាយចរន្ត កើន ៤២,៥%។ ចំណាយលើបៀវត្សរ៍ កើន ៧០,២% ធៀបឆ្នាំមុន រីឯចំណាយលើឧបត្ថម្ភធន និងជំនួយសង្គមធ្លាក់ចុះ ១៥,៤%។ កំណើនបៀវត្សរ៍មន្ត្រីរាជការ (ឧ. គ្រូបង្រៀន) ជាកត្តាបង្កកំណើនចំណាយលើបៀវត្សរ៍។

## អតិផរណា និង ការវិវត្តរូបិយវត្ថុ

អតិផរណានៅត្រីមាសទី២ កើនដល់ ៤,៨%។ ថ្លៃអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ៥,៣%។ អតិផរណាមាននិន្នាការកើនឡើង ចាប់តាំងពីឆ្នាំ២០១៣ មក ដែលនាំឲ្យចំណាយលើជីវភាពកើនឡើងដែរ។

នៅត្រីមាសទី២ ឆ្នាំ២០១៤ ប្រាក់រៀលឡើងថ្លៃ ០,២% ទល់នឹងប្រាក់ដុល្លារ និង ៨,១% ទល់នឹងប្រាក់បាតថៃ។ មាសធ្លាក់ថ្លៃ ១០,១% ធៀបឆ្នាំមុន មកត្រឹម ១៥៥,៩ដុល្លារ/ជី។ សាំងធ្លាក់ថ្លៃ ១,៤% មកត្រឹម ៥២០០រៀល/លីត្រ រីឯម៉ាស៊ូតឡើងថ្លៃ ០,៣% ដល់ ៥០០៦,៧រៀល/លីត្រ។ ថ្លៃម៉ាស៊ូត និងសាំងក្នុងស្រុក ហាក់ដូចគ្មានប្រែប្រួលទេ ទោះបីជាថ្លៃប្រេងឆៅនៅលើទីផ្សារពិភពលោកមាននិន្នាការធ្លាក់ចុះក្តី។

នៅត្រីមាសទី២ ដដែលនេះ សាច់ប្រាក់ងាយស្រួលសរុប កើន ២០,៨% ធៀបឆ្នាំមុន។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ២០,៥% ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ២១,៦%។ រូបិយវត្ថុទូទៅ កើន ១៤,១% ធៀបឆ្នាំមុន ហើយរូបិយវត្ថុផ្សេងៗ កើន ២២,០%។ កំណើនសាច់ប្រាក់ងាយស្រួលសរុបជាដំណឹងល្អ សម្រាប់ប្រទេសមានសេដ្ឋកិច្ចកំពុងរីកចម្រើន។ ទោះយ៉ាងនេះក្តី ធនាគារជាតិត្រូវពិនិត្យឲ្យដិតដល់ថា ឥណទានផ្តោតចំវិស័យមានផលិតភាពនានា។ លើសពីនេះ ត្រូវពិនិត្យលើកំណើនរូបិយវត្ថុទូទៅ និងរូបិយវត្ថុផ្សេងៗ ព្រមទាំងអត្រាអតិផរណាផងដែរ។

## ស្ថានភាពក្រីក្រ

នៅខែសីហា ២០១៤ ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នករើសអេតចាយ និងអ្នករត់ម៉ូតូឌុប បានធ្លាក់ចុះ បើធៀបឆ្នាំមុន។ គិតពីខែឧសភា តមក ចំណូលរបស់កម្មកររោងចក្រកាត់ដេរ បានធ្លាក់ចុះ រីឯចំណូលរបស់អ្នកលីសែង កើនឡើង។

---

អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ៤៥% ធៀបនឹងអង្កេតលើកមុន ដល់ ៨៤៩៥រៀល។ កត្តាចម្បង គឺចំនួនកម្មករតិចជាងមុន ដែលធ្វើឲ្យប្រាក់កម្រៃកើនឡើងនៅខេត្តកំពង់ស្ពឺ និង កណ្ដាល។ ប្រហែល ៦៧% នៃកម្មករទាំងនេះ ក៏ត្រូវធ្វើការលើដីកសិកម្មរបស់ខ្លួនឯងដែរ ដែលមានទំហំប្រមាណ ០,១ ទៅ ១,៥ហិកតា ហើយអាចផ្ដល់នូវប្រាក់បន្ថែមពីលើចំណូលបានពីការលក់កម្លាំងពលកម្ម។ កសិករដែលគ្មានដីធ្លីត្រូវទ្រទ្រង់ជីវភាពគ្រួសារ ដោយប្រើប្រាស់ធនធានទ្រព្យរួមការចិញ្ចឹមមាន់ទា និងការខ្ចីបុល។ អ្នកស៊ីឈ្នួលធ្វើស្រែ ចំណាយ ២៩% នៃប្រាក់រកបាន ទៅលើម្ហូបអាហារ ដោយត្រូវធ្វើការជាមធ្យម ២៤ថ្ងៃ ក្នុងមួយខែ។

ចំណូលរបស់អ្នកលក់បន្លែ កើន ១៣% ដល់ ១៥.៣៧២ រៀល/ថ្ងៃ។ ក្នុងក្រុមនេះ មាន ៥៣% មកពីខេត្តកណ្ដាល ដូច្នេះអាចធ្វើដំណើរទៅមករៀងរាល់ថ្ងៃ។ សមាជិកក្រុមនេះ ៥៤% ស្នាក់នៅផ្ទះជួល ឬនៅជាមួយសាច់ញាតិ ឬនៅតាមវត្ត។ ពួកគេចាយវាយអស់ត្រឹមតែ ៣៩% នៃប្រាក់រកបានប៉ុណ្ណោះ ប៉ុន្តែប្រាក់ចំណូលតិចតួចនេះ នៅតែមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ។ អ្នកលក់បន្លែ ៧៥% ប្រាប់ថា ចង់ពង្រីកអាជីវកម្មខ្លួន ដើម្បីរកចំណូលបន្ថែម ប៉ុន្តែមិនមានលទ្ធភាពធ្វើ។

ចំណូលរបស់អ្នកបម្រើតាមភោជនីយដ្ឋាន កើន ១៣% ធៀបនឹងខែឧសភា ដល់ ៧៥៦៥រៀល/ថ្ងៃ។ កម្មករគ្រប់គ្នាក្នុងអង្កេតនេះ ជាអ្នកមកពីខេត្ត ក្នុងនោះមាន ៣៨% មកពីព្រៃវែង។ ក្រៅពីប្រាក់កម្រៃ ពួកគេទទួលបានអាហារ និងកន្លែងស្នាក់នៅ ប៉ុន្តែពិបាកនឹងសន្សំប្រាក់បាន ពីព្រោះត្រូវទ្រទ្រង់គ្រួសារនៅឯខេត្ត។

ចំណូលពិតរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ៩,៥% ធៀបនឹងអង្កេតលើកមុន មកត្រឹម ៨៣៣៧រៀល/ថ្ងៃ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ទាំង ៤០នាក់ មាន ៥៥% មកពីខេត្តព្រៃវែង និងខ្លះទៀតមកពីខេត្តកណ្ដាល។ ក្នុងចំណោមពួកគេ មាន ៣៥នាក់ មករាជធានីភ្នំពេញជាមួយក្រុមគ្រួសារទាំងមូល។ អ្នករើសអេតចាយទាំងអស់ ត្រូវជួលកន្លែងស្នាក់នៅ និងតែងស្នាក់នៅជាមួយមនុស្ស ៤នាក់ផ្សេងទៀតជាមធ្យម។ ពួកគេមិនមានការងារអ្វីផ្សេងទេ ហើយប្រាក់រកបានអាចដោះស្រាយតម្រូវការចាយវាយបានតែមួយភាគ ដូច្នេះមាន ៧៥% បានខ្ចីប្រាក់គេ។

អ្នកធាក់ស៊ីក្លូរហូតដល់ ៩៥% បានឆ្លើយសម្ភាសន៍ប្រាប់ថា គាត់មកពីខេត្ត ភាគច្រើន ខេត្តព្រៃវែង និងកំពង់ស្ពឺ (២៣% ដូចគ្នា)។ ក្រុមនេះមានប្រាក់ចំណូល ៩៨៦៧រៀល/នាក់/ថ្ងៃ ដែលទាបជាងកាលពីខែឧសភា ដល់ ៨,៣% និងមាន ៩៧,៥% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ប្រាក់កម្រៃរកបានមិនគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់លើរាល់ចំណាយក្នុងគ្រួសារនោះទេ ដូច្នេះមាន ៦៥% ត្រូវចិញ្ចឹមសត្វ ដូចជាមាន់ទា ដើម្បីរកចំណូលបន្ថែម។ រហូតដល់ ៨៨% នៃអ្នកធាក់ស៊ីក្លូដែលបានឆ្លើយសម្ភាសន៍ ធ្វើដំណើរមករាជធានីភ្នំពេញតែម្នាក់ឯង ហើយត្រូវជួលកន្លែងស្នាក់នៅជាមធ្យមជាមួយមនុស្ស ៣ ឬ ៤នាក់ផ្សេងទៀត។ គាត់ចាយវាយអស់ ៥៦% នៃចំណូលរកបាន ហើយចំណាយលើម្ហូបអាហារ មានចំណែក ៩៤% នៃចំណាយសរុប។

ចំណូលរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ៥,៦% ធៀបនឹងខែឧសភា មកត្រឹម ១២.៦៥៦រៀល/ថ្ងៃ។ រហូតដល់ ៩០% នៃអ្នកឆ្លើយសម្ភាសន៍ បានប្រាប់ថា ចំនួនអ្នករត់ម៉ូតូឌុបកើនឡើង រីឯចំនួនអតិថិជននៅថេរដដែល។ អ្នករត់ម៉ូតូឌុបឆ្លើយសម្ភាសន៍ ២០% អាចពឹងផ្អែកលើប្រាក់ចំណូលខ្លួនដើម្បីទ្រទ្រង់គ្រួសារ រីឯ ៨០% ទៀត ត្រូវពឹងផ្អែកលើប្រភពចំណូលដទៃទៀត ជាពិសេសការចិញ្ចឹមមាន់ទានៅផ្ទះ។ ជាមធ្យម ពួកគាត់ចាយវាយអស់ ៤១% នៃប្រាក់ចំណូលរបស់គាត់ ហើយ ចំណាយលើម្ហូបអាហារមានចំណែក ៩៤% នៃចំណាយសរុប។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នាប្រាប់ថា មិនមានសល់ប្រាក់សម្រាប់សន្សំទុកនោះទេ។

ក្នុងចំណោមកម្មកររោងចក្រកាត់ដេរឆ្លើយសម្ភាសន៍ គ្មានអ្នកណាបានបញ្ចប់ថ្នាក់បឋមសិក្សាឡើយ។ ពួកគេទទួលបានកម្រៃ ១១.៣៨៨រៀល/ថ្ងៃ ឬធ្លាក់ចុះ ០,២% ធៀបនឹងអង្កេតលើកមុន។ មានតែ ១១% នៃកម្មករទាំងនោះប៉ុណ្ណោះ ដែលទទួលបានការបណ្ដុះបណ្ដាលជាឯកជន មុនពេលចូលធ្វើការ។ ជាមធ្យមពួកគេបម្រើការក្នុងរោងចក្រកាត់ដេរបច្ចុប្បន្ន បានជាងពីរឆ្នាំមកហើយ រីឯការងារជាក់ស្ដែងគឺ ដេរ និងមុខងារសាមញ្ញៗផ្សេងទៀត ដែលមិនបានផ្ដល់នូវជំនាញសម្រាប់ការរីកចម្រើនក្នុងវិជ្ជាជីវៈឡើយ។ ទោះយ៉ាងណាក្ដី ៥២% នៃកម្មករបានឆ្លើយប្រាប់ថា មិនចង់ផ្លាស់ប្ដូរការងារទេ ហើយ ៤៤% ប្រាប់ថា មិនទាំងដឹងពីការងារអ្វីផ្សេងដែលខ្លួនឯងអាចធ្វើបានផង។

*តពីទំព័រ ១៧* **កំណែទម្រង់វិមជ្ឈការ...**

*Local Rural Governance*. CDRI Working Paper Series No. 94. Phnom Penh: CDRI.

Hughes, Caroline. 2009. *Dependent Communities: Aid and Politics in Cambodia and East Timor*. Ithaca, NY: Cornell Southeast Asia Program.

Kim Sedara. 2012. “Democracy in Action: Decentralization in Post-Conflict Cambodia.” PhD dissertation, University of Gothenburg.

Kim Sedara and Joakim Öjendal. 2009. “Decentralization as a Strategy for State Reconstruction in Cambodia.” In *Beyond Democracy in Cambodia:Political Reconstruction in a Post-Conflict Society,* edited by J. Öjendal and M. Lilja, 101-135. Copenhagen: NIAS Press.

Malena, Carmen, and Kristina Chhim. 2009. *Linking Citizens and the State: An Assessment of Civil Society Contributions to Good Governance in Cambodia*. Phnom Penh: World Bank Cambodia Country Office.

Martin, Marie Alexandrine. 1994. *Cambodia: A Shattered Society*. Berkeley: University of California Press.

MOEYS, Ministry of Education, Youth and Sport. 2011. *National Policy on Cambodia Youth Development*. Phnom Penh: MOEYS.

NEC, National Election Committee. 2012. “Report on Registered Voters in 2012.” Phnom Penh: NEC.

Öjendal, Joakim, and Kim Sedara. 2006. “‘Korob, Kaud, Klach’: In Search of Agency in Rural Cambodia.” *Journal of Southeast Asia Studies* 37(3): 507-526.

# តាមដានសេដ្ឋកិច្ច-សូចនាករ

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៧-១៤*

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 135.6 | 92.0 | 615.0 | 530.7 | 725.0 | 531.6 | 2.3 | 57.8 | 133.1 | 738.3 | 28.9 | 27.6 |
| ឧស្សាហកម្ម | 709.1 | 724.9 | 818.5 | 403.7 | 2860.1 | 829.3 | 195.4 | 1928.3 | 119.5 | 1014.1 | 179.0 | 239.3 |
| *កាត់ដេរ* | 170.7 | 142.8 | 90.1 | 122.8 | 393.9 | 497.0 | 109.5 | 76.4 | 65.15 | 73.1 | 109.3 | 172.4 |
| សេវាកម្ម | 1742.5 | 10,003.2 | 4432.0 | 1337.3 | 3425.4 | 916.6 | 21.2 | 106.0 | 5.3 | 8.3 | 219.1 | 114.4 |
| *សណ្ឋាគារ និងទេសចរណ៍* | 1048.3 | 8758.1 | 3980.1 | 1105.1 | 2850.9 | 691.5 | 0.0 | 106.0 | 0.0 | 0.0 | 163.3 | 15.4 |
| សរុប | 2587.2 | 10,570.9 | 5865.5 | 2271.7 | 7010.4 | 2278.0 | 218.9 | 2091.1 | 257.9 | 1760.7 | 426.9 | 302.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | -81.1 | 855.5 | -87.7 | 582.8 | -75.8 | -29.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -32.0 | 308.6 | -44.5 | -61.3 | 209 | -67.5 | -47.5 | 666.0 | -39.9 | 52.2 | 95.1 | -85.5 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៧-១៤

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 79.1 | 154.7 | 64.3 | 36.2 | 185.5 | 175.2 | 145.2 | 10.3 | 51.6 | 110.2 | 27.1 | 8.8 |
| ផ្ទះល្វែង | 297.2 | 221.6 | 149.6 | 183.8 | 219.6 | 372.1 | 114.1 | 33.0 | 62.7 | 131.9 | 106.5 | 75.2 |
| ផ្សេងៗ | 259.6 | 740.9 | 227.3 | 269.7 | 199.9 | 463.6 | 154.4 | 238.3 | 336.0 | 130.8 | 190.0 | 141.7 |
| សរុប | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 1010.9 | 443.7 | 281.6 | 450.3 | 372.9 | 323.6 | 225.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 590.9 | -36.5 | 59.9 | -17.2 | -13.2 | -30.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 96.7 | 75.7 | -60.5 | 11.0 | 23.5 | 67.1 | 28.1 | -15.6 | 157.5 | 107.6 | -21.8 | -19.8 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនភ្ញៀវបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៧-១៤

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ចំនួនភ្ញៀវ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1280.2 | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 611.2 | 398.1 | 428.0 | 580.4 | 699.0 | 438.2 |
| តាមផ្លូវគោក និងទឹក | 740.5 | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 560.9 | 522.5 | 536.6 | 572.5 | 569.0 | 495.2 |
| សរុប | 2020.7 | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 1172.1 | 920.5 | 964.6 | 1153.0 | 1268.0 | 933.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 16.4 | -21.5 | 4.8 | 19.5 | 10.0 | -26.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 18.9 | 5.3 | 0.5 | 13.6 | 20.1 | 24.4 | 17.8 | 20.9 | 17.5 | 14.5 | 8.0 | 1.4 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៧-១៤*

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3050.3 | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 1576.9 | 1620.1 | 1969.9 | 1815.4 | 1976.5 | 1859.8 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2938.9 | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 1225.2 | 1259.0 | 1568.5 | 1333.4 | 1464.0 | 1379.2 |
| - ទៅសហរដ្ឋអាមេរិក | 1956.5 | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 526.8 | 474.6 | 597.9 | 476.0 | 531.1 | 452.5 |
| - ទៅសហភាពអឺរ៉ុប | 654.3 | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 397.5 | 477.5 | 572.8 | 521.9 | 532.7 | 558.5 |
| - ទៅអាស៊ាន | 3.2 | 10.76 | 6.9 | 9.9 | 17.6 | 39.4 | 13.0 | 12.7 | 17.4 | 17.2 | 21.9 | 19.3 |
| - ទៅជប៉ុន | 28.5 | 25.2 | 44.5 | 86.5 | 147.0 | 188.6 | 57.6 | 51.4 | 98.1 | 71.6 | 101.4 | 74.9 |
| - ទៅប្រទេសផ្សេងៗ | 296.4 | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 230.3 | 242.8 | 282.4 | 247.4 | 277.0 | 273.9 |
| កសិកម្ម | 55.7 | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 123.8 | 128.9 | 362.4 | 173.0 | 167.0 | 157.3 |
| - កៅស៊ូ | 41.0 | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 36.6 | 38.7 | 282.4 | 51.1 | 31.7 | 40.0 |
| - ឈើ | 8.7 | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 14.5 | 8.9 | 16.9 | 33.3 | 55.9 | 48.4 |
| - ត្រី | 3.2 | 2.3 | 3.9 | 2.8 | 3.1 | 2.0 | 0.3 | 0.5 | 0.2 | 0.2 | 0.3 | 0.2 |
| - អង្ករ | 1.5 | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 65.8 | 56.5 | 57.3 | 82.7 | 57.9 | 52.8 |
| - ផលិតផលកសិកម្មផ្សេងៗ | 1.2 | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 6.6 | 24.4 | 5.7 | 5.7 | 21.2 | 16.0 |
| ផ្សេងៗ | 55.8 | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 274.9 | 232.2 | 272.6 | 308.5 | 345.5 | 323.3 |
| ការនាំចូលសរុប | 3770 | 4272.5 | 4331.5 | 5190.6 | 6375.9 | 8593.3 | 2192.1 | 2211.4 | 2059.7 | 2130.1 | 2238.2 | 2449.3 |
| ក្នុងនេះ៖ | | | | | | | | | | | | |
| សាំង | 73.65 | 84.8 | 91.13 | 108.6 | 294.4 | 308.0 | 1225.2 | 77.2 | 71.3 | 80.5 | 77.4 | 83.2 |
| ម៉ាស៊ូត | 133.7 | 19.5 | 180.7 | 203.8 | 447.0 | 559.5 | 526.8 | 137.4 | 150.9 | 132.2 | 148.5 | 142.5 |
| សម្ភារសំណង់ | 44.31 | 56.3 | 49.7 | 57.6 | 48.1 | 66.1 | 397.5 | 17.8 | 18.0 | 17.2 | 27.8 | 29.2 |
| ផ្សេងៗ | 3519.0 | 4011.8 | 4010.0 | 4820.6 | 5586.4 | 7659.1 | 13.0 | 1979.0 | 1819.4 | 1899.6 | 1984.5 | 2194.5 |
| ជញ្ជីងពាណិជ្ជកម្ម | -719.9 | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | -615.2 | -591.2 | -89.8 | -314.7 | -261.7 | -334.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | 7.4 | 2.8 | 24.6 | -15.0 | 9.8 | -5.8 |
| ការនាំចេញសរុប | - | - | - | - | - | - | 8.4 | 2.7 | 21.6 | -7.8 | 8.9 | -5.9 |
| ការនាំចូលសរុប | - | - | - | - | - | - | 13.1 | 0.9 | -6.9 | 3.4 | 5.1 | 9.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 8.9 | 1.6 | -14.1 | 25.7 | 32.1 | 17.7 | 14.4 | -14.6 | 18.0 | 16.9 | 19.5 | 9.6 |
| ការនាំចេញសរុប | 8.5 | 1.6 | -6.3 | 25.1 | 35.8 | 23.9 | 23.2 | -8.8 | 23.4 | 24.8 | 25.3 | 14.8 |
| ការនាំចូលសរុប | 23.7 | 13.3 | 1.4 | 19.8 | 22.8 | 16.8 | 36.2 | 17.3 | 2.2 | 9.9 | 2.1 | 10.8 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៦-១៤ (ពាន់លានរៀល)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 3259.2 | 1146.1 | 5290.0 | 4885.2 | 5989.0 | 6251.4 | 7691.9 | 1820.2 | 2204.8 | 1868.9 | 2361.2 | 2220.5 |
| ចំណូលចរន្ត | 2881.8 | 1141.6 | 5210.7 | 4855.9 | 5859.1 | 6179.3 | 7443.8 | 1817.4 | 2241.3 | 1858.1 | 2316.3 | 2219.2 |
| ចំណូលពន្ធ | 2270.9 | 965.2 | 4409.9 | 4268.0 | 4693.0 | 5277.5 | 6334.8 | 1577.7 | 2024.0 | 1646.0 | 1950.4 | 1988.7 |
| ពន្ធក្នុងស្រុក | - | 661.8 | 3248.4 | 3088.6 | 3533.6 | 4071.6 | 5002.8 | 1254.5 | 1652.9 | 1300.6 | 1520.1 | 1593.6 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | 303.5 | 1161.5 | 1064.7 | 1159.4 | 1205.9 | 1331.7 | 323.1 | 371.1 | 345.4 | 430.3 | 449.0 |
| ចំណូលមិនមែនពន្ធ | 610.9 | 176.4 | 800.8 | 702.1 | 1166.1 | 901.8 | 1118.2 | 239.8 | 217.4 | 212.2 | 365.9 | 176.6 |
| ចំណូលលើទ្រព្យសម្បត្តិ | - | 13.6 | 78.0 | 64.6 | 291.1 | 63.8 | 143.0 | 8.4 | 18.1 | 24.3 | 33.2 | 11.1 |
| លក់ទំនិញ និងសេវា | - | 124.3 | 424.7 | 408.0 | 460.1 | 588.7 | 667.4 | 153.3 | 173.3 | 178.8 | 245.0 | 160.3 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | 38.5 | 298.2 | 228.2 | 408.9 | 249.3 | 298.8 | 78.1 | 25.9 | 9.0 | 87.7 | 5.2 |
| ចំណូលជាមូលធន | 377.4 | 4.5 | 79.3 | 29.3 | 129.9 | 72.1 | 247.9 | 6.2 | 11.5 | 10.7 | 45.0 | 1.3 |
| ចំណាយសរុប | 4174.7 | 1689.7 | 6297.8 | 7383.5 | 8784.6 | 9032.4 | 9660.9 | 2114.8 | 3181.6 | 3093.0 | 4146.4 | 1642.4 |
| ចំណាយជាមូលធន | 1638.1 | 807.4 | 2574.4 | 2694.9 | 2853.2 | 3546.9 | 3628.3 | 1108.4 | 1273.7 | 1350.6 | 1834.8 | 208.5 |
| ចំណាយចរន្ត | 2536.8 | 882.3 | 3809.0 | 4440.0 | 4773.1 | 5341.2 | 6188.4 | 1006.4 | 1907.8 | 1742.4 | 2311.6 | 1433.8 |
| បៀវត្សរ៍ | 822.0 | 362.6 | 1397.0 | 2012.0 | 2048.8 | 2170.6 | 2486.6 | 505.0 | 757.0 | 827.3 | 908.0 | 859.6 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | 194.2 | 927.1 | 871.4 | 1099.4 | 1518.8 | 1586.8 | 252.0 | 652.5 | 285.0 | 373.4 | 213.1 |
| ចំណាយចរន្តផ្សេងទៀត | - | 325.5 | 1384.9 | 1556.6 | 1624.8 | 1651.8 | 2115.1 | 249.4 | 498.3 | 630.1 | 1030.2 | 361.1 |
| សមតុល្យសរុប | -915.5 | -543.6 | -1007.8 | -2498.3 | -2795.7 | -1271.4 | -1969.0 | -294.6 | -976.7 | -1224.1 | -1785.2 | 578.1 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | -445.1 | 741.5 | 2055.10 | 1746.1 | 1845.2 | -2781.0 | 2457.8 | 906.0 | 1150.6 | 1032.2 | 1237.4 | -14.4 |
| ហិរញ្ញប្បទានក្នុងស្រុក | - | -185.8 | -127.00 | 474.9 | 938.6 | 2379.2 | -332.9 | -470.6 | 270.3 | 113.0 | 65.8 | -14.4 |

Source: MEF website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៧-១៤

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 19.7 | -0.7 | 4.1 | 5.4 | 2.3 | 1.5 | 2.3 | 3.7 | 4.7 | 4.6 | 4.8 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 9.9 | 33.1 | -0.3 | 4.4 | 6.5 | 2.5 | 1.6 | 3.3 | 4.8 | 5.8 | 5.7 | 5.3 |
| - ដឹកជញ្ជូន | 5.8 | 19.4 | -10.7 | 7.0 | 6.9 | 3.3 | -0.7 | -1.0 | -0.1 | -0.4 | -1.1 | 0.5 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4062.7 | 4058.2 | 4140.5 | 4187.1 | 4063.6 | 4039.2 | 3995 | 4033.1 | 4062.0 | 4059.0 | 3993.8 | 4026.9 |
| រៀលក្នុង ១ បាតថៃ | 122.8 | 123.5 | 121.1 | 133.1 | 133.2 | 130.0 | 134.7 | 135.74 | 131.4 | 130.7 | 123.0 | 124.8 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.0 | 24.8 | 23.4 | 21.7 | 19.7 | 19.4 | 19.3 | 19.3 | 19.3 | 19.4 | 19.1 | 19.2 |
| ថ្លៃមាស (ដុល្លារ/ជី) | 83.2 | 105.9 | 113.1 | 147.5 | 184.5 | 200.9 | 197.3 | 173.4 | 161.1 | 171.8 | 156.6 | 155.9 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3262.3 | 4555.2 | 3170.9 | 3859.3 | 4761.2 | 4941.2 | 5134.4 | 4992.0 | 5022.5 | 4927.0 | 4971.2 | 5006.7 |
| ថ្លៃសាំង (រៀល/លីត្រ) | 4005.0 | 4750.8 | 3593.1 | 4368.1 | 5044.5 | 5312.7 | 5410.5 | 5274.5 | 5245.2 | 5126.7 | 5171.5 | 5200.0 |

Sources: NIS, NBC and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៧-១៤ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2007 | 2009 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17,893.9 | 18,154.5 | 19,976.7 | 21,772.9 | 18,720.7 | 21,260.1 | 23,344.4 | 26,235.8 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 576.0 | 1513.3 | 1573.0 | 2778.9 | 5760.8 | 10,437.4 | 10,504.1 | 9886.1 | 10,634.8 | 11,508.3 | 11,817.4 | 12,024.4 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -1816.0 | -2987.0 | -2252.0 | -2126.6 | -2123.1 | -2486.4 | -2991.6 | -3012.6 | -2804.4 | -2794.9 | -3349.3 | -3747.3 |
| ឥណទានដល់ផ្នែកឯកជន | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 17,552.8 | 23,536.6 | 24,820.2 | 25,146.0 | 26,445.3 | 27,608.8 | 28,584.5 | 30,621.3 |
| រូបិយវត្ថុទូទៅ M2 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 23,654.7 | 28,591.9 | 30,480.8 | 31,659.1 | 29,355.5 | 32,768.4 | 35,161.8 | 38,259.9 |
| រូបិយវត្ថុ M1 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4500.6 | 4585.9 | 4720.8 | 4878.2 | 5376.2 | 5231.3 |
| រូបិយវត្ថុផ្សេងៗ | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 19,698.5 | 24,546.2 | 25,980.2 | 27,073.2 | 24,634.8 | 27,890.2 | 29,785.7 | 33,028.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 62.9 | 4.8 | 36.9 | 20.0 | 17.8 | 20.9 | 22.6 | 18.8 | 9.3 | 14.6 | 15.4 | 20.8 |
| រូបិយវត្ថុ M1 | 23.8 | 16.9 | 30.1 | 3.2 | 16.9 | 2.3 | 12.9 | 18.4 | 23.6 | 20.6 | 19.5 | 14.1 |
| រូបិយវត្ថុផ្សេងៗ | 75.2 | 2.2 | 38.6 | 24.0 | 17.9 | 44.6 | 24.4 | 18.8 | 6.9 | 13.6 | 14.6 | 22.0 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2011 | 2012 | 2013 | | | | 2014 | | | 2014 | | |
| | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 9532 | 10,303 | 9592 | 10,681 | 10,636 | 10,842 | 10,832 | 10,764 | 9867 | 12.9 | 0.8 | -7.2 |
| អ្នកលីសែង | 10,785 | 12,143 | 12,749 | 12,823 | 14,157 | 13,260 | 12,141 | 12,568 | 13,399 | -4.8 | -2.0 | -5.4 |
| អ្នកលក់បន្លែតូចតាច | 8337 | 10,771 | 9953 | 11,571 | 11,490 | 12,449 | 12,294 | 13,581 | 15,372 | 23.5 | 17.4 | 33.8 |
| អ្នករើសអេតចាយ | 8388 | 8680 | 9487 | 10,440 | 9620 | 9732 | 9593 | 9214 | 8337 | 1.1 | -11.7 | -13.3 |
| អ្នកបម្រើភោជនីយដ្ឋាន* | 5986 | 6111 | 6529 | 6744 | 6791 | 6723 | 7449 | 6696 | 7565 | 14.1 | -0.7 | 11.4 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5695 | 6151 | 5811 | 6427 | 7771 | 6388 | 8932 | 5836 | 8795 | 53.7 | -9.2 | 13.2 |
| កម្មកររោងចក្រកាត់ដេរ | 8409 | 8932 | 10,004 | 9776 | 10,420 | 10,442 | 9548 | 11,412 | 11,388 | -4.6 | 16.7 | 9.3 |
| អ្នករត់ម៉ូតូឌុប | 11,568 | 12,930 | 14,433 | 12,522 | 13,656 | 13,189 | 13,227 | 13,401 | 12,656 | -8.4 | 7.0 | -7.3 |
| កម្មករសំណង់គ្មានជំនាញ | 10,307 | 11,078 | 12,554 | 13,728 | 13,023 | 13,431 | 15,162 | 15,316 | 15,401 | 20.8 | 11.6 | 18.3 |
| កម្មករសំណង់មានជំនាញ | 13,159 | 13,743 | 15,162 | 14,136 | 15,822 | 16,647 | 15,163 | 15,765 | 20,420 | 0.0 | 11.5 | 29.1 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI

*តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ**...

ភ្នំពេញ ដើម្បីពិភាក្សាបង្ហើយការសិក្សាស្តីពី "តួនាទីនៃគោលនយោបាយ និងស្ថាប័ននានា ក្នុងការថែទាំសុខភាព និងអប់រំ នៅតាមបណ្តាប្រទេស GMS" និងពិនិត្យពីជំហានបន្ទាប់សម្រាប់បន្តកម្មវិធីស្រាវជ្រាវរបស់បណ្តាញនេះ។ សន្និសីទប្រចាំឆ្នាំលើកទី៧ នៃវេទិកាស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា (DRF) បានប្រារព្ធឡើងនៅថ្ងៃទី១១-១២ ខែកញ្ញា នៅរាជធានីភ្នំពេញ ក្រោមប្រធានបទ "ការរៀបចំការអប់រំឲ្យបានត្រឹមត្រូវទៅតាម តម្រូវការកំពុងផ្លាស់ប្តូរនៃទីផ្សារការងារនៅកម្ពុជា"។ ព្រឹត្តិការណ៍រយៈពេលបីថ្ងៃនេះ មានអ្នកចូលរួមជាង ៣០០នាក់ រួមមាន អ្នកកសាងគោលនយោបាយអ្នកស្រាវជ្រាវ អ្នកសិក្សាវិភាគ និងដៃគូអភិវឌ្ឍន៍។

ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI បានធ្វើការប្រជុំប្រចាំឆមាសរបស់ខ្លួននៅថ្ងៃទី១ ខែកញ្ញា។ ក្រុមប្រឹក្សាភិបាលបានលើកសរសើរដល់បុគ្គលិក និងថ្នាក់គ្រប់គ្រងរបស់ CDRI ចំពោះលទ្ធផលជាវិជ្ជមាន នៃការបូកសរុបពាក់កណ្តាលអាណត្តិលើភាពជាដៃគូឆ្នាំ២០១១-១៥ រវាង CDRI នឹងទីភ្នាក់ងារសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍អន្តរជាតិ នៃប្រទេសស៊ុយអែត (Sida) ដែលជាដៃគូផ្តល់ធនធានរយៈពេលវែងរបស់ CDRI។ ក្រុមប្រឹក្សាភិបាលបានកត់សំគាល់ជាពិសេសថា CDRI រក្សាបាននូវ "តុល្យភាពដោយប្រយ័ត្នប្រយែង រវាងការចូលពាក់ព័ន្ធ និងឯករាជ្យភាពរបស់ខ្លួន"។ ក្រុមប្រឹក្សាភិបាល បានស្វាគមន៍ការចូលមកកាន់តំណែងរបស់នាយកប្រតិបត្តិថ្មី ហើយបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់លោកនាយកប្រតិបត្តិចប់អាណត្តិចំពោះសមិទ្ធផល និងការចូលរួមចំណែកដ៏ធំធេងក្នុងការអភិវឌ្ឍ CDRI, ការដឹកនាំវិទ្យាស្ថានឲ្យសម្រេចបាននូវស្តង់ដារវិជ្ជាជីវៈដ៏ខ្ពស់, ការបំពេញតាមចក្ខុវិស័យ និងប្រឹងលើកស្ទួយឲ្យកាន់តែល្អឡើងទៀត, ការតាំងចិត្តដ៏មោះមុតធ្វើការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់បុគ្គលិក និងធ្វើកម្ពុជាភាវូបនីយកម្មលើថ្នាក់គ្រប់គ្រងរបស់វិទ្យាស្ថាន, ការផ្តល់អាទិភាពដល់ផ្នែកស្រាវជ្រាវរបស់កម្ពុជាជាចម្បង, ការជំរុញឲ្យវិទ្យាស្ថាន CDRI មានសំឡេងប្រកបដោយឥទ្ធិពល និងការគោរពនៅក្នុងសហគមន៍ស្រាវជ្រាវក្នុងតំបន់ និងអន្តរជាតិ, និងការជួយការពារគុណតម្លៃដ៏ប្រពៃបំផុតរបស់ CDRI ពោលគឺ ភាពល្អប្រណិត និងឯករាជ្យភាព។

## ផ្នែកស្រាវជ្រាវ

### *កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ* (DGPSR)

ការសិក្សាចំនួនបួនបានចប់សព្វគ្រប់ ដោយមានការផ្ញើចេញនូវរបាយការណ៍ស្តីពី "ដំណោះស្រាយនយោបាយ និងកំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា" និង "ដំណោះស្រាយនយោបាយ និងវិស័យសុខាភិបាលនៅកម្ពុជា"ព្រមទាំងការបោះពុម្ពផ្សាយឯកសារពិភាក្សាស្តីពី "ការចូលរួមខាងផ្នែកនយោបាយរបស់យុវជននៅកម្រិតឃុំ" និង "រដ្ឋកម្ពុជា៖ តើមានលក្ខណៈល្អយ៉ាងណាសម្រាប់ការអភិវឌ្ឍ?"។ ឯកសារពិភាក្សាទី៣ ស្តីពី "ការអនុវត្តជាក់ស្តែងនូវវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស" កំពុងរៀបចំសម្រាប់ការបោះពុម្ពផ្សាយ។

គម្រោងសិក្សាបួន កំពុងអនុវត្តទៅមុខ។ សម្រាប់ការសិក្សាពី "ការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា" ក្រុមស្រាវជ្រាវបានអនុវត្តរួចរាល់នូវ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងការប្រមូលទិន្នន័យជុំទី១ និងការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ។ សម្រាប់ការសិក្សាស្តីពី "លំហូរព័ត៌មានថ្មីៗ និងអភិបាលកិច្ចនៅមូលដ្ឋាន" ក្រុមស្រាវជ្រាវកំពុងតាក់តែងអត្ថបទផ្សព្វផ្សាយមួយ។ សម្រាប់ការសិក្សាស្តីពី "វិមជ្ឈការក្នុងការផ្តល់សេវាសង្គម៖ ករណីសិក្សាពីវិស័យសុខាភិបាល" ការសិក្សាដល់កន្លែងកំពុងអនុវត្តទៅមុខ។ ដំណាក់កាលទី១ នៃការសិក្សាដល់កន្លែង និងរបាយការណ៍ព្រាងសម្រាប់គម្រោងរួមគ្នាមួយស្តីពី "ការសម្រេចចិត្ត និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការគ្រប់គ្រងធនធានទឹក និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា" ក៏បានអនុវត្តរួចរាល់ដែរ។

នៅខែកញ្ញា អ្នកស្រាវជ្រាវនារីមួយរូប បានតំណាងឲ្យកម្ពុជាក្នុងឋានៈជាឯកអគ្គរដ្ឋទូតវ័យក្មេង និងបានធ្វើបទបង្ហាញមួយនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលយុវវ័យ ដើម្បីសន្តិភាពប្រចាំឆ្នាំ២០១៤។ សិក្ខាសាលានេះ ប្រមូលផ្តុំថ្នាក់ដឹកនាំវ័យក្មេងមកពី ១៥ប្រទេស ដែលជាតំណាងនៃសង្គមមានជនជាតិ និងវប្បធម៌ខុសៗគ្នាជាច្រើន ឲ្យមកជុំគ្នា ដើម្បីបង្ហាញពីចក្ខុវិស័យរបស់ខ្លួនក្នុងការលើកកម្ពស់សន្តិភាព និងយុត្តិធម៌ ព្រមទាំងពង្រីកការយល់ដឹងឲ្យបានកាន់តែស៊ីជម្រៅអំពីលក្ខណៈពិសេស និងបញ្ហាប្រឈមរបស់តំបន់អាស៊ី។

### *កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ* (PARD)

គម្រោងចំនួន១០ កំពុងអនុវត្តទៅមុខ ក្នុងនេះមាន ៤គម្រោង ជាកិច្ចសហការជាមួយកម្មវិធីផ្សេងទៀតរបស់ CDRI។ របាយការណ៍ព្រាងលើកទី២ ស្តីពី "ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យា ទៅលើជីវភាពរបស់ម្ចាស់ដីតូចៗ" ដែលទទួលមូលនិធិពី Sida បានចប់សព្វគ្រប់។ គម្រោង "ការរចនារៀបចំក្របខ័ណ្ឌវាយតម្លៃ និងការត្រួតពិនិត្យលើអង្កេតគោល និងអង្កេតចុងបញ្ចប់ សម្រាប់ការជួយទ្រទ្រង់ដល់ជីវភាព និងទ្រព្យផលិតកម្ម" ដែលទទួលបានមូលនិធិពី កម្មវិធីស្បៀងអាហារពិភពលោកនោះ បានបញ្ចប់ការប្រមូលទិន្នន័យ និងកំពុងស្ថិតក្នុងដំណាក់កាលវិភាគទិន្នន័យជាក់ស្តែង។ របាយការណ៍ស្រេចបាច់ស្តីពី "អង្កេតពីការចម្លងតាមគ្នាក្នុងផលិតកម្មផ្កា បន្លែ ផ្លែឈើ ស្រូវ និងវារីវប្បកម្ម" ដែលទទួលបានមូលនិធិពី USAID តាមរយៈ Fintrac បានបញ្ជូនទៅម្ចាស់ជំនួយ ហើយលទ្ធផលស្រាវជ្រាវមានធ្វើជាបទបង្ហាញជូនដល់ក្រុមការងាររបស់ USAID/Fintrac នៅឯស្ថានទូតសហរដ្ឋអាមេរិក ក្នុងខែកញ្ញា។ ការប្រមូលទិន្នន័យសម្រាប់គម្រោងទទួលបានមូលនិធិពី Sida ស្តីពី "ផលប៉ះពាល់នៃគោលនយោបាយជំរុញការនាំចេញស្រូវ និងសន្តិសុខស្បៀង" បានចប់រួចរាល់។ របាយការណ៍នៃគម្រោង "ការសិក្សាពីយន្តកម្មនៅតាមកសិដ្ឋាន និងនិន្នាការទីផ្សារពលកម្មក្នុងវិស័យកសិកម្ម" ដែលទទួលមូលនិធិពី Sida និងករណីសិក្សាពីរ ស្តីពី "សត្វចិញ្ចឹម" និង "ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម" ដែលស្ថិតក្នុងដំណាក់កាលទី២ នៃគម្រោង "គោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធដាំដុះផ្តោតលើដំណាំស្រូវ នៅតំបន់មេគង្គកណ្តាល" ដែលទទួលបានមូលនិធិពី ACIAR នោះ កំពុងតែចងក្រងឡើង។

### *កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់* (ETRC)

របាយការណ៍ពីរ ស្តីពី "កំណើនសេដ្ឋកិច្ច វិសមភាព និងការកាត់បន្ថយភាពក្រីក្រ" និង "ការវាយតម្លៃពីភាពអំណោយផលដល់ជនក្រីក្រនៃគោលនយោបាយសារពើពន្ធ" ដែលស្ថិតក្នុងគម្រោងទទួលបានជំនួយទ្រទ្រង់រយៈពេល ៥ឆ្នាំ របស់ Sida ស្តីពី "កំណើនសម្រាប់គ្រប់គ្នា" នោះ កំពុងចងក្រងបញ្ចប់សម្រាប់បោះពុម្ពផ្សាយជាឯកសារពិភាក្សា។ ដើម្បីផ្តល់ការយល់ដឹងកាន់តែស៊ីជម្រៅពីកំណើនសម្រាប់គ្រប់គ្នានោះ គម្រោងស្រាវជ្រាវថ្មីចំនួន៣ កំពុងរចនារៀបចំឡើង ដោយផ្អែកលើសំណុំទិន្នន័យអង្កេតតាមពេលវេលាបន្តបន្ទាប់ប្រាំលើក លើ ៧៩៣គ្រួសារ និងផ្តោតលើភាពក្រីក្រ ទីផ្សារពលកម្ម និងមីក្រូហិរញ្ញវត្ថុ។ ក្រុមស្រាវជ្រាវ បានគណនារួចរាល់នូវតួលេខប៉ាន់ស្មានជាដំបូងៗមួយចំនួននៃភាពក្រីក្រពុំរ៉ៃ និងភាពក្រីក្របណ្តោះអាសន្ន។ លទ្ធផលជាដំបូងៗទទួលបានពីការត្រួតពិនិត្យលំអិតឡើងវិញ លើការសិក្សាស្តីពី "គោលការណ៍ណែនាំផ្អែកនយោបាយស្តីពីការអភិវឌ្ឍវិស័យឯកជន និងភាពក្រីក្ររ៉ាំរ៉ៃ" ដែលទទួលបានមូលនិធិពី វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ODI) នោះ បានយកទៅលើកបង្ហាញក្នុងសិក្ខាសាលាពិគ្រោះយោបល់មួយស្តីពី ការអភិវឌ្ឍវិស័យឯកជន និងភាពក្រីក្ររ៉ាំរ៉ៃនៅតំបន់អាស៊ីអាគ្នេយ៍ នៅដើមខែសីហា រីឯរបាយការណ៍នៃគម្រោងនេះកំពុងចងក្រងបញ្ចប់។ សម្រាប់គម្រោង "ទំនាក់ទំនងរវាងគោលនយោបាយសាធារណៈ ចំណាកស្រុក និងការអភិវឌ្ឍនៃប្រទេសជាដៃគូ៖ ករណីសិក្សា និងអនុសាសន៍គោលនយោបាយ" ដែលទទួលមូលនិធិពី អង្គការដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ក្រុមស្រាវជ្រាវ បានធ្វើអង្កេតគ្រួសាររួចហើយ រីឯការធ្វើសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ ក៏បានចប់រួចរាល់ដែរ ហើយសព្វថ្ងៃកំពុងធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ។ របាយការណ៍ព្រាងស្តីពី "ការត្រួតពិនិត្យជាយុទ្ធសាស្ត្រលើការសិក្សាសាកល្បង របស់កម្មវិធីស្បៀងអាហារពិភពលោក (WFP) នៅប្រទេសមានចំណូលមធ្យម "ករណីប្រទេសកម្ពុជា" ដែលទទួលមូលនិធិពី WFP បានចប់សព្វគ្រប់ និងបញ្ជូនទៅម្ចាស់ជំនួយឲ្យផ្តល់មតិ។ គម្រោងថ្មីមួយ ស្តីពី "ការសិក្សាក្នុងតំបន់ ស្តីពីតំបន់សេដ្ឋកិច្ចពិសេស" ទើបទទួលបានកិច្ចសន្យាឲ្យស្រាវជ្រាវអំពីធនាគារអភិវឌ្ឍន៍អាស៊ី។

កិច្ចប្រជុំពិគ្រោះយោបល់របស់ បណ្តាញវិភាគអភិវឌ្ឍន៍នៃមហាអនុតំបន់មេគង្គ (GMS-DAN) បានរៀបចំឡើងនៅថ្ងៃទី១០ កញ្ញា ដើម្បីពិភាក្សាលើគោលគំនិតសម្រាប់ធ្វើការស្រាវជ្រាវស្តីពី "ទីផ្សារពលកម្ម កង្វះខាតជំនាញ និងការអភិវឌ្ឍវិស័យឯកជន និងសហគ្រាស ក្នុង GMS៖ ទិដ្ឋភាពតាមប្រទេស និងក្នុងតំបន់" និងលទ្ធភាពកសាងភាពជាដៃគូ សម្រាប់ដំណាក់កាលបន្ទាប់នៃ GMS-DAN។ ដើម្បីសម្រេចបាននូវភាពជាដៃគូធំទូលាយនៅមហាអនុតំបន់មេគង្គ និងដើម្បីគាំទ្រដល់កំណើនការស្រាវជ្រាវមានគុណភាពខ្ពស់ពី គោលនយោបាយអភិវឌ្ឍន៍ និងការធ្វើសមាហរណកម្មក្នុងមហាអនុតំបន់មេគង្គនោះ វិទ្យាស្ថាន CDRI បានទទួលស្វាគមន៍អ្នកស្រាវជ្រាវពីរូបមកពី មជ្ឈមណ្ឌលដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម នៃវិទ្យាស្ថានធនធានអភិវឌ្ឍន៍មីយ៉ាន់ម៉ា។

### *កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន* (NRE)

របាយការណ៍ស្ដីពី "បច្ចេកវិទ្យាកសិកម្មៈ ការអនុវត្ត និង ចន្លោះខ្វះខាតក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ" ដែល ទទួលមូលនិធិពី Sida កំពុងចងក្រងឡើងសម្រាប់បោះពុម្ពផ្សាយ ជាឯកសារពិភាក្សា នៅចុងឆ្នាំ២០១៤។ គម្រោងទទួលមូលនិធិ ពីក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ច និងសង្គម (ESRC) ស្ដីពី "ប្រទេសចិនឈានឡើងកម្រិតសកល" កំពុងស្ថិតក្នុងដំណាក់ កាលកត់ត្រាជាលាយលក្ខណ៍អក្សរ បកស្រាយ និងដាក់លេខ កូដសម្រាប់ធ្វើវិភាគលើព័ត៌មានបានពីសម្ភាសន៍ និងការចុះ សិក្សាដល់កន្លែង។

ឯកសារពិភាក្សាលេខ ៩៧ ទើបចេញផ្សាយថ្មី ស្ដីពី "ឧបករណ៍ និងវិធីសាស្ត្រវាយតម្លៃពីភាពងាយរងគ្រោះ និងការ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅតំបន់អាងទន្លេសាប នៅកម្ពុជា" ជាលទ្ធផលស្រាវជ្រាវដំបូងក្នុងចំណោមលទ្ធផល រំពឹងទុកនានានៃ គម្រោងស្រាវជ្រាវទទួលមូលនិធិពី IDRC ស្ដីពី "ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកនៅកម្ពុជា"។ ការសិក្សាតាមដានបន្ត មានជាអាទិ៍ "ការសិក្សាផ្នែកធារាសាស្ត្រ និងការវាយតម្លៃពីភាពងាយរងគ្រោះ" កំពុងអនុវត្តទៅមុខ។ ដើម្បី កសាងសមត្ថភាពក្នុងតំបន់ ដែលជាសមាសធាតុដ៏សំខាន់មួយ នៃគម្រោង គឺមានការផ្ដល់អាហារូបករណ៍ដល់និស្សិតកម្ពុជា វ័យក្មេង ១៨នាក់ ឲ្យសិក្សាថ្នាក់បរិញ្ញាប័ត្រ និងថ្នាក់អនុបណ្ឌិត នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានបច្ចេកវិទ្យា កម្ពុជា។ គម្រោងថ្មីមួយទទួលមូលនិធិពី កម្មវិធីសម្ព័ន្ធភាព ប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) នៃក្រសួងបរិស្ថាន ស្ដីពី "ការសិក្សាលើទម្លាប់ ឥរិយាបថ និងចំណេះដឹងទូទាំងប្រទេស ក្នុងឆ្នាំ២០១១ អំពី ការប្រែប្រួលអាកាសធាតុនៅកម្ពុជា" បានចាប់អនុវត្តទៅមុខ។

សំណើអនុវត្តគម្រោងជាច្រើន បានដាក់ជូនទៅម្ចាស់ជំនួយ និងកំពុងរង់ចាំការឆ្លើយតបវិញ គឺមាន គម្រោង "ការផ្ដល់សិទ្ធិ អំណាច ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់អ្នកពាក់ព័ន្ធ ទាំងអស់ នៅក្នុងខ្សែចង្វាក់តម្លៃផ្សងក្រៅផ្លូវការនៅកម្ពុជា" (ដាក់ទៅ EU Aid), គម្រោង "វារីអគ្គិសនីនៅអាងមេគង្គក្រោម" (ដាក់ទៅ GIZ), គម្រោង "និរន្តរភាពនៃការអភិវឌ្ឍវារីអគ្គិសនី នៅទន្លេ និងដៃទន្លេមេគង្គ" (ដាក់ទៅកម្មវិធីគំនិតផ្ដួចផ្ដើមគោល នយោបាយសាធារណៈទន្លេមេគង្គក្រោមៈ LMPPI), និង "ការ ចែករំលែកទឹកឆ្លងកាត់ព្រំប្រទល់ ក្នុងអនុតំបន់ទន្លេស្រែពកនៃ អាងទន្លេមេគង្គ" (ដាក់ទៅកម្មវិធីទឹក ដី និងប្រព័ន្ធអេកូឡូស៊ីៈ WLE)។

### *កម្មវិធីអភិវឌ្ឍន៍សង្គម* (SD)

គម្រោងធំៗបីកំពុងដំណើរការទៅមុខ។ របាយការណ៍ព្រាង ស្ដីពី "ហិរញ្ញប្បទានផ្នែកសុខភាព" និង "ការចុះកិច្ចសន្យាផ្នែក សុខាភិបាល" ដែលជាសមាសធាតុនៃគម្រោង ReBUILD ក្រោមជំនួយមូលនិធិពី ក្រសួងអភិវឌ្ឍន៍អន្តរជាតិ (អង់គ្លេស) (DFID) បានចងក្រងរួចរាល់។ ក្រុមស្រាវជ្រាវគម្រោង "ការ សិក្សាពីពលកម្មកុមារ" បានកែសម្រួលរបាយការណ៍ស្ដីពី "កុមារបម្រើការងារតាមផ្ទះ" និង "ផលប៉ះពាល់នៃចំណាក ស្រុករបស់មនុស្សពេញវ័យ ទៅលើពលកម្មកុមារ" ដោយផ្អែក លើការជួយមតិពី អ្នកស្រាវជ្រាវមានជំនាញស្រដៀងគ្នានៅ ខាងក្រៅ។ ក្រុមស្រាវជ្រាវក៏បានអនុវត្តរួចរាល់នូវការចុះសិក្សា ដល់កន្លែងសម្រាប់អនុគម្រោងទី៣ ស្ដីពី "ភាពគ្មានដីធ្លី និង ពលកម្មកុមារ"។ សិក្ខាសាលាពិគ្រោះយោបល់អំពីពលកម្ម កុមារ បានរៀបចំឡើងនៅថ្ងៃទី៣០ កញ្ញា កន្លងទៅ ដោយបាន អញ្ជើញអ្នកស្រាវជ្រាវ ដៃគូអភិវឌ្ឍន៍, ជំនាញការខាងអភិវឌ្ឍន៍ តំណាងរដ្ឋាភិបាល និងបុគ្គលិកទីភ្នាក់ងារអន្តរជាតិនានា (ឧ. ILO) ឲ្យមកជួបជុំគ្នា ធ្វើការជជែកវែកញែកយ៉ាងសកម្មអំពី ការ រៀបចំច្បាប់គ្រប់គ្រងលើពលកម្មកុមារ។ ការសិក្សាពីពលកម្ម កុមារ ជាផ្នែកមួយនៃគម្រោង Cambodian-EXCEL របស់អង្គការ ទស្សនៈពិភពលោកកម្ពុជា (World Vision Cambodia) និង ទទួលមូលនិធិពី ក្រសួងការងារសហរដ្ឋអាមេរិក (USDOL) សម្រាប់រយៈពេល ៤ឆ្នាំ រហូតដល់ឆ្នាំ២០១៦។ ក្រុមស្រាវជ្រាវ ក្នុងគម្រោង "ReBUILD ដំណាក់កាលទី២" បានអនុវត្តរួចរាល់ នូវការដាក់លេខកូដទិន្នន័យ និងកំពុងវិភាគទិន្នន័យសម្រាប់ការ សិក្សាសាកល្បង។ គម្រោងរួមគ្នាមួយស្ដីពី "ការធានាជោគជ័យ នៃការអប់រំនៅថ្នាក់មធ្យមសិក្សា" កំពុងស្ថិតក្នុងដំណាក់កាល ចងក្រងរបាយការណ៍។

សំណើស្រាវជ្រាវពីរបានដាក់ស្នើឡើង គឺមាន "អង្កេតពី ការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាល" (ដាក់ទៅធនាគារ ពិភពលោក) និង "ការស្រាវជ្រាវលើការយល់ឃើញរបស់អ្នក ប្រើប្រាស់អំពី ការប្រើកងពន្យាកំណើតដើម្បីធ្វើផែនការគ្រួសារ រយៈពេលវែង" (ដាក់ទៅទីភ្នាក់ងារមូលនិធិប្រជាជននៃអង្គការ សហប្រជាជាតិៈ UNFPA)។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

នៅថ្ងៃទី១ កញ្ញា ២០១៤ បន្ទាប់ពីបំពេញមុខងារជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានជាង ១០ឆ្នាំមក លោក Larry Strange បានលាលែងពីតំណែងនេះ ហើយត្រូវបានបន្តវេនដោយ បណ្ឌិត ឆែម វិទ្ធី ដែលជាអតីតមន្ត្រីការទូតជាន់ខ្ពស់នៃអង្គការសហប្រជាជាតិ និងទើបលាលែងពីតំណែងជានាយកផ្នែកសុខភាពមនុស្ស នៃទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ។ លោក Larry Strange នឹងបន្តការងារនៅវិទ្យាស្ថាន CDRI ក្នុងតំណែងជាទីប្រឹក្សាជាន់ខ្ពស់។

ក្នុងពិធីជប់លៀងពេលល្ងាចមួយ ជូនជាកិត្តិយលដល់លោក Larry Strange បុគ្គលិកទាំងអស់របស់ CDRI បានសម្តែងនូវសេចក្តីគោរពរាប់អានចំពោះលោក និងទទួលស្គាល់នូវការរួមចំណែកដ៏ប្រសើរថ្លៃថ្លា ព្រមទាំងការប្តេជ្ញាចិត្តដ៏មោះមុតរបស់លោកចំពោះវិទ្យាស្ថាន CDRI ។ ក្នុងពិធីជប់លៀងមួយទៀតដែលរៀបចំឡើងដើម្បីបញ្ជាក់ជាផ្លូវការ នូវការរួមចំណែករបស់លោកនាយកប្រតិបត្តិចប់អាណត្តិ និងណែនាំបង្ហាញខ្លួនលោកនាយកប្រតិបត្តិថ្មី ជូនដល់ដៃគូអភិវឌ្ឍន៍នានារបស់វិទ្យាស្ថាន CDRI គេឃើញមានការចូលរួមពីសំណាក់សមាជិកបច្ចុប្បន្ន និងសមាជិកពីមុននៃក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI, រដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ជាច្រើនរបស់រដ្ឋាភិបាល, អ្នកតំណាងនៃទីភ្នាក់ងារអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និង ស្ថាប័នសិក្សាស្រាវជ្រាវថ្នាក់ជាតិនានា។ នៅថ្ងៃក្រោយៗមកទៀត លោកនាយកប្រតិបត្តិថ្មីរបស់វិទ្យាស្ថាន CDRI បានចូលជួបសំដែងការគួរសមចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ឯកឧត្តមបណ្ឌិត ជា ចាន់តូ ប្រធានកិត្តិយសនៃក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI, និង តំណាងជាន់ខ្ពស់នៃស្ថាប័នជាដៃគូនានា។

នៅខែកក្កដា នាយកផ្នែកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI បានចូលរួមក្នុងវេទិកាបណ្តាញអភិវឌ្ឍអាស៊ីបូព៌ា (EADN) ប្រចាំឆ្នាំ ២០១៣-២០១៤ នៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន។ នៅខែសីហា វិទ្យាស្ថាន CDRI បានរៀបចំកិច្ចប្រជុំតុមូលខាងគោលនយោបាយក្រោមប្រធានបទ "ការគ្រប់គ្រងឲ្យបានកាន់តែប្រសើរលើចំណាកស្រុកនៅកម្ពុជា៖ បញ្ហាចោទ បទពិសោធន៍ និងអាទិភាពគោលនយោបាយ"។ កិច្ចប្រជុំនេះ មានការចូលរួមពីសំណាក់អ្នកកសាងគោលនយោបាយជាន់ខ្ពស់ មកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង អ្នកតំណាងមកពីអង្គការពលកម្មអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីពិភាក្សាពីផលពាក់ព័ន្ធខាងគោលនយោបាយ នៃមាតុភូមិនិវត្តន៍របស់ពលករចំណាកស្រុកកម្ពុជា ដែលមិនមានឯកសារត្រឹមត្រូវប្រមាណជា ៣០០.០០០នាក់ មកពីប្រទេសថៃ នៅដើមឆ្នាំនេះ។

នៅដើមខែកញ្ញា សមាជិកនៃបណ្តាញវិភាគអភិវឌ្ឍន៍នៃមហាអនុតំបន់មេគង្គ (GMS-DAN) បានមកជួបជុំគ្នានៅរាជធានី

តទៅទំព័រ ២៥

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៨ លេខ៣ ខែកញ្ញា ឆ្នាំ២០១៤

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួលៈ ខេង សេង
សហគ្រាសបោះពុម្ព សាលាបច្ចេកទេសដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៤ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ: www.cdri.org.kh